Co-funded by the European Union

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប
NCDD

កម្រងឯកសារមេរៀនស្ដីអំពី ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

Compendium on Public Financial Management in the Cambodian Sub-National Context

អារម្ភកថា

គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (EU DAR) បានផ្តួចផ្តើមរៀបចំចងក្រងឡើងវិញនូវកម្រងឯកសារសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីផ្តល់ជាមូលដ្ឋានគ្រឹះដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសក្រុមប្រឹក្សាក្រុង ស្រុក ក្នុងការស្វែងយល់បន្ថែម និងដកស្រង់ចំណុចសំខាន់ៗ ដើម្បីយកទៅដោះស្រាយបញ្ហាប្រឈមនានាទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន និងនាពេលអនាគតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ គម្រោង EU DAR ទទួលបានថវិកាពីក្រសួងសហប្រតិបត្តការសេដ្ឋកិច្ច និងអភិវឌ្ឍនៃសហព័ន្ធអាល្លឺមង់ (BMZ) និងទទួលហិរញ្ញប្បទានរួមគ្នាពីសហភាពអឺរ៉ុប និងអនុវត្តដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ)។

កម្រងឯកសារនេះ ជាការប្រមូលផ្តុំនៃឯកសារពាក់ព័ន្ធនានា ដែលបានរៀបចំឡើងជាដំណាក់ៗ តាំងពីវគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើកទី០១ រហូតមកដល់វគ្គបណ្តុះបណ្តាលទី០៣នេះ។ វគ្គបណ្តុះបណ្តាលជាសេរីទាំង០៣នេះ ជាការផ្តួចផ្តើមរួមគ្នារវាងលេខាធិការដ្ឋានគ.ជ.អ.ប ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគម្រោង EU DAR។ វគ្គបណ្តុះបណ្តាលជាសេរីទាំង០៣នេះ បានគ្រោងរៀបចំធ្វើឡើង ក្នុងអំឡុងខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១៨ នៅក្នុងខេត្តបាត់ដំបង និងរាជធានីភ្នំពេញ។ អ្នកចូលរួមក្នុងក្នុងវគ្គបណ្តុះបណ្តាល ជាសេរីទាំង០៣នេះ គឺជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ដែលមានសមាសភាពក្នុងគណៈកម្មាធិការលទ្ធកម្ម និងគណៈ កម្មាធិការសម្របសម្រួលបច្ចេកទេសមកពីក្រុង និងស្រុកគោលដៅក្នុងខេត្តដៃគូទាំង០២ គឺខេត្តបាត់ដំបង និងខេត្តកណ្តាល។ ក្នុងអំឡុងវគ្គបណ្តុះបណ្តាលទាំង០៣នេះ ខ្លឹមសារក្របខ័ណ្ឌច្បាប់ ទ្រឹស្តីសំខាន់ៗមួយចំនួន រួមទាំង បទពិសោធន៍អនុវត្តជាក់ស្តែងប្រចាំថ្ងៃ និងការប្រឈមនានារបស់ក្រុមប្រឹក្សា ត្រូវបានលើកយកមកពិភាក្សាយ៉ាងល្អិតល្អន់។ សរុបមកវគ្គបណ្តុះបណ្តាលទាំង០៣នេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការបង្កើនចំណេះដឹង និងការផ្លាស់ប្តូរបទពិសោធន៍ជាក់ស្តែងរវាងក្រុមប្រឹក្សាក្រុង ស្រុកក្នុងខេត្តដៃគូទាំង០២។

នៅក្នុងវគ្គបណ្តុះបណ្តាលទី០១ តម្រូវការ និងទស្សនៈទាននានាទាក់ទងនឹងកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានលើកឡើង ហើយការប៉ាន់ប្រមាណចំណេះដឹងក្នុងវគ្គបណ្តុះបណ្តាលលើកទី០១នេះផងដែរ ក៏ជាមូលដ្ឋានគ្រឹះក្នុងការជួយរៀបចំឱ្យវគ្គបណ្តុះបណ្តាលជាសេរីនេះកំណត់បាននូវគោលដៅរួមមួយសមស្របផងដែរ។ ចំណែកឯវគ្គបណ្តុះបណ្តាលលើកទី០២ គឺបានផ្តោតទៅលើការសិក្សាស្វែងយល់ស៊ីជម្រៅទៅលើលិខិតបទដ្ឋាន

គតិយុត្តិសំខាន់ៗពាក់ព័ន្ធ និងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាក្នុងវដ្តថវិកា។ វគ្គបណ្តុះបណ្តាលលើកទី០៣ ផ្តោតទៅលើការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា និងផ្ទេរចំណេះដឹងទទួលបាននានាឱ្យក្លាយទៅជាការអនុវត្តមួយសមស្រប ហើយលើសពីនេះ គម្រោ EU DAR ក៏សង្ឃឹមថាក្រុមប្រឹក្សាដែលបានចូលរួមវគ្គបណ្តុះបណ្តាលជាសេរីទាំង០៣នេះ នឹងធ្វើការផ្សព្វផ្សាយបន្តដល់ជាមាជិក្រុមប្រឹក្សាផ្សេងទៀតផងដែរ។

ដើម្បីជួយដល់ក្រុមប្រឹក្សាក្រុង ស្រុក ក្នុងការអនុវត្តតួនាទី ភារកិច្ចទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្រងឯកសារនានា ដែលបានចងក្រងរួមមាន៖ សន្ទានុក្រមហិរញ្ញវត្ថុសាធារណៈ លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធសំខាន់ៗ ដែលជួយបង្ហាញផ្លូវដល់ក្រុមប្រឹក្សាក្រុង ស្រុក ឯកសារនីតិវិធីមួយចំនួនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់លក្ខណៈវិនិច្ឆ័យច្បាស់លាស់ ឧទាហរណ៍នានានៃដំណើរការរៀបចំគម្រោងថវិកា ហើយចុងក្រោយបង្អស់ គឺឧបករណ៍មួយចំនួនដែល អាចជួយដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការពិនិត្យពិច័្ឆយថវិកា។

១. សារគន្លឹះសម្រាប់អ្នកចូលរួម

២. សន្ទានុក្រមសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្នាក់ក្រោមជាតិ

៣. នីតិវិធីរៀបចំថវិកា

៤. សារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៥. អនុក្រឹត្យលេខ៣៦ ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក

៦. អនុក្រឹត្យលេខ១៧២ ស្តីអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក

៧. ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៨. ប្រកាសលេខ ៣២៤ ស្តីអំពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៩. មេរៀនស្តីអំពីវិមជ្ឈការសារពើពន្ធ និងការគ្រប់គ្រងហិរញ្ញវត្ថុ

១០. បទបង្ហាញស្តីអំពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១១. បទបង្ហាញស្តីអំពីការពិនិត្យពិច្ច័យថវិកាថ្នាក់មូលដ្ឋាន

១២. ក្រដាសកិច្ចការ “ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់មូលដ្ឋាន”

ក. ក្រដាសកិច្ចការទី០១៖ ព័ត៌មានហិរញ្ញវត្ថុ

ខ. ក្រដាសកិច្ចការទី០២៖ ព័ត៌មានហិរញ្ញវត្ថុដែលងាយយល់

គ. ក្រដាសកិច្ចការទី០៣៖ ការវិភាគថវិការបស់រដ្ឋបាលស្រុក (ការចំណាយ)

ឃ. ក្រដាសកិច្ចការទី០៤៖ ការវិភាគថវិការបស់រដ្ឋបាលស្រុក (ចំណូល)

ង. ក្រដាសកិច្ចការទី០៥៖ តារាងគណនី

ច. ក្រដាសកិច្ចការទី០៦៖ វដ្តថវិកា

១៣. បទបង្ហាញស្តីអំពីគណនេយ្យសាធារណៈ និងតារាងគណនី

១៤. បទបង្ហាញស្តីអំពីរបៀបទទួលបានភ័ស្តុតាង

១៥. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាក្នុងដំណើរការរៀបចំថវិកា អនុវត្ត និងតាមដាន

Foreword

Dear Reader,

With this compendium on Public Financial Management in the Cambodian sub-national context, the Deutsche Gesellschaft für Internationale Zusammenarbeit (German Society for International Cooperation, GIZ) intends to provide the councilmen and -women of the EU Project for Decentralisation and Administrative Reform's (EU DAR) partner districts and municipalities with a lasting foundation to tackle the current and future public-finance-related challenges in their respective constituencies. Furthermore, it is meant to serve as the cornerstone for the sharing of knowledge among the councilmen and -women and their colleagues in non-partner districts.

The information collected in this publication stems from the produced output of three workshops on Public Financial Management, which were held between September and December 2018 in the cities of Battambang and Phnom Penh. In these workshops, academic expertise on financial administration was coupled with the insights from the day-to-day challenges, encountered on the district and municipal level. These three workshops involved three stages of synergetic knowledge growth.

In the first stage, perspectives on the financial management needs were shared and current knowledge assessed, in order to establish common grounds for learning and collaboration. In the second stage, the understanding of legal frameworks and budget cycles was deepened and the importance of the councillors' role in the financial processes stressed. In the final stage, the focus lied on enacting such role and putting know-how into practice, as well as scaling up lessons from the trainings to other councillors.

Meant to accompany the councilmen and -women in their future steps, this compendium contains the following information. A lexicon on public finance jargon, the legal framework documents, which are necessary for councilmen and -women to navigate the Cambodian sub-national public financial system, procedural documents from the Ministry of Finance, which provide clear criteria and examples of the budgeting process, and finally, step-by-step instructive material for the enactment of public financial management and budget scrutiny.

Proud to present the results of this intensive collaboration, we wish you a good read.

EU Project for Decentralisation and Administrative Reform
Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH
German International Cooperation

Table of Contents

1. Participant testimonials
2. Lexicon of financial management at sub-national level
3. The budget preparation process
4. Circular on the district/municipal fund procedure 2018
5. Sub-Decree #36 on district/municipal funds
6. Sub-Decree # 172 on the district/municipal financial management system
7. Royal decree on the law of SNA financial regime and property management
8. Prakas #324 on SNA procurement committees and procurement units
9. Module on fiscal decentralisation and financial management
10. Presentation on the sub-national finance law
11. Introduction to local budget scrutiny
12. Worksheets “Public Financial Management on the Local Level”
    a. Worksheet 01 – Financial information
    b. Worksheet 02 – Easy-to-understand financial information
    c. Worksheet 03 – Budget analysis of district budgets - Expenditures
    d. Worksheet 04 – Budget analysis of district budgets - Revenues
    e. Worksheet 05 – Chart of accounts
    f. Worksheet 06 – Budget cycle
13. Introduction to public accounting and the chart of accounts
14. How to retrieve the evidence

Chapter 1
Participant testimonials

សារគន្លឹះ

សមាជិកក្រុមប្រឹក្សាស្រុកជាតួអង្គតំណាងអោយរដ្ឋបាលស្រុកជាដៃគូមិនអាចខ្វះបាន ជាមួយគណៈអភិបាល និងរដ្ឋបាលស្រុក ហើយដែលដឹងពីកិច្ចការហិរិញ្ញវត្ថុរបស់រដ្ឋបាលស្រុក ដូចជា៖ ថវិកា និងរបាយការណ៍ហិរញ្ញវត្ថុ ហើយប្រើប្រាស់តួនាទីក្នុងនាមជាអ្នកត្រួតពិនិត្យ ដើម្បីធានាថាហិរញ្ញវត្ថុរបស់ស្រុកត្រូវបានប្រើប្រាស់ត្រឹមត្រូវបំផុត ប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល ក្នុងគោលបំណងឆ្លើយតបនឹងតម្រូវការ និងការរំពឹងទុករបស់ពលរដ្ឋក្នុងក្រុង ស្រុក។

ក្រុមប្រឹក្សាក្រុង ស្រុក មានតួនាទីយ៉ាងសកម្មក្នុងដំណើរការរៀបចំផែនការថវិកា

ក្រុមប្រឹក្សាក្រុង ស្រុក យល់ដឹងកាន់តែប្រសើរ អំពីចំណូល ចំណាយរបស់រដ្ឋបាលក្រុង ស្រុក

លទ្ធភាពទទួលបាន និងការបង្ហាញព័ត៌មានហិរញ្ញវត្ថុ នឹងមានភាពប្រសើរឡើង

ការពិនិត្យពិច័យថវិកាក្រុង ស្រុក ជាការសិក្សារៀនសូត្រ និងធ្វើអោយប្រសើរឡើងនូវការប្រើប្រាស់មូលនិធិក្រុង ស្រុក ជាជាងការស្តីបន្ទោស

Chapter 2

Lexicon of financial management at sub-national level

សន្ទានុក្រមពាក្យគន្លឹះៗមួយចំនួនទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

Lexicon for financial management at SNA

អាណាប័កដើមខ្សែ (Principle budget administrator)	សំដៅដល់មន្ត្រីដែលមានសិទ្ធិពេញលេញតាមផ្លូវច្បាប់ក្នុងការបញ្ជាប្រតិបត្តិការចំណូល ចំណាយថវិកាខ្លួនឯងផ្ទាល់ដោយត្រូវគោរពទៅតាមព្រំដែននៃសិទ្ធិអំណាច និងមុខងាររបស់ខ្លួន។
អាណាប័កផ្ទេរសិទ្ធ (Delegated budget administrator)	សំដៅដល់មន្ត្រីដែលទទួលសិទ្ធិប្រទានពីអាណាប័កដើមខ្សែសម្រាប់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
រជ្ជទេយ្យបុរេប្រទាន (Petty Cash Advance)	គឺជាការចំណាយលើដំណើរការរដ្ឋបាល និងចំណាយដែលមានលក្ខណៈប្រចាំ ចាំបាច់ បន្ទាន់ និងមិនអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់ធម្មតាបាន។
រជ្ជទេយ្យករបុរេប្រទាន (Petty Cash Advance Officer)	គឺជាមន្ត្រីទទួលបន្ទុកលើការចំណាយលើដំណើរការរដ្ឋបាលនិងចំណាយដែលមានលក្ខណៈប្រចាំ ចាំបាច់ បន្ទាន់ និងមិនអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់ធម្មតាបាន។
វិភាជន៍ថវិកា (Budget allocation)	សំដៅដល់ការផ្ទេរថវិកាពីថ្នាក់ជាតិទៅតាមខ្ទង់ចំណាយនីមួយៗ។
រជ្ជទេយ្យចំណូល (Revenue account)	គឺជាចំណូលមិនមែនសារពើពន្ធដែលមានលក្ខណៈជាប្រចាំ មានចំនួនទឹកប្រាក់តិចពុំមានកិច្ចសន្យា។
រជ្ជទេយ្យចំណាយ (Expenditure account)	គឺជាការចំណាយមានលក្ខណៈជាប្រចាំ មានចំនួនទឹកប្រាក់តិច ពុំមានកិច្ចសន្យា។
ហិរញ្ញប្បទាន (Financing)	គឺសំដៅដល់ការផ្តល់និងការទទួលប្រាក់ឬមូលនិធិ សម្រាប់គាំទ្រដំណើរការគម្រោងធុរកិច្ចអ្វីមួយ។
ហិរញ្ញប្បទានឱនភាព (Deficit financing)	មូលនិធិសម្រាប់ធ្វើការចំណាយតាមរយៈកម្ចី។
អតិរេកថវិកា (surplus)	សំដៅដល់ថវិកាដែលនៅសល់ពីគម្រោងចំណាយដែលបានគ្រោងនៅដើមឆ្នាំ។
ឱនភាពថវិកា (Budget deficit)	សំដៅដល់ចំនួនទឹកប្រាក់ដែររដ្ឋាភិបាលចំណាយលើសចំណូល។
និយ័តកម្មឥណទានថវិកា (Budget credit reallocation)	សំដៅដល់ការបង្វែរ (និយ័តភាព)ឥណទានថវិកាពីអនុគណនីមួយទៅអនុគណនីមួយ និងពីគណនីមួយទៅគណនីមួយ និង ពីជំពូកមួយទៅជំពូកមួយ។

ចំណាយចរន្ត (Current expenditure)	សំដៅលើការចំណាយជាប្រចាំសម្រាប់ទ្រទ្រង់កិច្ចប្រតិបត្តិការផ្នែករដ្ឋបាល។
ចំណាយជាមូលធន (Capital expenditure)	សំដៅលើការចំណាយពាក់ព័ន្ធនឹងការវិនិយោគក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីបង្កើនចំណូលនៅពេលអនាគត។
ចំណូលចរន្ត (Recurrent revenue)	សំដៅលើចំណូជាប្រចាំរបស់រដ្ឋបាលស្រុកដែលទទួលបានពីរចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។
ចំណូលជាមូលធន (Capital revenue)	សំដៅលើចំណូលដែរមានប្រភពមកពី (ប្រាក់កម្ចី/ជំនួយឥតសំណងរបស់ដៃគូអភិវឌ្ឍ/ និងមូលនិធិគាំទ្រ) ទាំងក្នុងស្រុក និងក្រៅប្រទេស។
ចំណូលពិត (Real revenue)	សំដៅដល់ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។
ចំណូលសារពើពន្ធ (Fiscal revenue)	គឺជាពន្ធអារក និងសិទ្ធិដែលត្រូវបានបង្វែលជាកាតព្វកិច្ចទៅឱ្យរដ្ឋ រួមមាន៖ ចំណូលសារពើពន្ធក្នុងប្រទេស និងចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស។
ឧបត្ថម្ភធន (Subsidy)	សំដៅដល់ជំនួយជាប្រាក់(ឬការបន្ធូលបន្ថយ ឬលើកលែងពន្ធ) ដោយរដ្ឋាភិបាល ដើម្បីលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបំពេញការងារ/អភិវឌ្ឍន៍។
ទ្រព្យសកម្មរយៈពេលខ្លី (Short term asset)	គឺជាទ្រព្យសម្បត្តិដែលត្រូវលក់ ឬបង្វែលជាសាច់ប្រាក់ដើម្បីទូទាត់បំណុលក្នុងរយៈពេលមួយឆ្នាំ។
ទ្រព្យសកម្មរយៈពេលវែង (Long term asset)	ជាទ្រព្យសម្បត្តិដែលត្រូវលក់ ឬបង្វែលជាសាច់ប្រាក់ដើម្បីទូទាត់បំណុល ក្នុងរយៈពេលមួយឆ្នាំ។
អចលកម្មអរូបី (Intangible asset)	ទ្រព្យសម្បត្តិមិនមែនរូបវ័ន្ត តែវាមានតម្លៃដោយសិទ្ធិផ្ដល់ផលជាកម្មសិទ្ធិ។
អចលកម្មរូបី (Tangible asset)	ទ្រព្យសម្បត្តិរូបវ័ន្ត ដែលមានតម្លៃដោយសិទ្ធិផ្ដល់ផលជាកម្មសិទ្ធិ។
គណីចរន្ត (Current account)	គណនេយ្យមួយត្រូវប្រើ សម្រាប់គត់ត្រាគណនេយ្យត្រូវសង ឬ គណនេយ្យត្រូវទារជាមួយភាគីដ៏ទៃទៀត។
មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខ័ណ្ឌ (Unconditional transferred Fund)	គឺជាមូលនិធិដែលក្រុមប្រឹក្សាប្រើប្រាស់ដើម្បី៖ - បំពេញភារកិច្ចតាមផ្លូវច្បាប់ - បំពេញមុខងារ ភារកិច្ច ក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ - ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង - ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា។

មូលនិធិផ្ទេរមាន ភ្ជាប់លក្ខខ័ណ្ឌ (Conditional transferred Fund)	គឺជាមូលនិធិដែលក្រុមប្រឹក្សាប្រើប្រាស់៖ - ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ច មួយ ឬច្រើនដែលត្រូវបាន ផ្ទេរឱ្យក្រុមប្រឹក្សា តាមការ ប្រគល់មុខងារ ឬការធ្វើប្រតិភូកម្មមុខងារ ឬ - ដើម្បីបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស មួយ ឬច្រើនដែលក្រសួង ស្ថាប័នរបស់រដ្ឋាភិបាលធ្លាប់ បានអនុវត្ត ឬ - សម្រាប់គោលបំណងជាកាតព្វកិច្ចមួយ ឬច្រើនដែលបានកំណត់។
ទ្រព្យសម្បត្តិ (Asset)	សំដៅទៅលើគ្រឿងម៉ាស៊ីន យានយន្ត ឧបករណ៍ គ្រឿងសង្ហារឹម សម្ភារៈការិយាល័យ លិខិតស្នាម ឯកសារ និងដីសាធារណៈ អចលនទ្រព្យសាធារណៈ សំណង់សាធារណៈ ឬ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដូចជា ស្ពាន អគារ ព្រែក ផ្លូវ ឬវត្ថុប្រហាក់ប្រហែលគ្នា។
គណនេយ្យហិរញ្ញវត្ថុ (*Financial Accounting)*	គឺជាការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុដែលធ្វើឡើងតាមរយៈគណនីប្រាក់បញ្ញើរបស់រដ្ឋបាលស្រុក ក្រុងនៅរតនាគារខេត្ត និងដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ និងទាន់ពេលវេលាសម្រាប់ផ្តល់ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក។
គណនេយ្យថវិកា (*Budgetary Accounting)*	គឺជាការតាមដាន និងរាយការណ៍អំពីការអនុវត្តថវិកាដើម្បីធានាថាការចំណាយត្រូវ បានធ្វើឡើងនៅកម្រិតឥណទានថវិកាដែលបានអនុញ្ញាត ហើយចំណូលត្រូវមាន សង្គតិភាពជាមួយនឹងថវិកាដែរគ្រោង។
ក្របខណ្ឌចំណាយរយៈ ពេលមធ្យម Medium Term Expenditure Framework:	សំដៅដល់ការធ្វើការផែនការចំណាយសាធារណៈដែលមានរយៈពេលបី (០៣)ឆ្នាំ ដល់ប្រាំ(០៥)ឆ្នាំដែលកំណត់តម្រូវការធនធានពេលអនាគតសម្រាប់សេវាកម្ម និងការអភិវឌ្ឍដែលស្ថិតក្នុងបរិបទនៃការប៉ាន់ស្មានធនធានសរុបរបស់រដ្ឋបាលថ្នាក់ក្រោម ជាតិដែលបានមកពីប្រភពក្នុងមូលដ្ឋាន និងប្រភពពីខាងក្រៅ។

ឯកសារយោង៖

- ច្បាប់រៀបចំអង្គការ (២០០៨)
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ(២០១១)
- អ.ន.ក្រ លេខ ១៧២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក (២០១២)
- ប្រកាសលេខ ២៧៥ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ(២០១៥)
- Guide to the national budget, 2015 (សៀវភៅណែនាំស្តីពីថវិកាជាតិ) http://ngoforum.org.kh/files/ce61ca5dee2c7899d9c78565e3252748-Guide-to-the-National-Budget-English.pdf
- (https://www.scribd.com/doc/315539240/english-khmer-glossary-of-accounting-and-auditing-terminology)
- (https://www.facebook.com/cvnlawyer/posts)

Chapter 3

The budget preparation process

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

បទបង្ហាញសង្ខេប
ស្តីពី
ការរៀបចំគម្រោងថវិការបស់រដ្ឋបាលក្រុងស្រុក

រៀបចំដោយៈ លោក ចន ជីវ័ន្ត ប្រធានការិយាល័យ
នៃអគ្គនាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

<u>មាតិកា</u>

១. ក្របខ័ណ្ឌច្បាប់ និង លិខិតបទដ្ឋានពាក់ព័ន្ធ

២. ដំណើរការរៀបចំគម្រោងថវិការដ្ឋបាលក្រុង ស្រុក

២.១ ផ្នែកចំណូល

២.១.១ ចំណូលមិនមែនសារពើពន្ធ

២.១.២ ចំណូលសារពើពន្ធ

២.២ ផ្នែកចំណាយ

២.២.១ បន្ទុកបុគ្គលិក (ជំពូក ៦៤ រួមមានៈ បៀវត្ស និងការឧបត្ថម្ភផ្សេងៗ...។ល។)

២.២.២ ចំណាយផ្នែករដ្ឋបាល (ជំពូក ៦០ និង ៦១ ៦២...)

២.២.៣ ចំណាយទ្រទ្រង់ដល់ការអភិវឌ្ឍមូលដ្ឋាន (ជំពូក ៦១ អនុគណនី ៦១០៥ ,ជំពូក ២១)

៣. ការវេចខ្ចប់ថវិកា

៣.១ ការអនុម័តថវិកាដោយក្រុមប្រឹក្សា

៣.២ ការធ្វើអនុលោមភាពថវិកាដោយអភិបាលខេត្ត

៣.៣ ការប្រមូលសរុបថវិកាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៤. ការអនុតម័តថវិកា

៤.១ ដាក់ជូនទីស្តីកាគណៈរដ្ឋមន្ត្រីពិនិត្យ

៤.២ ដាក់ជូនសភាពិនិត្យ និងអនុម័ត

៤.៣ ប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ

....

ជំហានទី០៣

តើដំណើរការពិនិត្យពិច័យថវិកានៅមូលដ្ឋានត្រូវរៀបចំដោយរបៀបណា?

(**ដំណើរការរៀបចំថវិការបស់រដ្ឋបាលក្រុងស្រុក**)

១. ក្របខ័ណ្ឌច្បាប់ និង លិខិតបទដ្ឋានពាក់ព័ន្ធ

- ប្រច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ព្រះរាជក្រមលេខ នសដែលប្រកាស ២០០៨ខែឧសភា ឆ្នាំ ២២ចុះថ្ងៃទី ០១៧/០៥០៨/រកម/ ឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- អនុក្រឹត្យលេខ ៥០ អនក្របក ចុះថ្ងៃទី.១១ ខែមេសា ឆ្នាំ២០១៨ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិ ក្រុង ស្រុក
- ប្រកាសលេខ ៥២៣ សហវ ប្រក.ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- សារាចរណែនាំស្តីពីនីតិវិធិបច្ចេកទេសក្នុងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦
- អនុក្រឹត្យលេខ ៣៦ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សា
- ....
- ....

២. ដំណើរការរៀបចំគម្រោងថវិការដ្ឋបាលក្រុង ស្រុក

២.១ ផ្នែកចំណូល

២.១.១ ចំណូលមិនមែនសារពើពន្ធ

- ថវិកាឧបត្ថម្ភពីថ្នាក់ជាតិ (មូលនិធិក្រុង ស្រុក)

  អត្រាផ្ទេរធនធានពីថ្នាក់ជាតិមានកម្រិត និងថេរវេលាចំនួន ៥ ឆ្នាំ÷

  ១.១% នៃចំណូលចរន្តថវិកាជាតិអនុម័តក្នុងឆ្នាំ២០១៨

  ១.២% នៃចំណូលចរន្តថវិកាជាតិអនុម័តក្នុង២០១៩

  ១.៣% នៃចំណូលចរន្តថវិកាជាតិអនុម័តក្នុង២០២០

  ១.៤% នៃចំណូលចរន្តថវិកាជាតិអនុម័តក្នុងឆ្នាំ២០២១

  ១.៥% នៃចំណូលចរន្តថវិកាជាតិអនុម័តក្នុងឆ្នាំ២០២២

***ការវិភាជមូលនិធិក្រុងស្រុកជូនរដ្ឋបាលក្រុងស្រុកនីមួយៗ

មូលនិធិក្រុងស្រុកចែកចេញជាពីរសមាសភាគ÷

១. រដ្ឋបាលទូទៅ (មានបន្ទុកបុគ្គលិក និង ចំណាយប្រតិបត្តិការរដ្ឋបាល)

១.១ ការគណនាបន្ទុកបុគ្គលិក

១.២ ការគណនាចំណាយប្រតិបត្តិការរដ្ឋបាល

មិនលើសពី ២៥% នៃផលដករវាង មូលនិធិសរុប - បន្ទុកបុគ្គលិក

២. អភិវឌ្ឍមូលដ្ឋាន

សំណល់នៃផលដក មូលនិធិសរុប - បន្ទុកបុគ្គលិក - ចំណាយប្រតិបត្តិការរដ្ឋបាល

៣. ការបែងចែកសមាសភាគនីមួយៗទៅអោយរដ្ឋបាលក្រុងស្រុកនីមួយ

៣.១ បន្ទុកបុគ្គលិក

ត្រូវបានគណនាចេញពីរដ្ឋបាលក្រុងស្រុកនីមួយជាក់ស្តែង តាមនីតិវិធីជំនាញបច្ចេកទេស

៣.២ ចំណាយប្រតិបត្តិការរដ្ឋបាល

- ចំនួន ៤០% ជាចំណែកស្មើគ្នា
- ចំនួន ៣០% នៃចំនួនក្រុមប្រឹក្សា និង ចំនួនគណៈអភិបាលក្រុង ស្រុកនីមួយៗ
- ចនួន ៣០% នៃចំនួនមន្ត្រី និង បុគ្គលិក

៣.៣ ចំណាយប្រតិបត្តិការរដ្ឋបាល

- ចំនួន ៤០% ជាចំណែកស្មើគ្នា
- ចំនួន ២០% នៃសមាមាត្រចំនួនប្រជាជនក្នុងរដ្ឋបាលក្រុងស្រុកនីមួយៗ
- ចំនួន ៤០% នៃសមាមាត្រសន្ទស្សន៍ភាពក្រីក្ររបស់រដ្ឋបាលក្រុងស្រុកនីមួយៗ

***ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងជូនដំណឹងអំពីតួលេខវិភាជនេះក្នុងខែមិថុនា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ........សហវ........

ថ្ងៃ........ខែ........ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី........ ខែ........ ឆ្នាំ២០១៨

ជម្រាបជូន

ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលខេត្ត

កម្មវត្ថុ៖ ការវិភាជមូលនិធិក្រុង ស្រុក ជូនរដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។

យោង៖ អនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ ស្ដីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលខេត្តមេត្តាជ្រាបថា÷ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុបានធ្វើការវិភាជមូលនិធិក្រុង ស្រុក ជូនរដ្ឋបាលក្រុង ស្រុកសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។

ក្រោយពីទទួលបានតារាងវិភាជន៍មូលនិធិក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សូមឯកឧត្តម លោកជំទាវមេត្តាជូនដំណឹង និងជួយណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំទៅតាមទម្រង់មាតិកាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួចដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យនិងអនុម័ត មុននឹងបញ្ជូនទៅអភិបាលនៃគណៈអភិបាលខេត្តដើម្បីពិនិត្យ និងបញ្ជាក់អនុលោមភាព។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលខេត្តមេត្តាចាត់ចែងផ្សព្វផ្សាយ និងណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនទៅតាមខ្លឹមសារនៃសារាចរណែនាំស្ដីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាឆ្នាំ២០១៩ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សូមឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលខេត្ត ទទួលនូវការគោរពរាប់អានពីខ្ញុំ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋលេខាធិការ

បណ្ឌិត ជុំ គឹមឡេង

ចម្លងជូន:

- ក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- អគ្គនាយកដ្ឋានរតនាគារជាតិ
- គ្រប់សាលាខេត្តទាំង២៤ (ដើម្បីផ្សព្វផ្សាយ)
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តទាំង២៤ (ដើម្បីសហការអនុវត្ត)
- គ្រប់រតនាគារខេត្តទាំង២៤ (ដើម្បីសហការអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

លេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
2. Sangkat Wat Phnom . Khan Daun Penh. Phnom Penh. CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧
Phone : 855-23-724 664 Fax : 855-23-427 798

តារាងឧបសម្ព័ន្ធភ្ជាប់តាមលិខិតលេខ   ចុះថ្ងៃទី   ខែ   ឆ្នាំ២០១៨

ការវិភាជមូលនិធិក្រុង ស្រុក ឆ្នាំ២០១៩

ឯកតា: លានរៀល

លេខកូដ	ឈ្មោះក្រុង ស្រុក	រដ្ឋបាលទូទៅ	អភិវឌ្ឍន៍	សរុប
សរុបរួម		132,890.00	59,170.00	192,060.00
01	បន្ទាយមានជ័យ	6,538.65	2,929.99	9,468.64
02	បាត់ដំបង	10,048.56	4,624.31	14,672.87
03	កំពង់ចាម	8,072.79	3,436.03	11,508.82
04	កំពង់ឆ្នាំង	5,976.22	2,522.39	8,498.61
05	កំពង់ស្ពឺ	6,513.81	2,741.12	9,254.93
06	កំពង់ធំ	6,532.35	2,765.56	9,297.91
07	កំពត	6,735.67	2,572.39	9,308.06
08	កណ្តាល	9,153.31	3,776.39	12,929.70
09	កោះកុង	3,754.98	1,911.87	5,666.85
10	ក្រចេះ	4,172.96	1,894.46	6,067.42
11	មណ្ឌលគិរី	2,890.72	1,383.60	4,274.32
13	ព្រះវិហារ	5,084.50	2,365.37	7,449.87
14	ព្រៃវែង	9,499.83	4,259.69	13,759.52
15	ពោធិ៍សាត់	4,270.27	1,954.62	6,224.89
16	រតនគិរី	5,182.23	2,536.55	7,718.78
17	សៀមរាប	8,577.70	3,994.95	12,572.65
18	ព្រះសីហនុ	2,905.52	1,159.33	4,064.85
19	ស្ទឹងត្រែង	3,137.68	1,456.28	4,593.96
20	ស្វាយរៀង	5,648.81	2,500.45	8,149.26
21	តាកែវ	7,743.30	3,350.23	11,093.53
22	ឧត្តរមានជ័យ	3,151.77	1,507.55	4,659.32
23	កែប	1,079.64	543.96	1,623.60
24	ប៉ៃលិន	1,158.39	550.89	1,709.28
25	ត្បូងឃ្មុំ	5,060.34	2,432.02	7,492.36

តារាងឧបសម្ព័ន្ធភ្ជាប់តាមលិខិតលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៨

ការវិភាជមូលនិធិក្រុង ស្រុក ឆ្នាំ២០១៩

ឯកតា: លានរៀល

លេខកូដ	ឈ្មោះក្រុង ស្រុក	រដ្ឋបាលទូទៅ	អភិវឌ្ឍន៍	សរុប
06	**កំពង់ធំ**	**6,532.35**	**2,765.56**	**9,297.91**
0601	បារាយណ៍	981.57	421.67	1,403.24
0602	កំពង់ស្វាយ	837.36	363.25	1,200.61
0603	ស្ទឹងសែន	769.00	301.82	1,070.82
0604	ប្រាសាទបល្ល័ង្គ	709.34	321.43	1,030.77
0605	ប្រសាទសំបូរ	734.96	305.38	1,040.34
0606	សណ្ដាន់	738.38	320.39	1,058.77
0607	សន្ទុក	844.66	351.52	1,196.18
0608	ស្ទោង	917.08	380.10	1,297.18

-ចំណូលកាតព្វកិច្ច

-ចំណូលពីដៃគូអភិវឌ្ឍន៍....។ល។

-ចំណូលពីឧបករណ៍វិនិយោគថ្នាក់ក្រោមជាតិ (SNIFF)

-ពន្ធចែករំលែកពីខេត្តជូនរដ្ឋបាលក្រុង ស្រុកចំណុះ (3%)

-ចំណូលពីដៃគូអភិវឌ្ឍន៍....។ល។

២.១. ចំណូលសារពើពន្ធ

-ពន្ធចែករំលែកពីខេត្តជូនរដ្ឋបាលក្រុង ស្រុកចំណុះ (3%)

២.២ ផ្នែកចំណាយ

២.២.១ បន្ទុកបុគ្គលិក (ជំពូក ៦៤ រួមមានៈ បៀវត្ស និងការឧបត្ថម្ភផ្សេងៗ...។ល។)

២.២.២ ចំណាយផ្នែករដ្ឋបាល (ជំពូក ៦០ និង ៦១ ៦២...)

២.២.៣ ចំណាយទ្រទ្រង់ដល់ការអភិវឌ្ឍមូលដ្ឋាន (ជំពូក ៦១ អនុគណនី ៦១០៥ ,ជំពូក ២១)

៣. ការវេចខ្ចប់ថវិកា

៣.១ ការអនុម័តថវិកាដោយក្រុមប្រឹក្សា (១៥ កក្កដា)

៣.២ ការធ្វើអនុលោមភាពថវិកាដោយអភិបាលខេត្ត

៣.៣ ការបូកសរុបថវិកាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៤. ការអនុតម័តថវិកា

៤.១ ដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យ

៤.២ ដាក់ជូនសភាពិនិត្យ និងអនុម័ត

៤.៣ ប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ

ចប់

....

Chapter 4

Circular on the district/municipal fund procedure 2018

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០៦........សហវ........

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ២០១៧

សារាចរណែនាំ
ស្តីពី
នីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៨

មាត្រា ៣៥ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បាន កំណត់អំពីប្រតិទិននៃកិច្ចដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជា ៣ ដំណាក់កាលគឺ: **ដំណាក់កាលទី១:** ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីខែមីនា ដល់ ខែឧសភា **ដំណាក់កាលទី២:** ការរៀបចំកញ្ចប់ថវិកា ពីខែមិថុនា ដល់ខែកញ្ញា និង**ដំណាក់កាលទី៣:** ការអនុម័តថវិកា ពីខែតុលា ដល់ខែធ្នូ។ ក្នុងដំណាក់កាលទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០១៨។ ជាបន្ទាប់ នៅក្នុងដំណាក់កាលទី២ ដែលជាដំណាក់កាលរៀបចំកញ្ចប់ថវិកា រាជរដ្ឋាភិបាលបានចេញសារាចរណែនាំ លេខ ០៤ សរណន ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨។ ផ្អែកលើសារាចរណែនាំនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៨។

ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចរៀបចំគម្រោងថវិកាប្រចាំ ឆ្នាំ២០១៨ របស់ខ្លួន ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ឆ្នាំ២០១៨ របស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចតទៅ ÷

គម្រោងចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបានរៀបចំទៅតាមទម្រង់ និង ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដូចបានចែងក្នុងតារាងឧបសម្ព័ន្ធទី១ (តារាងសរុបចំណូលថវិការបស់ថ្នាក់រដ្ឋបាលនីមួយៗ) តារាងឧបសម្ព័ន្ធទី២ (តារាងសរុបចំណាយថវិការបស់ថ្នាក់រដ្ឋបាលនីមួយៗ)។

គម្រោងចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាដែលបានរៀបចំដោយរដ្ឋបាលនីមួយៗក្នុងគោលដៅ ដើម្បីធានាឲ្យបានប្រសិទ្ធភាពថវិកា និង ការផ្សារភ្ជាប់ផែនការអភិវឌ្ឍទៅនឹងគម្រោងថវិការបស់រដ្ឋបាលនីមួយៗ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom . Khan Daun Penh. Phnom Penh. CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ថ្នាក់រដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដកស្រង់ជូន ដើម្បីរៀបចំគម្រោងថវិការបស់ខ្លួន និងផ្ញើជូនទៅតាមការកំណត់ដូចខាងក្រោម ÷

រដ្ឋបាលសង្កាត់ ត្រូវផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សាសង្កាត់បានអនុម័តរួចទៅរដ្ឋបាលក្រុង និងរដ្ឋបាលរាជធានីយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៧។

រដ្ឋបាលខណ្ឌ ត្រូវផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សាខណ្ឌបានអនុម័តរួចទៅរដ្ឋបាលរាជធានី យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៧។

រដ្ឋបាលឃុំ ត្រូវផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សាឃុំបានអនុម័តរួច ទៅរដ្ឋបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧។

រដ្ឋបាលក្រុង ត្រូវផ្ញើគម្រោងថវិកា (រួមបញ្ចូលទាំងគម្រោងថវិកាសង្កាត់) ដែលក្រុមប្រឹក្សាក្រុង បានអនុម័តទៅរដ្ឋបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧។

រដ្ឋបាលស្រុក ត្រូវផ្ញើគម្រោងថវិកា ដែលក្រុមប្រឹក្សាស្រុកបានអនុម័តទៅរដ្ឋបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧។

រដ្ឋបាលខេត្ត ត្រូវផ្ញើគម្រោងថវិកាដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួចទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧។

រដ្ឋបាលរាជធានី ត្រូវផ្ញើគម្រោងថវិកា (រួមបញ្ចូលគម្រោងថវិកាខណ្ឌនិងសង្កាត់) ដែលក្រុមប្រឹក្សារាជធានីបានអនុម័តរួចទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ត្រូវរៀបចំកម្មវិធីដោយសម្របសម្រួលជាមួយអភិបាលនៃគណៈអភិបាលខេត្ត ដើម្បីពិនិត្យ និងបញ្ជាក់អនុលោមភាពលើគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក ដោយមានការចូលរួមពីមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវធ្វើការបូកសរុបថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រចាំរាជធានី ខេត្តនីមួយៗតាមគំរូតារាងឧបសម្ព័ន្ធទី១" ក " ១" ខ "និង ១" គ " (តារាងសរុបចំណូលថវិការបស់រាជធានី ខេត្ត ក្រុង ស្រុក) និងគំរូតារាងឧបសម្ព័ន្ធទី២" ក " ២ " ខ "និង ២ " គ " (តារាងសរុបចំណាយថវិការបស់រាជធានី ខេត្ត ក្រុង ស្រុក) និងផ្ញើជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧។

ការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគោរពទៅតាមគោលការណ៍តុល្យភាពនៃថវិកា។ រាល់ការវិភាជន៍ថវិកាតាមខ្ទង់ចំណាយលម្អិតទាំងអស់ ត្រូវស្ថិតក្នុងក្របខ័ណ្ឌដែលគម្រោងចំណូលសរុបអាចធានាប៉ាន់ប្រមាណបានជាក់ស្តែង អាណាប័ករបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវធ្វើការគិតគូររៀបចំគម្រោងចំណូលសរុប ដើម្បីធ្វើជាមូលដ្ឋានក្នុងការវិភាជគម្រោងចំណាយ។

ចំពោះរដ្ឋបាលខេត្តមួយចំនួនដែលត្រូវជ្រើសរើសដើម្បីអនុវត្តសាកល្បងថវិកាកម្មវិធីនៅឆ្នាំ២០១៨ ត្រូវយកចិត្តទុកដាក់រៀបចំ និងបែងចែកថវិកាទៅតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងជាពិសេសលទ្ធផលអំពីប្រសិទ្ធភាពនៃការបែងចែក ឬធាតុចេញ ដែលនឹងសម្រេចបាន ដើម្បីសម្រេចគោលបំណងគោលនយោបាយ

ដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន។ ក្នុងន័យនេះ ជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់ធ្វើជាអំណះអំណាង និងគាំទ្រដល់ការរៀបចំ និងការពិភាក្សាចរចារគម្រោងថវិការបស់ខ្លួន តាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។ រដ្ឋបាលខេត្ត ដែលត្រូវអនុវត្តសាកល្បងថវិកាកម្មវិធី ត្រូវរៀបចំរចនាសម្ព័ន្ធថវិកាកម្មវិធី និងគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០១៨ ទៅតាមទម្រង់ដូចក្នុងតំរូតារាងឧបសម្ព័ន្ធទី៣ ជូនភ្ជាប់មកជាមួយ និងត្រូវរៀបចំឲ្យទាន់ពេលវេលា ដូចបានកំណត់ខាងលើ។

ក. អំពីគម្រោងចំណូល

រាជរដ្ឋាភិបាលបានកំណត់ក្របខ័ណ្ឌចំណូលថវិកាសម្រាប់ឆ្នាំ២០១៨ គ្រោងសម្រេចឲ្យបាន ១៨,៧៥% នៃផ.ស.ស. គឺមានកំណើន ០,២១ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១១,៩% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។ ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឲ្យបានប្រមាណ ១៨,៦០% នៃផ.ស.ស. គឺមានកំណើន ០,១៩ ពិន្ទុភាគរយនៃផ.ស.ស ឬកើនឡើង ១១,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ ក្នុងនោះចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាគ្រោងសម្រេចឲ្យបាន ៨,៤១% នៃផ.ស.ស. គឺមានកំណើន ០,២៤ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៤,០% ធៀបច្បាប់ថវិកាឆ្នាំ២០១៧, ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវគ្រោងសម្រេចឲ្យបាន ៦,៨១% នៃផ.ស.ស គឺមានកំណើន ០,២២ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៤,៣% ធៀបនឹង ច្បាប់ថវិកាឆ្នាំ២០១៧, និងចំណូលមិនមែនសារពើពន្ធ ត្រូវគ្រោងសម្រេចឲ្យបាន ២,៥០% នៃផ.ស.ស. គឺថយចុះ ០,១១ ពិន្ទុភាគរយនៃផ.ស.ស. ប៉ុន្តែមានកំណើន ៦,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។

ក-១. គម្រោងចំណូលចរន្ត

ក-១-១. ថ្នាក់រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំគម្រោងចំណូលផ្អែកលើមូលដ្ឋានប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ដែលបានកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ។

- **ចំណូលសារពើពន្ធ ត្រូវបានគ្រោងដោយផ្អែកលើ ÷**
  + លទ្ធផលដែលសម្រេចបានក្នុងឆ្នាំកន្លងមក
  + លទ្ធផលដែលទទួលបាន និងការប៉ាន់ស្មានលទ្ធផលសរុបដែលអាចសម្រេចបានក្នុងឆ្នាំកំពុងអនុវត្ត
  + ប៉ាន់ស្មានលើការវិវត្តសេដ្ឋកិច្ចអាជីវកម្មដ្ឋាននៅពេលខាងមុខ
  + ការប្រែប្រួលដែលអាចកើតមានឡើងដោយអត្រា និងចំនួនមូលដ្ឋានប្រមូលពន្ធ
  + ពង្រឹង និងកែលម្អរដ្ឋបាលពន្ធដារ ។
- **ចំណូលមិនមែនសារពើពន្ធ ត្រូវបានគ្រោងដោយផ្អែកលើ ÷**
  + កិច្ចការទាំងឡាយដែលនាំឲ្យមានផលទុនចំណូលដូចជា កិច្ចសន្យាជួល សៀវភៅបន្ទុកសេវាកម្ម និងការកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+ ស្ថិតិមុខសញ្ញាប្រមូលក្នុងឆ្នាំកំពុងអនុវត្ត និងការវិវត្តសេដ្ឋកិច្ចដែលនាំមកនូវមុខសញ្ញាចំណូលថ្មី

+ ស្ថិតិបំណុលដែលពុំទាន់បានដោះស្រាយ

+ ពង្រឹង និងជំរុញការអនុវត្តប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិកាឧបត្ថម្ភធនលើការគ្រប់គ្រង និងប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។

ក-១-១-១. គម្រោងចំណូលសរុបរបស់រដ្ឋបាលរាជធានី ត្រូវរួមបញ្ចូលទាំងគម្រោងចំណូលរបស់ខណ្ឌ និងសង្កាត់ទាំងអស់ចំណុះរដ្ឋបាលរាជធានី ដែលបានពីការបែងចែកនិងផ្ទេរមកពីមូលនិធិឃុំ សង្កាត់ នៅថ្នាក់ជាតិ និងចំណូលដែលរដ្ឋបាលខណ្ឌ និងសង្កាត់ប្រមូលបានដោយខ្លួនឯង។

ផ្អែកលើមូលដ្ឋានកញ្ចប់គម្រោងចំណូលថវិកាប្រចាំឆ្នាំដែលបានកំណត់រួច អភិបាលនៃគណៈអភិបាលរាជធានីត្រូវធ្វើការបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិការបស់ខណ្ឌ និងសង្កាត់នីមួយៗ ដើម្បីរៀបចំគម្រោងថវិកាលម្អិតរបស់ខ្លួន។

ក-១-១-២. ការបែងចែកកញ្ចប់ថវិកាសម្រាប់ខណ្ឌនីមួយៗត្រូវផ្អែកលើ ៖

- កញ្ចប់ថវិការបស់ខណ្ឌនីមួយៗដែលបានប្រើប្រាស់ក្នុងឆ្នាំកន្លងមក
- ចំណូលដែលរដ្ឋបាលខណ្ឌប្រមូលបានដោយខ្លួនឯង
- តម្រូវការចាំបាច់មួយចំនួនរបស់ខណ្ឌនីមួយៗដែលបានកំណត់ជាធរមាន
- តម្រូវការក្នុងការអនុវត្តមុខងារដែលអភិបាលនៃគណៈអភិបាលរាជធានីពិនិត្យឃើញថាសមស្រប ត្រូវធ្វើប្រតិភូកម្មទៅឱ្យអភិបាលនៃគណៈអភិបាលខណ្ឌនីមួយៗ។

ក-១-១-៣. ការបែងចែកកញ្ចប់ថវិកាសម្រាប់សង្កាត់នីមួយៗត្រូវផ្អែកលើ ៖

- កញ្ចប់មូលនិធិសង្កាត់នីមួយៗ ដែលទទួលបានពីការបែងចែកមូលនិធិឃុំ សង្កាត់ពីថ្នាក់ជាតិ
- ចំណូលដែលរដ្ឋបាលសង្កាត់ប្រមូលបានដោយខ្លួនឯង
- តម្រូវការក្នុងការអនុវត្តមុខងារ ដែលអភិបាលនៃគណៈអភិបាលរាជធានីពិនិត្យឃើញថាសមស្រប ត្រូវធ្វើប្រតិភូកម្មទៅឱ្យចៅសង្កាត់នីមួយៗ។

ក-១-២. ថ្នាក់រដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំគម្រោងចំណូល ដោយផ្អែកលើតួលេខដែលបានបែងចែក និងផ្ទេរមកពីថ្នាក់ជាតិនូវមូលនិធិក្រុង ស្រុក ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានជូនដំណឹង និងចំណូលដែលរដ្ឋបាលក្រុង ស្រុកប្រមូលបានដោយខ្លួនឯង (ចំណូលប្រមូលពីការផ្តល់សេវារដ្ឋបាលរបស់ក្រុង ស្រុក) ព្រមទាំងប្រភពចំណូល ផ្សេងៗពីការផ្ទេរមុខងាររបស់ក្រសួង ស្ថាប័នមករដ្ឋបាលក្រុង ស្រុកផ្ទាល់។

គម្រោងចំណូលសរុបរបស់ក្រុង ត្រូវរួមបញ្ចូលទាំងចំណូលរបស់សង្កាត់ទាំងអស់ចំណុះរដ្ឋបាលក្រុង ដែលបានវិភាជន៍និងផ្ទេរមកពីមូលនិធិឃុំ សង្កាត់នៅថ្នាក់ជាតិ និងចំណូលដែលរដ្ឋបាលសង្កាត់ប្រមូលបានដោយខ្លួនឯង។

ផ្អែកលើមូលដ្ឋានកញ្ចប់គម្រោងចំណូលថវិកាប្រចាំឆ្នាំដែលបានកំណត់រួច អភិបាលនៃគណៈអភិបាលក្រុង ត្រូវធ្វើការបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិការបស់សង្កាត់នីមួយៗ ដើម្បីរៀបចំគម្រោងថវិកាលម្អិតរបស់ខ្លួន។

ក-១-៣. ថ្នាក់រដ្ឋបាលខណ្ឌ និងសង្កាត់ចំណុះរាជធានី ត្រូវរៀបចំគម្រោងចំណូលដោយផ្អែកលើកញ្ចប់ថវិកាដែលបានបែងចែក និងជូនដំណឹងពីរដ្ឋបាលរាជធានី និងចំណូលដែលប្រមូលបានពីរដ្ឋបាលរបស់ខ្លួន។

ក-១-៤. ថ្នាក់រដ្ឋបាលសង្កាត់ចំណុះក្រុង ត្រូវរៀបចំគម្រោងចំណូលដោយផ្អែកលើកញ្ចប់ថវិកាដែលបានបែងចែក និងជូនដំណឹងពីរដ្ឋបាលក្រុង និងចំណូលដែលប្រមូលបានពីរដ្ឋបាលរបស់ខ្លួន (ចំណូលប្រមូលពីការផ្តល់សេវារដ្ឋបាលរបស់សង្កាត់)។

ក-១-៥. ថ្នាក់រដ្ឋបាលឃុំ ត្រូវរៀបចំគម្រោងចំណូលដោយផ្អែកលើតួលេខដែលបានវិភាជន៍ និងផ្ទេរពីថ្នាក់ជាតិនូវមូលនិធិឃុំ សង្កាត់ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានជូនដំណឹងតាមរយៈរដ្ឋបាលខេត្ត និងចំណូលដែលរដ្ឋបាលឃុំ សង្កាត់ប្រមូលបានពីរដ្ឋបាលរបស់ខ្លួន (ចំណូលប្រមូលពីការផ្តល់សេវារដ្ឋបាលរបស់ឃុំ)។

ក-២- គម្រោងចំណូលចរន្តសម្រាប់ចំណាយវិនិយោគ

ចំណូលចរន្តនៃថវិការបស់រដ្ឋបាលឃុំ សង្កាត់ អាចបានមកពីការផ្ទេរឥណទានពីថវិកាថ្នាក់ជាតិ និងចំណូលដែលមានប្រភពនៅនឹងមូលដ្ឋានផ្ទាល់ និងចំណូលបានមកពីប្រភពផ្សេងៗទៀត (ក្នុងជំពូក ៧៥ ចាប់ពីគណនី ៧៥១០ ដល់គណនី ៧៥១៨)។ ដូច្នេះ ពេលរៀបចំគម្រោងចំណូលចរន្តសម្រាប់ចំណាយវិនិយោគគ្រប់ថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលឱ្យអស់នូវជំនួយមនុស្សធម៌ និងជំនួយពីបរទេសដែលសប្បុរសជន អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនានា ដែលបានសន្យាផ្តល់ហិរញ្ញប្បទានផ្ទាល់ដល់ថវិការបស់រដ្ឋបាលនីមួយៗរួចហើយ។

ខ- អំពីគម្រោងចំណាយ

ចំណាយសរុបថវិការដ្ឋ សម្រាប់ឆ្នាំ២០១៨ ត្រូវបានគ្រោងស្មើនឹង ២៤,៦៨% នៃផ.ស.ស. គឺមានកំណើន ១,០៤ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៥,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។ ក្នុងនោះ **ចំណាយចរន្តថវិការដ្ឋ**នឹងកម្រិតត្រឹម ១៥,៦៨% នៃផ.ស.ស. គឺមានកំណើន ០,២៦ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ ដោយផ្តោតអាទិភាពជាពិសេសលើការបង្កើន**ចំណាយបៀវត្ស**សម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលនឹងធ្វើឱ្យចំណាយនេះឡើងដល់ ៥៣,៦៥% នៃចំណាយចរន្តសរុប ឬស្មើប្រមាណ ៨,៤២% នៃផ.ស.ស.។ **ចំណាយមូលធន** ត្រូវបានគ្រោងស្មើនឹង ៩,០% នៃផ.ស.ស. គឺមានកំណើន ០,៧៨ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ២១,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។ **ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស** ត្រូវបានគ្រោងក្នុងកម្រិត ៣,៦៦% នៃផ.ស.ស. គឺមានកំណើន ០,៩៨ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ៥១,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ និង**ចំណាយសម្រាប់ការទូទាត់ប្រាក់ខ្ចី** ត្រូវបានគ្រោងក្នុងកម្រិត ០,៧៤% នៃផ.ស.ស. គឺមានកំណើន ១០,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ

២០១៧។ ទន្ទឹមនេះ ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងក្នុងកម្រិត ៤,៥៩% នៃផ.ស.ស. គឺថយចុះ ០,២០ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ៦,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។ **ថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់** ត្រូវកំណត់ត្រឹម ១,៤៧% នៃផ.ស.ស. កើនឡើង ៤,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ ដែលក្នុងនោះថវិកាផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្តសរុបមានប្រមាណ ០,៧២% នៃផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រដ្ឋបាលរាជធានី ខេត្ត ស្មើនឹង ០,១៥% នៃផ.ស.ស. ឬស្មើនឹង ០.៩៦% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៧, ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រដ្ឋបាលក្រុង ស្រុក ស្មើនឹង ០,១៦% នៃផ.ស.ស. ឬស្មើនឹង ១,០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៧, និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់មូលនិធិឃុំ សង្កាត់ឆ្នាំ២០១៨ ស្មើនឹង ០,៤៤% នៃផ.ស.ស. ឬស្មើនឹង ២,៨០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៧។

ដើម្បីសម្រេចនូវក្របខ័ណ្ឌចំណាយថវិកាដូចខាងលើ ថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដំណើរការរៀបចំគម្រោងចំណាយថវិកា ដោយផ្អែកលើគោលការណ៍ដូចខាងក្រោម ÷

- ត្រូវស្ថិតក្នុងក្របខ័ណ្ឌដែលលទ្ធភាពសរុបចំណូលអាចធានារ៉ាប់រងបាន
- ត្រូវបានរៀបចំដោយវិចារណកម្មទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធ
- ត្រូវលម្អិតទៅតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាដែលមានការពាក់ព័ន្ធ និងទៅតាមលំដាប់លំដោយនៃអាទិភាពចំណាយ។

ខ-១- គម្រោងចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត

ខ-១-១. គម្រោងចំណាយរបស់រដ្ឋបាលរាជធានី ត្រូវបានរៀបចំលម្អិតតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋានសរុបចំណូលក្រោយពីបានដកចេញនូវកញ្ចប់ថវិកាខណ្ឌ និងកញ្ចប់ថវិកាសង្កាត់ចំណុះរាជធានីរួចហើយ នឹងត្រូវបានបូកបញ្ចូលជាមួយគម្រោងចំណាយរបស់រដ្ឋបាលខណ្ឌ និងសង្កាត់ក្រោយពេលដែលរដ្ឋបាលខណ្ឌ និងសង្កាត់បានផ្ញើជូននូវគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

ខ-១-២. គម្រោងចំណាយរបស់រដ្ឋបាលខេត្ត ត្រូវបានរៀបចំលម្អិតតាមជំពូក គណនី និងអនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើគម្រោងចំណូលសរុបដែលបានគណនារួច។

ខ-២.គម្រោងចំណាយរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ខ-២-១. គម្រោងចំណាយរបស់រដ្ឋបាលក្រុង ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានសរុបចំណូលក្រោយពីបានដកចេញនូវកញ្ចប់ថវិកាសង្កាត់ចំណុះក្រុងរួចហើយ នឹងត្រូវធ្វើការបូកបញ្ចូលជាមួយគម្រោងចំណាយរបស់រដ្ឋបាលសង្កាត់ក្រោយពេលដែលសង្កាត់ចំណុះក្រុង បានផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

ខ-២-២. គម្រោងចំណាយរបស់រដ្ឋបាលស្រុក ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្រប តាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានសរុបចំណូល ដែលបានគណនារួច។

ខ-២-៣. គម្រោងចំណាយរបស់រដ្ឋបាលខណ្ឌ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាដែលមានការពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋានកញ្ចប់ថវិកាដែលរដ្ឋបាលរាជធានីបានជូនដំណឹង។

ខ-៣. គម្រោងចំណាយរបស់រដ្ឋបាលឃុំ សង្កាត់

ខ-៣-១. គម្រោងចំណាយរបស់រដ្ឋបាលឃុំ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដោយផ្អែកលើមូលដ្ឋានសរុបចំណូលដែលបានគណនារួច។

ខ-៣-២. គម្រោងចំណាយរបស់រដ្ឋបាលសង្កាត់ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាដែលមានការពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋានកញ្ចប់ថវិកាដែលរដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងបានជូនដំណឹង។

គ. ការរៀបចំគម្រោងចំណាយ

ចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយតាមជំពូក គណនី អនុគណនី ដើម្បីបង្ហាញឱ្យឃើញថាការគិតគូរចំណាយរបស់ខ្លួន មានភាពត្រឹមត្រូវហ្មត់ចត់ និងសមហេតុផលហើយលិខិតយុត្តិការទាំងអស់នេះទុកសម្រាប់ធ្វើជាមូលដ្ឋាន លើការពិនិត្យនីត្យានុកូលភាពនៃគម្រោងថវិកា។

គ-១. ការរៀបចំគម្រោងចំណាយចរន្ត

គ-១-១. ប្រភេទ ១ : មធ្យោបាយ និងសេវា

គ-១-១-១. ជំពូក ៦៤ (បន្ទុកបុគ្គលិក)

ចំណាយបន្ទុកបុគ្គលិក (ជំពូក៦៤) ត្រូវបានចាត់ទុកជាចំណាយដែលមានអាទិភាពបំផុតក្នុងការរៀបចំគម្រោងថវិកា ដូច្នេះចំណាយសម្រាប់បន្ទុកបុគ្គលិក ថ្នាក់រដ្ឋបាលនីមួយៗ ត្រូវតែគិតគូរឱ្យបានច្បាស់លាស់ ទៅតាមគោលការណ៍តម្លើងបៀវត្សរបស់រាជរដ្ឋាភិបាល ព្រមទាំងធានាបាននូវសមធម៌ សង្គតិភាព និងប្រសិទ្ធភាព ជាពិសេសធានាបាននូវស្ថេរភាព និងចីរភាពថវិកា និងគម្លាតសមស្របរវាងអ្នកមានបៀវត្សខ្ពស់និងទាប។ ដូច្នេះ ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤) ត្រូវគ្រោងទៅតាមចំនួនមន្ត្រីរាជការ ដែលមានជាក់ស្តែងក្នុងឆ្នាំ២០១៧ ដោយផ្អែកតាមតារាងប្រព័ន្ធប្រាក់បៀវត្សរបស់ក្រសួងមុខងារសាធារណៈ។ គោលការណ៍សម្រាប់ការគ្រោងបន្ទុកបុគ្គលិកឆ្នាំ២០១៨ រួមមាន÷

\+ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងបង្កើនចំណាយបៀវត្សមូលដ្ឋានតាមតម្លៃឯកតាសន្ទស្សន៍ ២ ១៣០ រៀល គឺមានកំណើនស្មើនឹង ១២% ក្នុងមួយឆ្នាំ គិតចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៨ ដោយផ្អែកលើតារាងទូទាត់បៀវត្សប្រចាំខែថ្មីបំផុត (តារាងព័ត៌មានវិទ្យា) ដែលចេញដោយក្រសួងមុខងារសាធារណៈ។

+ ប្រាក់បំណាច់មុខងារ ត្រូវគ្រោងតម្លើងគិតពីខែមេសា ដល់ ខែធ្នូ (ប្រាំបួនខែ) ឆ្នាំ២០១៨ ដោយត្រូវផ្តល់បន្ថែមតាមគោលការណ៍ដូចខាងក្រោម៖

- ផ្តល់បន្ថែម ១០០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារកម្រិតចាប់ពី ៣៥០ ០០០ រៀល ដល់កម្រិតក្រោម ៥០០ ០០០ រៀល
- ផ្តល់បន្ថែម ៤០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារចាប់ពី ៥០០ ០០០ រៀល ឡើង

+ ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវគ្រោងទៅតាមគោលការណ៍របស់រាជរដ្ឋាភិបាល គិតចាប់ពីខែមេសា ដល់ ខែធ្នូ (ប្រាំបួនខែ) ឆ្នាំ២០១៨ ក្នុងនោះ៖

- ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវគ្រោងឱ្យម្នាក់ចំនួន ១ ៣៦០ ០០០ រៀល ក្នុងមួយខែ
- សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវគ្រោងឱ្យម្នាក់ចំនួន ១ ០៨៥ ០០០ រៀលក្នុងមួយខែ
- ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងឱ្យម្នាក់ចំនួន ១ ០៧៥ ០០០ រៀលក្នុងមួយខែ
- សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងឱ្យម្នាក់ចំនួន ៨៦០ ០០០ រៀលក្នុងមួយខែ
- មេឃុំ ចៅសង្កាត់ ត្រូវគ្រោងឱ្យម្នាក់ចំនួន ១ ០៣០ ០០០ រៀលក្នុងមួយខែ
- ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២ ត្រូវគ្រោងឱ្យម្នាក់ចំនួន ៨០០ ០០០ រៀលក្នុងមួយខែ
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវគ្រោងឱ្យម្នាក់ចំនួន ៧០០ ០០០ រៀលក្នុងមួយខែ
- មេភូមិ ត្រូវគ្រោងឱ្យម្នាក់ចំនួន ២៥០ ០០០ រៀលក្នុងមួយខែ
- អនុប្រធានភូមិ ត្រូវគ្រោងឱ្យម្នាក់ចំនួន ២០០ ០០០ រៀល ក្នុងមួយខែ
- សមាជិកភូមិ ត្រូវគ្រោងឱ្យម្នាក់ចំនួន ១៨០ ០០០ រៀល ក្នុងមួយខែ

+ ថ្នាក់រដ្ឋបាលដែលបានបង្កើតការិយាល័យច្រកចេញ ចូលតែមួយ ត្រូវគ្រោងប្រាក់ឧបត្ថម្ភជូនប្រធាន និងអនុប្រធានការិយាល័យប្រជាពលរដ្ឋ នៅក្នុងអនុគណនី៦៤០៧៨ (ប្រាក់បំណាច់ផ្សេងៗទៀត) ស្របតាមលិខិតលេខ ៨២៨ លស ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ ស្តីពីសំណើសុំកំណត់ប្រាក់ឧបត្ថម្ភសម្រាប់ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវកំណត់ដូចខាងក្រោម៖

- ប្រធានការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត មានប្រាក់ឧបត្ថម្ភប្រចាំខែស្មើនឹងប្រធានក្រុមប្រឹក្សារាជធានី ខេត្ត
- អនុប្រធានការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត មានប្រាក់ឧបត្ថម្ភប្រចាំខែស្មើនឹងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត
- ប្រធានការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានប្រាក់ឧបត្ថម្ភប្រចាំខែស្មើនឹងប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

+ ចំពោះមន្ត្រីរាជការដែលត្រូវជ្រើសរើសបន្ថែមថ្មី ត្រូវគ្រោងយ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាព។ មន្ត្រីដែលត្រូវបានកាត់ឈ្មោះចេញពីអង្គភាពរបស់ខ្លួន និងមិនអនុញ្ញាតឱ្យគ្រោងទេ។ ចំពោះការឡើងឋានៈ និងកាំប្រាក់ត្រូវគ្រោងដោយឡែក និងដោយផ្អែកលើលិខិតយុត្តិការផ្លូវការរបស់រាជរដ្ឋាភិបាល។

+ ចំនួនមន្ត្រីជាប់កិច្ចសន្យា ត្រូវគ្រោងមិនឱ្យលើសចំនួនដែលក្រសួងមុខងារសាធារណៈផ្តល់ជូន និងត្រូវប្រើប្រាស់ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់ស្របតាមគោលការណ៍ ដែលមានចែងនៅក្នុងអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា។ ក្នុងករណីដែលរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតម្រូវការមន្ត្រីជាប់កិច្ចសន្យាត្រូវគ្រោងនៅក្នុងអនុគណនី៦៤០៤១ (បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា)។ សម្រាប់ឆ្នាំ២០១៨ មន្ត្រីជាប់កិច្ចសន្យាត្រូវគ្រោងឱ្យក្នុងម្នាក់ចំនួន ៦០០ ០០០ រៀលក្នុងមួយខែ។

+ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំចំនួនមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យាដែលកំពុងបំពេញការងារនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗដែលរួមទាំងមន្ត្រីស្មៀនឃុំ សង្កាត់ផងនោះតាមគំរូតារាងដែលមានខ្លឹមសារដូចនឹងតារាងប្រព័ន្ធប្រាក់បៀវត្សរបស់ក្រសួងមុខងារសាធារណៈឆ្នាំមុន ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ចុះហត្ថលេខាបោះត្រាបញ្ជាក់។

+ ចំពោះប្រាក់បៀវត្សមូលដ្ឋានរបស់អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរាជការត្រូវគ្រោងនៅក្នុងអនុគណនី ៦៤០២១ (បៀវត្សមូលដ្ឋាន)។

+ ចំពោះប្រាក់បំណាច់មុខងារមន្ត្រីរាជការ ត្រូវគ្រោងក្នុងអនុគណនី ៦៤០២២ (ប្រាក់បំណាច់មុខងារ)។

+ ចំពោះប្រាក់បំណាច់មុខងារអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងនៅក្នុងអនុគណនី ៦៤០៧១ (ប្រាក់បំណាច់អភិបាល) ប្រាក់បំណាច់មុខងារអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងនៅក្នុងអនុគណនី ៦៤០៧២ (ប្រាក់បំណាច់អភិបាលរង)

+ ចំពោះគម្រោងប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រោងក្នុងអនុគណនី ៦៤០៧៣ (ប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សា និងមេឃុំ ចៅសង្កាត់) និងប្រាក់ឧបត្ថម្ភមន្ត្រីភូមិត្រូវគ្រោងនៅក្នុងអនុគណនី៦៤០៧៤ (ប្រាក់ឧបត្ថម្ភមន្ត្រីភូមិ)។

+ ចំពោះប្រាក់រង្វាន់លើកទឹកចិត្តរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងសម្រាប់ពង្រឹងយន្តការប្រមូលចំណូលលើការផ្តល់សេវារដ្ឋបាល ត្រូវគ្រោងក្នុងអនុគណនី៦៤០៣៣ (រង្វាន់) តាមសមាមាត្រនៃប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមឱវាទរបស់ថ្នាក់រដ្ឋបាលនីមួយៗត្រូវបូកសរុបនៅក្នុងតារាងទី១ និងចំនួនបុគ្គលិកអចិន្ត្រៃយ៍ប្រភេទ " ក", " ខ", " គ" ក្រុមប្រឹក្សា បុគ្គលិកអណ្តែត មន្ត្រីជាប់កិច្ចសន្យា ប្រធាន

ការិយាល័យច្រកចេញ ចូលតែមួយ ត្រូវបូកសរុបនៅក្នុងតារាងទី១ “ ក ” ដែលបានភ្ជាប់ជូនមកជាមួយនេះ។ សលាកប័ត្រនេះ មានចែកជាច្រើនខ្ទង់សម្រាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលថ្នាក់រដ្ឋបាលនីមួយៗមាន។

បុគ្គលិក មន្ត្រីរាជការដែលលម្អិតទៅតាមអង្គភាពនីមួយៗ ហើយចំនួននេះត្រូវតែផ្ទៀងផ្ទាត់ជាមួយនឹងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ (តាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ)។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវលម្អិតចំនួនបុគ្គលិកទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗដែលស្ថិតនៅក្រោមនិរាទរបស់ខ្លួន។

គ-១-១-២.ជំពូក ៦០ និង ៦១ (ការទិញ និងសេវាកម្ម)

ប្រមូលផ្តុំរាល់ការចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគ្រោងនៅក្នុងតារាងទី២ និងតារាងទី៣។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ ÷

- មួយផ្នែកជាឥណទានសម្រាប់បម្រើឲ្យកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរឲ្យបានហ្មត់ចត់ និងត្បិតត្បៀតសន្សំសំចៃ ដោយផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈ។ ក្នុងឆ្នាំ២០១៨ ឥណទានចំណាយផ្នែកនេះ គឺអនុញ្ញាតឲ្យគ្រោងក្នុងកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០១៧ តែប៉ុណ្ណោះ។ ដោយផ្អែកលើបរិមាណធាតុចូល និងតំលៃជាក់ស្តែងនៅលើទីផ្សារ ហើយជៀសវាងបង្កើនបរិមាណត្រូវកាត់បន្ថយការទិញឧបករណ៍ទំនើប និងគ្រឿងសង្ហារឹមប្រណិត។

ដោយឡែកថ្លៃឈ្នួល និងបន្ទុក (អនុគណនី ៦១០៣១) គឺអនុញ្ញាតឲ្យគ្រោងតែចំណាយសម្រាប់ជួលស្នាក់ការរដ្ឋបាលតែប៉ុណ្ណោះ។

- មួយផ្នែកទៀតជាឥណទានសម្រាប់បម្រើដល់គុណប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំមូលដ្ឋានសម្ភារៈនៃសេវាសាធារណៈ និងការអភិវឌ្ឍ។ ផ្អែកលើផែនការយុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍថ្នាក់រដ្ឋបាលនីមួយៗ ចាំបាច់ត្រូវរៀបចំទៅតាមលំដាប់លំដោយអាទិភាព របស់គម្រោងចំណាយអំពីការងារគុណប្រយោជន៍របស់ខ្លួន។

ទន្ទឹមនោះ គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវយកចិត្តទុកដាក់បង្កើននូវចំណាយអភិវឌ្ឍន៍ ក្នុងករណីដែលលទ្ធភាពចំណូលសម្រេចបានលើសផែនការ ព្រោះការអភិវឌ្ឍនៅមូលដ្ឋានជួយជំរុញកំណើនសេដ្ឋកិច្ច ដែលឈានទៅរកការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដូចដែលបានឆ្លុះបញ្ចាំងក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវគ្រោងឥណទានសម្រាប់ចំណាយជាគុណប្រយោជន៍រាជធានី ខេត្ត ក្រុង ស្រុកតាមការងារនីមួយៗ និងតាមការដ្ឋាននីមួយៗ (ផ្លូវថ្នល់ ស្ពាន សួនច្បារ លូទឹក ប្រឡាយ......) ដោយមានបញ្ជាក់អំពីបញ្ជីប៉ាន់តម្លៃ និងទីតាំងច្បាស់លាស់ដែលជាឯកសារសម្រាប់ការពិភាក្សាថវិកាប្រចាំឆ្នាំ។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សង្កាត់ ត្រូវគ្រោងលម្អិតជំពូក៦១ សេវាកម្មផ្សេងៗទៀតនៅក្នុងតារាងទី៣ ដូចជាចំណាយទទួលភ្ញៀវ បេសកកម្ម ទូរស័ព្ទ ពិធីបុណ្យផ្សេងៗ......។

ជាទូទៅ ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគ្រោងទៅតាមតម្រូវការ នៃសកម្មភាពឬទៅតាមបទដ្ឋានសមស្រប។ ម្យ៉ាងទៀតរាជធានី ខេត្ត ក្រុង ស្រុក មិនត្រូវគ្រោងបំប៉ោងឥណទានដែលស្នើសុំសម្រាប់ចំណាយប្រភេទនេះទេ។ ឥណទានសម្រាប់ចំណាយរដ្ឋបាលអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ និងការទទួលភ្ញៀវត្រូវគិតគូរក្នុងកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០១៧ នឹងត្រូវគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសម្រាប់ចំណាយអគ្គិសនី ទឹក សម្រាប់គុណប្រយោជន៍របស់រាជធានី ខេត្ត ក្រុង ស្រុក ត្រូវគ្រោងឲ្យបានគ្រប់គ្រាន់សម្រាប់តម្រូវការក្នុងឆ្នាំ និងការសងបំណុល។ ក្នុងករណីដែលរាជធានី ខេត្ត ក្រុង ស្រុក គ្រោងមិនបានគ្រប់គ្រាន់ ក្រសួងសេដ្ឋកិច្ច និងហិញ្ញវត្ថុ នឹងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូកថវិការបស់រាជធានី ខេត្ត ក្រុង ស្រុក ហើយដាក់កម្មវិធីចំណាយសម្រាប់ទូទាត់ជូនរាជធានី ខេត្ត ក្រុង ស្រុកដោយស្វ័យប្រវត្តិ។ ចំពោះគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក រៀបចំមិនត្រឹមត្រូវតាមគោលការណ៍ណែនាំខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើការកែតម្រូវថវិការបស់រដ្ឋបាលក្រុង ស្រុក ឡើងវិញឲ្យសមស្របតាមសារាចរណែនាំនេះ។

គ-១-២. ប្រភេទ ៣ : ចំណាយអន្តរាគមន៍សាធារណៈ

គ-១-២-១. ជំពូក ៦២ និងជំពូក ៦៥ : អត្ថប្រយោជន៍សង្គម និងឧបត្ថម្ភកធន

ចំណាយប្រភេទនេះ ត្រូវរៀបចំលម្អិតឲ្យច្បាស់លាស់តាមគោលដៅដែលត្រូវសម្រេច ដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផល និងចំនួនទឹកប្រាក់ដែលត្រូវពិនិត្យផ្តល់ជូន (គម្រោងចំណាយនេះត្រូវសរុបតារាងទី៤និង៥) ដូចជាឧបត្ថម្ភអត្ថប្រយោជន៍សន្តិសុខសង្គម ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម វប្បធម៌ និងឧបត្ថម្ភកធនជូនថ្នាក់រដ្ឋបាលនីមួយៗ។ រដ្ឋបាលខេត្តនីមួយៗ ត្រូវគ្រោងចំណាយសម្រាប់ឧបត្ថម្ភកធនជូនដល់រដ្ឋបាលក្រុងនៃដែនសមត្ថកិច្ចរបស់ខ្លួន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ អនុលោមតាមប្រកាសអន្តរក្រសួងលេខ០៧៣ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការប្រើប្រាស់កញ្ចប់សេវាអនាម័យបរិស្ថានសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ តាមទីប្រជុំជនក្រុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងអនុគណនី ៦៥០១២ (ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌ)។

ចំពោះគណៈបញ្ជាការឯកភាពត្រូវគ្រោងក្នុងអនុគណនី៦២៩៨១(អត្ថប្រយោជន៍សង្គមផ្សេងទៀត)។

ចំណាយឧបត្ថម្ភសមាជិកភាពជូនសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ចំនួន ២ភាគរយ (ពីរភាគរយ) នៃថវិកាផ្នែករដ្ឋបាល (ថវិការដ្ឋបាលដែលរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ទទួលបានពីវិភាជន៍សមាសភាគរដ្ឋបាលនៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ប្រចាំឆ្នាំ) ដោយដកបន្ទុកបុគ្គលិក (ជំពូក ៦៤) ហើយត្រូវគ្រោងក្នុងអនុគណនី៦២០៤១ (ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ)។

គ-១-៣. ប្រភេទ៤ : ចំណាយផ្សេងៗ

គ-១-៣-១. ជំពូក ៦៣ : (ពន្ធ និងអាករ)

ចំណាយប្រភេទនេះ គឺសម្រាប់កាតព្វកិច្ចពន្ធដូចជាចំណាយលើអាករ (លតាប័ត្រលើរថយន្ត ម៉ូតូរបស់រដ្ឋ.....) ពន្ធប្រថាប់ត្រាសម្រាប់ទទួលកម្មសិទ្ធិ និងចំណាយបង់ពន្ធអាករផ្សេងៗទៀតតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន (គម្រោងចំណាយនេះត្រូវសរុបតារាងទី៦)។

គ-១-៤.ប្រភេទ ៦ : ចំណាយមិនបានគ្រោងទុក

គ-១-៤-១.ជំពូក ៦៩ : (ចំណាយមិនបានគ្រោងទុក)

ចំណាយប្រភេទនេះ ត្រូវគ្រោងបម្រុងសម្រាប់ចំណាយចៃដន្យដែលអាចកើតមានជាយថាហេតុនៅក្នុងឆ្នាំអនុវត្ត។ សម្រាប់ឆ្នាំថវិកា២០១៨ ប្រភេទឥណទាននេះ គឺអនុញ្ញាតឲ្យគ្រោង ៥% នៃគម្រោងចំណាយសរុបរបស់ រដ្ឋបាលនីមួយៗ ហើយខ្ទង់ចំណាយនេះ ពេលអនុវត្តត្រូវស្នើសុំនិយ័តភាពទៅបំពេញឲ្យជំពូកដទៃទៀត ដែលតម្រូវការចំណាយចៃដន្យកើតមានឡើងជាយថាហេតុ តម្រូវការចំណាយសម្រាប់អភិវឌ្ឍ ចំណាយសងបំណុលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជាពិសេសនៅពេលដែលរាជរដ្ឋាភិបាលមានគោលការណ៍ តម្លើងប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំ និងបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិ ប្រកបដោយសមធម៌ សង្គតិភាព ប្រសិទ្ធភាព។

គ-២.ការរៀបចំគម្រោងចំណាយមូលធន:

គ-២-១.ប្រភេទ ២ : អចលកម្ម

គ-២-១-១.ជំពូក ២០ និងជំពូក ២១ : (អចលកម្មអរូបី និងអចលកម្មរូបី)

គម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អាចគ្រោងបានក្នុងករណីដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលគោលការណ៍អនុញ្ញាតជាផ្លូវការ ឲ្យគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់។

ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស ដោយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អាចគ្រោងបានក្នុងករណីដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានអតិរេកចរន្ត (គម្រោងចំណាយនេះត្រូវសរុបក្នុងតារាងទី៧)។

ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ត្រូវផ្អែកលើកម្មវិធីជំនួយឬគម្រោង ដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ឬម្ចាស់ជំនួយទ្វេភាគីមានបំណងផ្តល់ត្រង់ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកត់ត្រាចូលទៅក្នុងគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនេះ រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវយកចិត្តទុកដាក់ផងដែរ ក្នុងការកត់ត្រារាល់ចំណាយថវិកាបដិភាគជាប្រាក់រៀល ដែលត្រូវអនុវត្តជាមួយគម្រោងដោយហិរញ្ញប្បទានពីបរទេសផ្ទាល់។

គម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំគឺ ត្រូវផ្អែកលើកម្មវិធីវិនិយោគដែលបានធ្វើបច្ចុប្បន្នភាព នឹងត្រូវបានក្រុមប្រឹក្សាពិនិត្យអនុម័តចុងក្រោយគេបំផុត។

ឃ.វិធីសាស្ត្រក្នុងការរៀបចំគម្រោងចំណូល ចំណាយថវិកា

គម្រោងចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ហើយត្រូវបានពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលនីមួយៗ។

ឃ-១.ការរៀបចំគម្រោងចំណូល

- ដើម្បីគ្រប់គ្រង ចាត់ចែង និង អនុវត្តមុខងារជាកាតព្វកិច្ចមួយ ឬ ច្រើនដែលត្រូវបានផ្ទេរឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ ឬ
- ដើម្បីបន្តគ្រប់គ្រង ឬ ចាត់ចែង និងអនុវត្តមុខងារជាជម្រើសមួយ ឬ ច្រើនដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលធ្លាប់បានអនុវត្ត ឬ
- សំរាប់គោលបំណងជាកាតព្វកិច្ចមួយឬច្រើនដែលបានកំណត់ ។

ទម្រង់បែបបទ វិធាន និង លក្ខខណ្ឌនៃការផ្ទេរមូលនិធិមានភ្ជាប់លក្ខខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៣០.-

មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ជាមូលនិធិដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រើប្រាស់ដើម្បី :

- បំពេញភារកិច្ចតាមផ្លូវច្បាប់
- បំពេញមុខងារភារកិច្ចក្នុងការបង្កើត ការជំរុញ និង ការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- ជ្រើសរើស គ្រប់គ្រង ចាត់ចែង និង អនុវត្តមុខងារជាជម្រើសនានា ។

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលពីថវិកាជាតិប្រចាំឆ្នាំ នូវមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យ និងរូបមន្តប្រកបដោយតម្លាភាព ។

ទម្រង់បែបបទ វិធាន និង លក្ខខណ្ឌនៃការផ្ទេរមូលនិធិគ្មានភ្ជាប់លក្ខខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៣១.-

ត្រូវបង្កើតឲ្យមានមូលនិធិក្រុង ស្រុក ដែលមានគណនីដោយឡែកនៅរតនាគារជាតិ ដើម្បីទទួលមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌពីថវិកាជាតិ និង ទទួលធនធានពីប្រភពផ្សេងៗទៀតសម្រាប់ជា

ប្រយោជន៍ដល់ថវិកាថ្នាក់រដ្ឋបាលក្រុង និង ស្រុក ។

មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌដែលត្រូវផ្ទេរពីថវិកាជាតិទៅមូលនិធិក្រុង ស្រុក ត្រូវធ្វើឡើងជាដំណាក់កាលៗក្នុងឆ្នាំនីមួយៗ តាមរូបមន្ត ឬ អត្រាជាក់លាក់ និង អាចប៉ាន់ប្រមាណបានសម្រាប់រយៈពេលមធ្យម។

ការវិភាជន៍ធនធានពីមូលនិធិក្រុង ស្រុកជូនទៅ រដ្ឋបាលថ្នាក់ក្រុង ស្រុកនីមួយៗ ត្រូវធ្វើឡើងប្រចាំឆ្នាំដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យ និង រូបមន្តប្រកបដោយតម្លាភាព ។

ការបង្កើត និង វិធានអនុវត្តរបស់មូលនិធិក្រុង ស្រុក ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៣២.-

រដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបាននូវចំណូលអំពីការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ។

មាត្រា ៣៣.-

រដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបាននូវមុខងារជាភ្នាក់ងារក្នុងនាមរាជរដ្ឋាភិបាល ឬ ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ដោយផ្អែកទៅតាមច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

រដ្ឋបាលថ្នាក់ក្រោមជាតិអាចពិភាក្សាឯកភាពគ្នាជាមួយក្រសួងស្ថាប័ន ឬ មន្ទីរ អង្គភាពនានារបស់រដ្ឋបាលថ្នាក់ជាតិ ដើម្បីទទួលអនុវត្តនូវកិច្ចការអ្វីមួយតាមរយៈកិច្ចសន្យា ឬ កិច្ចព្រមព្រៀងដែលក្នុងនោះបានកំណត់ច្បាស់អំពីកិច្ចការដែលត្រូវធ្វើ ពេលវេលាដែលត្រូវអនុវត្ត លទ្ធផលដែលត្រូវសម្រេច និង ប្រាក់កម្រៃដែលភ្នាក់ងារអនុវត្តត្រូវបានទទួល ។

ទម្រង់បែបបទ និង វិធាននៃការប្រើប្រាស់ថវិកាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារខាងលើនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ផ្នែកទី ៣
ការរៀបចំ និង ការអនុម័តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

មាត្រា ៣៤.-

ផែនការយុទ្ធសាស្ត្រថវិកា និង គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំដោយអភិបាលនៃគណៈអភិបាល និង អនុម័តដោយក្រុមប្រឹក្សា ទៅតាមនីតិវិធីដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ គឺជាកញ្ចប់ថវិកាមួយដែលត្រូវបញ្ជូនមកពិនិត្យអនុម័តដោយរដ្ឋសភា និង ព្រឹទ្ធសភា ក្នុងក្របខ័ណ្ឌនៃការពិនិត្យ និង អនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។ ក្រោយពីច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានពិនិត្យ និង អនុម័តពីរដ្ឋសភា និងព្រឹទ្ធសភារួចហើយ កញ្ចប់ថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបែងចែកទៅតាមក្រុមប្រឹក្សានីមួយៗ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៣៥.–

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំទៅតាមប្រតិទិនដូចខាងក្រោម ៖

១- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែមីនា ដល់ខែឧសភា)

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវចេញសេចក្តីណែនាំស្តីពីការរៀបចំយុទ្ធសាស្ត្រថវិកាដល់គ្រប់ក្រសួងស្ថាប័ន អង្គភាពទាំងអស់ដើម្បីជូនដំណឹងដល់ក្រុមប្រឹក្សានីមួយៗនូវកម្មវិធី និងគម្រោងថវិកាក្នុងវិស័យរបស់ខ្លួន ដែលត្រូវអនុវត្តនៅដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។ ក្នុងនាមក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ដោយឈរលើមូលដ្ឋានផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ រួចហើយដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ ពិភាក្សា និងអនុម័តហើយត្រូវផ្ញើជូនទៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបូកសរុបផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ ឧសភា ។

២- ការរៀបចំកញ្ចប់ថវិកា (ពីខែមិថុនា ដល់ខែកញ្ញា)

នៅសប្តាហ៍ទី ១ នៃ ខែ មិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ពីទម្រង់បែបបទនីតិវិធីនៃការរៀបចំគម្រោងថវិកា និង ឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់ជាមួយ ហើយផ្ញើទៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរៀបចំគម្រោងចំណូល ចំណាយថវិកាលំអិតរបស់ខ្លួន ។ អភិបាលនៃគណៈអភិបាលនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគម្រោងចំណូល ចំណាយថវិកាលំអិតរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និង អាទិភាពគោលនយោបាយនៃរដ្ឋបាលរបស់ខ្លួន ដោយដាក់បញ្ចូលនូវរាល់ប្រភពថវិកាទាំងអស់ដែលត្រូវអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងដោយអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដោយមានជំនួយពីប្រធានហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា និង មន្ត្រីនៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនីមួយៗក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវគម្រោងថវិកានេះដើម្បីប្រមូលយោបល់ចូលរួមរបស់ប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួចហើយត្រូវ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ពិនិត្យ និង រៀបចំឡើងវិញនូវគម្រោងថវិកានេះ ដើម្បីដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិភាក្សា និងអនុម័តក្នុងកិច្ចប្រជុំជាសាធារណៈយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣០ ខែ មិថុនា ។

ចំពោះការរៀបចំគម្រោងថវិកាថ្នាក់ក្រុង ស្រុក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចធ្វើប្រតិភូកម្មឲ្យអភិបាលនៃគណៈអភិបាលខេត្តទទួលខុសត្រូវ ក្នុងការជួយគាំទ្របច្ចេកទេសដោយមានគម្រោងថវិការបស់ខ្លួនបានត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ បទបញ្ញា បែបបទ និងនីតិវិធីនានា ដែលកំណត់ដោយថ្នាក់ជាតិ ។ អភិបាលនៃគណៈអភិបាលខេត្ត ត្រូវធ្វើសេចក្ដីរាយការណ៍ក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការគាំទ្របច្ចេកទេសនេះ ។

អភិបាលនៃគណៈអភិបាលខេត្ត ត្រូវធានាថាមន្ត្រីនៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការបូកសរុបគម្រោងថវិការបស់ខេត្ត គម្រោងថវិការបស់ក្រុង គម្រោងថវិការបស់ស្រុកក្នុងខេត្តរបស់ខ្លួនចូលក្នុងទម្រង់ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយភ្ជាប់ជាមួយនូវគម្រោងថវិកា និងសេចក្ដីអត្ថាធិប្បាយពន្យល់របស់ខេត្ត របស់ក្រុង របស់ស្រុក ហើយត្រូវផ្ញើគម្រោង និងឯកសារទាំងនេះមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើការប្រមូលផ្ដុំបូកសរុបនូវគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំនីមួយៗ ។

ក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើការពិនិត្យនីត្យានុកូលភាព និង បញ្ជាក់អនុលោមភាពលើថវិការបស់រាជធានី ថវិការបស់ខេត្ត ថវិការបស់ក្រុង និងថវិការបស់ស្រុក ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចធ្វើប្រតិភូកម្មនូវការពិនិត្យនីត្យានុកូលភាពទៅដល់អង្គភាពជំនាញរបស់ខ្លួន ឬ អាជ្ញាធរណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមការចាំបាច់ ។

ដំណើរការពិនិត្យនីត្យានុកូលភាព ត្រូវមានការចូលរួមពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង និង ស្រុកដែលតំណាងឲ្យក្រុមប្រឹក្សាជាម្ចាស់ថវិកា តំណាងក្រសួងមហាផ្ទៃ និង សមាសភាពដទៃទៀតដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ក្នុងដំណើរការពិនិត្យនីត្យានុកូលភាពនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អាជ្ញាធរដែលបានទទួលអំណាចប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់លើគោលការណ៍នៃការពិនិត្យនីត្យានុកូលភាព ដូចខាងក្រោម :

- គម្រោងថវិកាបានរៀបចំឡើងទៅតាមទម្រង់ចំណាត់ថ្នាក់ថវិកាបែបបទ និង នីតិវិធីដែលបានកំណត់
- មានការចូលរួមពីប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំថវិកា
- ការគ្រោងឥណទានទៅតាមគោលការណ៍ចំណាយចាំបាច់
- គម្រោងថវិកាត្រូវគ្រោងតាមលក្ខខណ្ឌដែលភ្ជាប់ទៅនឹងការប្រើប្រាស់ធនធានពីប្រភពជាក់លាក់ដែលបានកំណត់ទុកជាមុន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

Kol

- ធានាឲ្យមានតុល្យភាពពិតប្រាកដរវាងចំណូល និង ចំណាយថវិកា

- មានការពិភាក្សាអនុម័តគម្រោងថវិកាក្នុងកិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា ។

ក្នុងករណីដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អាជ្ញាធរដែលបានទទួលអំណាចប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យឃើញថាគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិណាមួយមិនស្របទៅនឹងគោលការណ៍ពិនិត្យនីត្យានុកូលភាពដូចបានចែងខាងលើ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អាជ្ញាធរដែលបានទទួលប្រតិភូកម្មអំណាចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវសម្រេចកែសម្រួល និង ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំកែសម្រួលឡើងវិញទៅតាមនីតិវិធីជាធរមាន ។

៣- ការអនុម័តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (ពីខែតុលា ដល់ខែធ្នូ)

នៅសប្តាហ៍ទី ១ នៃ ខែ តុលា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបញ្ជូនគម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ សម្រេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទី ១ នៃ ខែ វិច្ឆិកា ដើម្បីពិនិត្យអនុម័តនិងដាក់ជូនព្រឹទ្ធសភានៅសប្តាហ៍ទី ១ នៃ ខែ ធ្នូ ដើម្បីសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែ ធ្នូ ។

មាត្រា ៣៦.-

ប្រសិនបើគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រូវបានអនុម័តមុនថ្ងៃទី ០១ ខែ មករា នៃឆ្នាំសំរាប់ការិយបរិច្ឆេទដែលត្រូវអនុវត្តទេនោះ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិប្រមូលចំណូលតាមលក្ខខណ្ឌដែលបានអនុម័តដូចឆ្នាំមុន និង ធានាចំណាយប្រចាំខែ ក្នុងកម្រិត ១/១២ នៃថវិកាឆ្នាំមុន ។

ផ្នែកទី ៤
ការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

មាត្រា ៣៧.-

ដើម្បីបម្រើឲ្យប្រតិបត្តិការចំណូល ចំណាយថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបើកគណនីប្រាក់បញ្ញើនៅរតនាគារថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ។

មាត្រា ៣៨.-

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិអាចត្រូវបានកែតម្រូវក្នុងអំឡុងឆ្នាំថវិកា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលជះឥទ្ធិពលទៅលើការព្យាករណ៍ដំបូងនៃ

ចំណូល និង ចំណាយ ។ ការកែតម្រូវថវិកាត្រូវរៀបចំពិនិត្យ អនុម័ត និង បញ្ជាក់ទទួលស្គាល់តាមនីតិវិធី ដូចមានចែងនៅក្នុង មាត្រា ៣៥ នៃច្បាប់នេះ ។

មាត្រា ៣៩.-

ចលនាឥណទានផ្ទៃក្នុងនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងក្នុងលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើនិយ័តកម្មឥណទានរបស់ខ្លួន ដើម្បីដោះស្រាយតម្រូវការក្នុងករណីចាំបាច់បន្ទាន់ ។

មាត្រា ៤០.-

ប្រភេទឥណទានថវិកានៃប្រភេទចំណាយមិនបានគ្រោងទុក អាចត្រូវបានប្រើប្រាស់សម្រាប់ធានាចំពោះចំណាយទាំងឡាយណាដែលការវិភាជន៍មិនបានកំណត់ជាក់លាក់ នៅពេលឥណទានត្រូវបានអនុម័ត ឬ សម្រាប់ឥណទានបំពេញបន្ថែមជាគុណប្រយោជន៍ដល់ប្រភេទចំណាយផ្សេងៗទៀតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

អភិបាលត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ពេលមានតម្រូវការប្រើប្រាស់ឥណទានចំណាយថវិកាមិនបានគ្រោងទុក ។

មាត្រា ៤១.-

គម្រោង ឬ កម្មវិធីដែលអនុវត្តមិនទាន់ចប់នៅក្នុងឆ្នាំថវិកា ត្រូវបានដាក់បញ្ចូលដើម្បីបន្តអនុវត្តដោយលើកគម្រោងចំណាយទៅក្នុងថវិកានៃឆ្នាំបន្ទាប់ ។

មាត្រា ៤២.-

ក្នុងករណីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឲ្យលេចចេញនូវឱនភាព រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវម្ចាស់ការដាក់ចេញនូវវិធានការគ្រប់បែបយ៉ាង ដើម្បីធានាតុល្យភាពថវិកាឡើងវិញ ។ នៅក្នុងឆ្នាំថវិកា ប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បានកើនលើសពីគម្រោងចំណូលប្រចាំឆ្នាំដែលបានគ្រោងទុក ឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ឬ ធ្វើនិយ័តកម្មទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិនានា ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទៅតាមកម្រិតចំណូលលើសដែលបានបញ្ជិកា ។ នៅដំណាច់ឆ្នាំ ថវិកាអតិរេកថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកត់ត្រាចូលគណនីលទ្ធផលនៃរតនាគារជាតិ ។

មាត្រា ៤៣.-

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាកម្មវត្ថុសំរាប់ធ្វើអធិការកិច្ច និង សវនកម្មរបស់ស្ថាប័នមានសមត្ថកិច្ច ។ គោលបំណងនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ និង សវនកម្ម គឺសំដៅធានានូវតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព នៃប្រកពព័ត៌មានហិរញ្ញវត្ថុ និង ការវាយតម្លៃនៃការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

របាយការណ៍អធិការកិច្ចហិរញ្ញវត្ថុ និង សវនកម្ម ដែលរួមមានបញ្ចូលនូវមតិយោបល់របស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ៤៤.-

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និង គណនេយ្យ ត្រូវប្រតិបត្តិតាមវិធានទាំងឡាយស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ ការគ្រប់គ្រងលទ្ធកម្មសាធារណៈ និង បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ដែលត្រូវកំណត់ដោយច្បាប់ និង លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

មាត្រា ៤៥.-

ការទូទាត់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ជាជំពូកមួយនៃច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋ ។ គោរពតាមគោលការណ៍គណនេយ្យឯកភាព អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចរៀបចំ និង ផ្តល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនូវរបាយការណ៍ស្តីពីការអនុវត្តថវិកា និង ព័ត៌មានចាំបាច់ផ្សេងៗទៀតនៅពេលដំណាច់ឆ្នាំថវិកានីមួយៗ ។

មាត្រា ៤៦.-

នៅដំណាច់ឆ្នាំថវិកា អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវធ្វើការផ្ទៀងផ្ទាត់គណនេយ្យរដ្ឋបាលរបស់ខ្លួនជាមួយនឹងគណនីគ្រប់គ្រងដោយគណនេយ្យករសាធារណៈរបស់រតនាគារ និង រៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា ព្រមទាំងព័ត៌មានចាំបាច់ផ្សេងៗទៀត ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និង អនុម័ត និង ផ្ញើជូនមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើការបូកសរុបជារបាយការណ៍រួមរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ រួចផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបូកសរុបជាសេចក្តីព្រាងនៃការទូទាត់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និង ដាក់បញ្ចូលទៅក្នុងជំពូកមួយនៃសេចក្តីព្រាងច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋ ដែលត្រូវដាក់ទៅសុំការពិនិត្យ និង អនុម័តពីរដ្ឋសភា និង ព្រឹទ្ធសភា ។

ជំពូកទី ៤
ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

មាត្រា ៤៧.-

ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមានទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឲ្យ និង ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង ។ រដ្ឋផ្ទេរ និង ប្រគល់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិកាន់កាប់ និង ប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋមួយចំនួនដែលជាអចលនវត្ថុ ហើយស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗទៅតាមការកំណត់របស់រដ្ឋ ។

ការផ្ទេរ ប្រគល់ទ្រព្យសម្បត្តិរបស់រដ្ឋទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ការផ្ទេរ ប្រគល់ ត្រូវបានប្រតិបត្តិក្នុងលក្ខណៈដែលអាចដកហូតយកមកវិញបាន ។

មាត្រា ៤៨.-

ការផ្ទេរទ្រព្យសម្បត្តិពីថ្នាក់ជាតិដើម្បីជាគុណប្រយោជន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ប្រើប្រាស់ជាសាធារណៈ ឬ សម្រាប់បំពេញនូវតម្រូវការនៃសេវាសាធារណៈ ត្រូវសមស្របទៅនឹងមុខងារ ដែលបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។

មាត្រា ៤៩.-

ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលត្រូវបានផ្ទេរប្រគល់ឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង ប្រើប្រាស់ និង ទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវថែរក្សាការពារឲ្យបានគង់វង្ស និង គ្មានសិទ្ធិលក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬ ផ្ទេរការប្រើប្រាស់ ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

មាត្រា ៥០.-

ទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯង ជាកម្មសិទ្ធិផ្ទាល់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិស្វ័យសម្រេចក្នុងការគ្រប់គ្រង និង ប្រើប្រាស់ដើម្បីទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ នៅក្នុងក្របខ័ណ្ឌដែលត្រូវកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។



Ksl

មាត្រា ៥១.-

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបញ្ចូលក្នុងបញ្ជីសារពើភណ្ឌរួមនៃទ្រព្យសម្បត្តិរដ្ឋ ។

ជំពូកទី ៥
បទប្បញ្ញត្តិដោយឡែក

មាត្រា ៥២.-

ក្នុងការអនុវត្តច្បាប់នេះដើម្បីឲ្យស្របទៅតាមតម្រូវការចាំបាច់ និង ផ្អែកតាមស្ថានភាព ជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរួមទាំងរដ្ឋបាលឃុំ សង្កាត់ផង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវពិភាក្សាជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើឡើងនូវអនុក្រឹត្យ ឬ ចេញប្រកាសដោយឡែកៗសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនោះ ។

ជំពូកទី ៦
ទោសប្បញ្ញត្តិ

មាត្រា ៥៣.-

សមាជិកក្រុមប្រឹក្សា និង មន្ត្រីសាធារណៈគ្រប់ប្រភេទ និង គ្រប់ឋានៈដែលកំពុងបម្រើការងារ និង អ្នកដែលធ្លាប់បានបម្រើការងារកន្លងមក ហើយរកឃើញថាមិនបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងការអនុវត្តមុខងារ និង ភារកិច្ចរបស់ខ្លួនដែលបានប្រគល់ជូន នឹងត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដែលមានជាធរមាន ដោយមិនគិតដល់ទោសព្រហ្មទណ្ឌ និង ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ព្រមទាំងត្រូវសងបង់ចូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិវិញ នូវរាល់តម្លៃបាត់បង់ខូចខាតទ្រព្យសម្បត្តិ ឬ ប្រាក់កាសសាធារណៈរួមទាំងការប្រាក់លើតម្លៃបាត់បង់ខូចខាត ដែលបង្កឡើងដោយកំហុសឆ្គងនេះ ។

ជំពូកទី ៧
អន្តរប្បញ្ញត្តិ

មាត្រា ៥៤.-

ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលអនុវត្តកន្លងមកនៅមានសុពលភាពរហូតដល់មានច្បាប់ និង លិខិតបទដ្ឋានគតិយុត្តថ្មីមក

ជំនួសស្របតាមស្មារតីនៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង ច្បាប់នេះ ។

ជំពូកទី ៨
អវសានប្បញ្ញត្តិ

មាត្រា ៥៥.-

ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ បទប្បញ្ញត្តិទាំងឡាយដែលជាវិសោធនកម្មនៃច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង និង បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥៦.-

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.១១០៦.៥៩៤

នរោត្តម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា
គាត ឈន់

26/20

លេខៈ ៥៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

Chapter 8

Prakas #324 on SNA procurement committees and procurement units

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣២៤ សហវ.ប្រក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាសអន្តរក្រសួង

ស្តីពី

នីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ

នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- យោងអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងអនុក្រឹត្យលេខ ៦០អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ប្រការ ២.-

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌត្រូវរៀបចំឲ្យមានគណៈកម្មាធិការលទ្ធកម្មរៀងៗខ្លួន ដើម្បីធានាឲ្យការគ្រប់គ្រង ការដឹកនាំ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និង ការជួលសេវាទីប្រឹក្សាប្រព្រឹត្តទៅដោយរលូនប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព គុណភាព សមភាព ការសន្សំសំចៃ និងទាន់ពេលវេលា។

ប្រការ ៣.-

គណៈកម្មាធិការលទ្ធកម្មរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបង្កើតឡើងដោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។

ប្រការ ៤.-

អង្គភាពលទ្ធកម្មរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌស្ថិតក្នុងរចនាសម្ព័ន្ធសាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក សាលាខណ្ឌ។

ប្រការ ៥.-

រដ្ឋបាលខណ្ឌ និងសង្កាត់ចំណុះរាជធានីត្រូវរាយការណ៍ជូនរដ្ឋបាលរាជធានីអំពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

រដ្ឋបាលសង្កាត់ចំណុះក្រុង ត្រូវរាយការណ៍ជូនរដ្ឋបាលក្រុងអំពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

ជំពូកទី ២
គណៈកម្មាធិការលទ្ធកម្ម

ប្រការ ៦.-

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវមានសមាសភាពដូចខាងក្រោម៖

- អភិបាលរាជធានី ខេត្ត	ប្រធាន
- អភិបាលរងរាជធានី ខេត្ត ០១រូប	អនុប្រធាន
- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន
- សមាជិកក្រុមប្រឹក្សារាជធានី ខេត្តយ៉ាងច្រើន០៣រូប	សមាជិក
- នាយករដ្ឋបាលនៃសាលារាជធានី ខេត្ត	សមាជិក
- នាយកទីចាត់ការហិរញ្ញវត្ថុ	សមាជិក
- ប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត	លេខាធិការ

សមាសភាពអនុប្រធានគណៈកម្មាធិការលទ្ធកម្មដែលជាអភិបាលរង ត្រូវស្នើដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

សមាសភាពនៃគណៈកម្មាធិការលទ្ធកម្មរាជធានី ខេត្ត ដែលជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវជ្រើសរើសដោយក្រុមប្រឹក្សារាជធានី ខេត្ត។

ប្រការ ៧.-

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានសមាសភាពដូចខាងក្រោម៖

- អភិបាលក្រុង ស្រុក ខណ្ឌ ប្រធាន
- អភិបាលរងក្រុង ស្រុក ខណ្ឌ ០១រូប អនុប្រធាន
- សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌយ៉ាងច្រើន០៣រូប សមាជិក
- នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ លេខាធិការ

សមាសភាពអនុប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវស្មើដោយអភិបាលក្រុង ស្រុក ខណ្ឌ។

សមាសភាពនៃគណៈកម្មាធិការលទ្ធកម្មក្រុង ស្រុក ខណ្ឌ ដែលជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវជ្រើសរើសដោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។

ប្រការ ៨.-

ក្នុងដំណើរការកិច្ចលទ្ធកម្មនីមួយៗ ប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវតែងតាំងសមាជិកចំពោះកិច្ចមួយចំនួន ដែលជាមន្ត្រីមានសមត្ថភាពគាំទ្របច្ចេកទេសមកពីអង្គភាព ស្ថាប័នរបស់រដ្ឋ ឬ ជួលពីខាងក្រៅដោយប្រើប្រាស់ថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអាចអញ្ជើញមន្ត្រីជំនាញក្នុងរដ្ឋបាលរបស់ខ្លួន ឬ ពីអង្គភាព ស្ថាប័នរដ្ឋផ្សេងៗទៀត ដើម្បីជួយផ្តល់យោបល់។

សមាជិកចំពោះកិច្ចនៃគណៈកម្មាធិការលទ្ធកម្មត្រូវរំសាយដោយស្វ័យប្រវត្តិនៅពេលកិច្ចលទ្ធកម្មនោះត្រូវបានបញ្ចប់ជាស្ថាពរ។

ប្រការ ៩.-

សមាជិកគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការលទ្ធកម្ម។

ប្រការ ១០.-

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវធ្វើសេចក្តីសម្រេចដោយសម្លេងភាគច្រើន។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានគណៈកម្មាធិការលទ្ធកម្មមានឧត្តមានុភាព។

ប្រការ ១១.-

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

- គោរពឱ្យបានខ្ជាប់ខ្ជួនតាមក្រមសីលធម៌លទ្ធកម្ម
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលរៀបចំដោយអង្គភាពលទ្ធកម្ម ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងឯកភាព មុននឹងផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័ត
- ណែនាំឱ្យអង្គភាពលទ្ធកម្មអនុវត្តឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម
- ប្រជុំវាយតម្លៃ កំណត់បុរេលក្ខណៈសម្បត្តិចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- ត្រួតពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗ មុននឹងចាប់ផ្តើមដំណើរការលទ្ធកម្ម
- ត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន។ ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបញ្ជូនឯកសារដេញថ្លៃទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័ត
- ប្រជុំបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្នងតម្លៃ ឬចរចាថ្លៃ
- ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា
- ត្រួតពិនិត្យនិងវាយតម្លៃឡើងវិញលើលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខមុនការសម្រេចប្រគល់កិច្ចសន្យា
- ជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឲ្យអ្នកដេញថ្លៃឈ្នះនិងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- គ្រប់គ្រង និងតាមដានការអនុវត្តកិច្ចសន្យា
- រាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការកិច្ចលទ្ធកម្មក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញតាមការចាំបាច់ និងការកំណត់របស់ក្រុមប្រឹក្សា
- ផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីរបាយការណ៍នោះត្រូវបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន
- អញ្ជើញតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួមសង្កេតការណ៍ដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្មលើកលែងតែដំណាក់កាលនៃការវាយតម្លៃប្រគល់កិច្ចសន្យា
- ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន ។

ប្រការ ១២.-

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌមានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- គោរពឱ្យបានខ្ជាប់ខ្ជួនតាមក្រមសីលធម៌លទ្ធកម្ម
- ពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលរៀបចំដោយអង្គភាពលទ្ធកម្មដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងឯកភាព មុននឹងផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងអនុម័ត។
- ណែនាំឱ្យអង្គភាពលទ្ធកម្មអនុវត្តឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម
- ប្រជុំវាយតម្លៃ កំណត់បុរេលក្ខណៈសម្បត្តិចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- ត្រួតពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗ មុននឹងចាប់ផ្តើមដំណើរការលទ្ធកម្ម
- ត្រួតពិនិត្យនិងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន
- ប្រជុំបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចាថ្លៃ
- ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា
- ត្រួតពិនិត្យនិងវាយតម្លៃឡើងវិញលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខ មុនការសម្រេចប្រគល់កិច្ចសន្យា
- ជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឲ្យអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- រាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការកិច្ចលទ្ធកម្មក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញតាមការចាំបាច់ និងការកំណត់របស់ក្រុមប្រឹក្សា
- ផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីរបាយការណ៍នោះត្រូវបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន
- ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន ។

ជំពូកទី ៣

អង្គភាពលទ្ធកម្ម

ប្រការ ១៣.-

អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានរចនាសម្ព័ន្ធស្ថិតក្រោមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផ្ទាល់ និងជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាល

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ប្រធានអង្គភាពលទ្ធកម្មជាលេខាធិការរបស់គណៈកម្មាធិការលទ្ធកម្ម ។

អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវដឹកនាំដោយប្រធានមួយ(០១) រូប និងមានអនុប្រធានយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ ដែលមិនត្រូវមានតួនាទី និងភារកិច្ចពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុផ្សេងទៀតក្នុងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួនឡើយ។

ប្រការ ១៤.-

អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តមានកម្រិតស្មើនឹងទីចាត់ការសាលារាជធានី ខេត្ត។ ប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តមានឋានៈស្មើនាយក និងនាយករងទីចាត់ការសាលារាជធានី ខេត្ត ។

អង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌមានកម្រិតស្មើនឹងការិយាល័យសាលាក្រុង ស្រុក ខណ្ឌ។ ប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌមានឋានៈស្មើប្រធាន និងអនុប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ។

ប្រការ ១៥.-

ប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានតែងតាំង ឬផ្លាស់ប្តូរដោយក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌតាមសំណើរបស់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើលក្ខណៈសម្បត្តិដែលត្រូវតែងតាំង តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ លក្ខខណ្ឌនៃការតែងតាំងប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវផ្អែកតាមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រធានអង្គភាពលទ្ធកម្មត្រូវមានលក្ខណៈសម្បត្តិបន្ថែមដូចខាងក្រោម៖

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាប័ត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុយ៉ាងតិច ៣ឆ្នាំ និង
- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកលទ្ធកម្មសាធារណៈ ដោយមានវិញ្ញាបនប័ត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ប្រការ ១៦.-

អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់
- រៀបចំឯកសារដេញថ្លៃ សម្រាប់ប្រភេទលទ្ធកម្មនីមួយៗ ផ្អែកតាមគំរូឯកសារដេញថ្លៃដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីកិច្ចលទ្ធកម្មនីមួយៗ

- លក់ ឬផ្ដល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្ម
- ទទួលសំណើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃ ក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ
- រៀបចំទុកដាក់សំណើដេញថ្លៃដែលបានទទួលឱ្យបានត្រឹមត្រូវ មានសុវត្ថិភាព និងត្រូវគ្រប់គ្រងឯកសារ ឬលិខិតស្នាមពាក់ព័ន្ធទាំងអស់មុនពេលបើកសំណើដេញថ្លៃ
- ចាត់ចែងរៀបចំទីកន្លែងសម្រាប់បើកសំណើដេញថ្លៃ
- រៀបចំបើកសំណើដេញថ្លៃជាសាធារណៈ ដោយមានការដឹកនាំត្រួតពិនិត្យពីគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំធ្វើរបាយការណ៍ ឬកំណត់ហេតុស្ដីពីការបើកសំណើដេញថ្លៃ
- ជួយសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃលើសំណើដេញថ្លៃ
- ផ្ញើលិខិតជូនដំណឹងស្ដីពីការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ធ្វើសេចក្ដីព្រាងកិច្ចសន្យាឱ្យសមស្របតាមបទដ្ឋានឯកសារកិច្ចសន្យាដែលបានកំណត់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- តាមដានការអនុវត្តកិច្ចសន្យា ដោយសហការជាមួយមន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀត
- រៀបចំរបាយការណ៍ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

ប្រការ ១៧.-

ត្រូវបានផ្ទេរការិយាល័យលទ្ធកម្មនៃទីចាត់ការហិរញ្ញវត្ថុសាលារាជធានី ខេត្ត ដែលកំណត់ក្នុងប្រកាសលេខ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ និងប្រកាសលេខ៤២៧៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ដើម្បីបង្កើតអង្គភាពលទ្ធកម្មមួយដោយឡែកចំណុះរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ខេត្តត្រូវផ្ទេរប្រធាន អនុប្រធានការិយាល័យ និងមន្ត្រី បុគ្គលិក ឧបករណ៍ សម្ភារៈ មធ្យោបាយ និងការងារពាក់ព័ន្ធនឹងកិច្ចការលទ្ធកម្មពីការិយាល័យលទ្ធកម្មនៃទីចាត់ការហិរញ្ញវត្ថុរបស់សាលារាជធានី ខេត្តទៅឲ្យអង្គភាពលទ្ធកម្មនៃសាលារាជធានី ខេត្តដែលបង្កើតថ្មីតាមស្មារតីប្រកាសនេះ។

រដ្ឋបាលក្រុង ស្រុកត្រូវផ្ទេរមន្ត្រី បុគ្គលិក ឧបករណ៍ សម្ភារៈ មធ្យោបាយ និងការងារពាក់ព័ន្ធនឹងកិច្ចការលទ្ធកម្មពីការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុកទៅឲ្យអង្គភាពលទ្ធកម្មសាលាក្រុង ស្រុកដែលបង្កើតថ្មីតាមស្មារតីប្រកាសនេះ។

ក្នុងករណីតែងតាំងប្រធានអង្គភាពលទ្ធកម្មដែលត្រូវជ្រើសរើសបេក្ខភាពផ្សេងពីប្រធានការិយាល័យលទ្ធកម្មបច្ចុប្បន្ន និងក្នុងករណីមានការស្នើសុំផ្លាស់ប្តូរប្រធានអង្គភាពលទ្ធកម្មនាពេលខាងមុខ បេក្ខភាពដែលស្នើសុំតែងតាំង ឬជំនួសត្រូវមានលក្ខណៈសម្បត្តិដូចមានចែងក្នុងប្រការ១៥នៃប្រកាសនេះ។

ជំពូកទី ៤
អន្តរប្បញ្ញត្តិ

ប្រការ ១៨.-

ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុត្រូវធ្វើ ប្រតិភូកម្មអំណាចឲ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បី៖

- ពិនិត្យនិងអនុម័តផែនការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង
- ពិនិត្យនិងសម្រេចលើកិច្ចលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រការ ១៩.-

នៅពេលមិនទាន់មានលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ យោងតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលរាជធានី ខេត្តត្រូវលើកសំណើសុំតែងតាំង ឬផ្លាស់ប្តូរប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មសាលារាជធានី ខេត្ត ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យសម្រេចតាមគោលការណ៍ បែបបទ និងនីតិវិធីកំណត់។ អភិបាលរាជធានី អភិបាលខេត្ត យោងតាមសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌដែលមានការឯកភាពពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យ សម្រេចលើការតែងតាំង ឬផ្លាស់ប្តូរប្រធាន និងអនុប្រធាន អង្គភាព លទ្ធកម្មសាលាក្រុង ស្រុក ខណ្ឌស្របតាមគោលការណ៍ បែបបទ និងនីតិវិធីកំណត់។

ប្រការ ២០.-

ផ្អែកតាមការកំណត់នៃប្រការ១៤ ខាងលើ ប្រាក់បំណាច់មុខងារប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមមាត្រា១៤៥ នៃអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ និងមាត្រា២០៧ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការ ងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាល ស្រុក។

ប្រការ ២១.-

ផ្អែកតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាមទារឲ្យមានការរៀបចំនូវយន្តការ នីតិវិធី ការតែងតាំងមន្រ្តី និងការបណ្តុះបណ្តាលកសាងសមត្ថភាពជាមុន។ ការរៀបចំនូវកិច្ចដំណើរការទាំងនេះត្រូវអនុវត្តភ្លាមបន្ទាប់ពីប្រកាសនេះចូលជាធរមាន ដើម្បីឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានលទ្ធភាពអនុវត្តនូវកិច្ចលទ្ធកម្មសាធារណៈរបស់ខ្លួន ក្នុងពេលវេលាសមស្របណាមួយក្នុងឆ្នាំ២០១៣។

ក្នុងពេលដែលកិច្ចដំណើរការខាងលើនេះពុំទាន់បានរៀបចំចប់សព្វគ្រប់ កិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវអនុវត្តតាមយន្តការ និងនីតិវិធីនៃកិច្ចលទ្ធកម្មសាធារណៈដែលអនុវត្តនៅរដ្ឋបាលរាជធានី ខេត្ត។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

ប្រការ ២២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ២៣.-

ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាសង្កាត់ អង្គភាពចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ០៧ ឆ្នាំ២០១៣

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន:</u>

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋានគ.ជ.អ.ប
- ដូចប្រការ ២៣
- ឯកសារ-កាលប្បវត្តិ

Chapter 9

Module on the fiscal decentralisation and financial management

មេរៀនសំរាប់ការយល់ដឹង និង ការបណ្តុះបណ្តាលអំពី

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

មេរៀនទី ១៥:

វិមជ្ឈការសារពើពន្ធ និង ការគ្រប់គ្រងហិរញ្ញវត្ថុ

វគ្គទី ១៖

១. សេចក្តីផ្តើម

២. វិមជ្ឈការសារពើពន្ធ

៣. ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

៤. ការចាត់ចែងហិរញ្ញវត្ថុរបស់ឃុំ សង្កាត់

ផ្នែកទី ១៖ សេចក្តីផ្តើម

- ✓ វិមជ្ឈការសារពើពន្ធ គឺជាផ្នែកដ៏សំខាន់ **និងជាផ្នែកដែលមិនអាចខ្វះបាននៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**។ វិមជ្ឈការសារពើពន្ធ សំដៅលើសិទ្ធិរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងប្រមូលចំណូលរបស់ខ្លួនផ្ទាល់ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនដោយមានស្វ័យភាពបង្គួរ។ វិមជ្ឈការសារពើពន្ធគួរធានាថា ក្រុមប្រឹក្សានីមួយៗមានធនធានហិរញ្ញវត្ថុ និងមានឆន្ទានុសិទ្ធិចាំបាច់ ដើម្បីប្រកាន់យកជម្រើសដែលឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។
- ✓ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ឆ្នាំ ២០០៦-២០១០ គូសបញ្ជាក់ពីសារៈសំខាន់របស់ក្រុមប្រឹក្សាក្នុងការមាន**ហិរញ្ញវត្ថុគ្រប់គ្រាន់** (រួមមានចំណូលរបស់ខ្លួនផ្ទាល់ពីពន្ធ និងកម្រៃ)។ (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០)។
- ✓ ប្រជាពលរដ្ឋ មានឱកាសកាន់តែធំទូលាយ ដើម្បីចូលរួមចំណែកជាមួយក្រុមប្រឹក្សាដែលបានជាប់ឆ្នោតរបស់ខ្លួន ដើម្បីមានឱកាសធ្វើឱ្យមានឥទ្ធិពលទៅលើរបៀបចំណាយមូលនិធិសាធារណៈនៅថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ ប្រជាពលរដ្ឋអាចមើលឃើញយ៉ាងងាយអំពីរបៀបដែលក្រុមប្រឹក្សានៅមូលដ្ឋាន ធ្វើការចំណាយ ឬមិនចំណាយមូលនិធិសាធារណៈ។
- ✓ ជាមួយនឹង**ការលើកកម្ពស់តម្លាភាព** និង **ឱកាសកាន់តែធំទូលាយដើម្បីធ្វើឱ្យមានឥទ្ធិពល**លើសេចក្តីសម្រេចនោះ ប្រជាពលរដ្ឋ គួរស្ថិតនៅក្នុងទីតាំងដ៏ល្អក្នុងធ្វើឱ្យ**ក្រុមប្រឹក្សាមានគណនេយ្យភាព**ចំពោះរបៀបដែលក្រុមប្រឹក្សាចំណាយធនធានហិរញ្ញវត្ថុរបស់ខ្លួន។

ចំណុចល្អ និងមិនល្អនៃស្វ័យភាពហិរញ្ញវត្ថុ

ជាមួយនឹងការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការលុបបំបាត់អំពើពុករលួយ រាជរដ្ឋាភិបាលមានការខ្វល់ខ្វាយយ៉ាងត្រឹមត្រូវអំពីសុចរិតភាពនៃមូលនិធិដែលបានផ្ទេរឱ្យថ្នាក់ក្រោមជាតិ។ ជាការសំខាន់ដែលត្រូវមានយន្តការ ដើម្បីចៀសវាងអំពើពុករលួយ និងដើម្បីលាតត្រដាង និងដាក់ទណ្ឌកម្មអំពើពុករលួយនៅពេលដែលអំពើនេះកើតមានឡើង។ ទោះបីជាយ៉ាងក៏ដោយ គ្មានប្រទេសណាមួយនៅលើពិភពលោកដែលមិនមានអំពើពុករលួយនោះឡើយ។

អ្វីដែលសំខាន់នោះ ការខ្វល់ខ្វាយអំពីអំពើពុករលួយ មិនគួរមានអានុភាពលើការចាំបាច់ក្នុងការផ្តល់ដល់ក្រុមប្រឹក្សានូវស្វ័យភាពផ្នែកហិរញ្ញវត្ថុពេញលេញឡើយ។ ក្រុមប្រឹក្សាត្រូវការស្វ័យភាពផ្នែកហិរញ្ញវត្ថុពេញលេញ ដើម្បីមានលទ្ធភាពឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។

- ✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្តល់ការចង្អុលបង្ហាញយ៉ាងទូលំទូលាយអំពីហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវមានការបកស្រាយលើខ្លឹមសារលំអិតជាច្រើនទៀតទាក់ទងនឹងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សានៅក្នុងច្បាប់ និងលិខិតបទដ្ឋាន រួមមាន *ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ* (មាត្រា ៤៤-៤៦, ២៤៤, ២៤៥, ២៤៨, ២៥៣, ២៥៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) មានអនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ ដែលជួយ និងផ្តល់យោបល់ គ.ជ.អ.ប អំពីការងារទាក់ទងនឹងកិច្ចការហិរញ្ញវត្ថុ និងសារពើពន្ធរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ (មាត្រា ១០ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការ គ.ជ.អ.ប)។

កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM)

វិមជ្ឈការហិរញ្ញវត្ថុ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM)។ ទិសដៅមួយនៅក្នុងកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដំណាក់កាលទី២ ឆ្នាំ២០០៨ ដល់ឆ្នាំ២០១០) គឺដើម្បី*ពង្រឹង និងអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការសារពើពន្ធ*។ ទិសដៅនេះ នឹងត្រូវសម្រេចបានតាមរយៈការធានាឱ្យបានថា គោលនយោបាយ វិមជ្ឈការរបស់រាជរដ្ឋាភិបាល និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុវត្ត និងថាគោលនយោបាយ និងច្បាប់នេះ មានបញ្ចូល**គណនេយ្យភាព**។ កំណែទម្រង់ពីរ គឺកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវដំណើរការព្រមគ្នា និងមានសុខដុមជាមួយគ្នា។

នៅថ្នាក់ឃុំ សង្កាត់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានបំណងកែលម្អការរៀបចំ និងការអនុវត្តថវិកា ក៏ដូចជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា។ ក្តីសង្ឃឹមគឺថា ជាការចាប់ផ្តើមការប្រមូលចំណូលមិនមែនជាពន្ធ នឹងមានការកើនឡើង (សូមអានកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ២ ទំព័រ ៤២ ទិសដៅទី ២៧)។

ផ្នែកទី ២: វិមជ្ឈការសារពើពន្ធ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ២៤១-២៤៣, ២៤០

សេចក្តីផ្តើម

- ✓ សមាសធាតុដ៏សំខាន់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់អោយមានការ **មុខងារគ្រប់គ្រង** ត្រូវបាន**ផ្ទេរ**ឱ្យក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សា ឃុំ (មាត្រា ២១៤, ២១៧, ២៧៧, ២៧៨, ២៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

  - **ឧទាហរណ៍** ក្រុមប្រឹក្សាក្រុងអាចទទួលបានការផ្ទេរមុខងារឱ្យប្រមូលសម្រាម សាងសង់ ជួសជុល និងថែទាំប្រព័ន្ធលូបង្ហូរទឹកកខ្វក់ និងផ្តល់ទីជម្រកដល់ជនអនាថា។ ក្រុមប្រឹក្សាស្រុក អាចទទួលបានការផ្ទេរមុខងារក្នុងនោះផ្តល់ការអប់រំនៅបឋមសិក្សា និងគ្រប់គ្រងមន្ទីរពេទ្យបង្អែកស្រុក។ ក្រុមប្រឹក្សាឃុំ អាចទទួលបានការផ្ទេរមុខងារ ឱ្យផ្តល់សេវាផ្សព្វផ្សាយកសិកម្ម និងផ្គត់ផ្គង់ទឹកស្អាត និងគ្រប់គ្រងមណ្ឌលសុខភាព។

> ចំពោះព័ត៌មានបន្ថែមស្តីពីការផ្ទេរមុខងារដល់ក្រុមប្រឹក្សា សូមអានមេរៀនទី ១៣។

- ✓ ជាការគ្មានន័យអ្វីឡើយក្នុងការផ្ទេរមុខងារ (ទោះបីជាមុខងាររដ្ឋបាល ឬមុខងារតាមវិស័យក្តី) ដោយមិនផ្ទេរឱ្យក្រុមប្រឹក្សាក្នុងពេលជាមួយគ្នានូវធនធានដែលក្រុមប្រឹក្សាត្រូវការដើម្បីអនុវត្តមុខងារថ្មីទាំងនោះ។ ដូច្នេះ សមាសធាតុដ៏សំខាន់ទីពីរនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺថាធនធាន **ត្រូវតែមានអមជាមួយមុខងារ**។ ប្រការនេះ មានន័យថា នៅពេលមុខងារ ត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សា ក្រុមប្រឹក្សាក៏ត្រូវតែទទួលបានធនធានសមស្រប (ហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិ) ដើម្បីធ្វើឱ្យក្រុមប្រឹក្សា មានលទ្ធភាពអនុវត្តមុខងារ (មាត្រា ២១៧, ២៤២, ២៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ សមាសធាតុដ៏សំខាន់ទីបីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺថា ក្រុមប្រឹក្សា ត្រូវមាន **ចំណូលគ្រប់គ្រាន់** ដើម្បីអនុវត្តកិច្ចការទូទៅរបស់ខ្លួន (មាត្រា ២៤២ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ ការដាក់សមាសធាតុទីពីរ និងទីបីជាមួយគ្នា មានន័យថា ក្រុមប្រឹក្សា ត្រូវមាន**ចំណូលគ្រប់គ្រាន់** ដើម្បីឱ្យក្រុមប្រឹក្សាមានលទ្ធភាព:

- អនុវត្តមុខងារជាកាតព្វកិច្ចរបស់ខ្លួន
- អនុវត្តមុខងារជាជម្រើសមួយចំនួន
- បំពេញភារកិច្ចតាមផ្លូវច្បាប់របស់ខ្លួន
- ទូទាត់ការចំណាយផ្នែករដ្ឋបាលសមស្របរបស់ខ្លួន
- អនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនទៅតាមរបៀបដែលជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

  (មាត្រា ២៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

មុខងារជាកាតព្វកិច្ច

មុខងារដែលកំណត់ដោយលិខិតបទដ្ឋានថាជាមុខងារដែលតម្រូវឱ្យក្រុមប្រឹក្សាអនុវត្ត។

មុខងារជាជម្រើស

មុខងារដែលក្រុមប្រឹក្សាអាចជ្រើសរើសអនុវត្ត ឬអាចជ្រើសរើសមិនអនុវត្ត។

ថវិកា

- ✓ **ភ្នំពេញ** និងគ្រប់**ខេត្ត ក្រុង** និង**ស្រុក** មានថវិកាប្រចាំឆ្នាំរបស់ខ្លួនផ្ទាល់។ (មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ **ឃុំ** និង**សង្កាត់ទាំងអស់នៅក្នុងស្រុក** មានថវិការបស់ខ្លួនផ្ទាល់ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (មាត្រា ៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។
- ✓ ថវិការបស់**ខណ្ឌ និងសង្កាត់**នៅរាជធានីភ្នំពេញ គឺជាផ្នែកមួយនៃថវិការបស់រាជធានីភ្នំពេញ។ ថវិការបស់សង្កាត់នៅក្នុងក្រុង គឺជាផ្នែកមួយនៃថវិការបស់ក្រុង។ (មាត្រា ៤៤, ២៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ ការកំណត់បែបនេះ ធ្វើឱ្យរាជធានីភ្នំពេញ និងក្រុង មានលទ្ធភាពធានាឱ្យមានការអភិវឌ្ឍទីប្រជុំជនដែលមានសង្គតិភាព និងមានលក្ខណៈឯកភាពគ្នា។
- ✓ ក្រុមប្រឹក្សា អនុម័តថវិការបស់ខ្លួនអនុលោមទៅតាមដំណើរការប្រចាំឆ្នាំនៃការរៀបចំថវិការដ្ឋ។ ក្រុមប្រឹក្សា ក៏ត្រូវអនុម័តផងដែរនូវ**ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម**ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ (មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ ថវិការបស់ក្រុមប្រឹក្សា ត្រូវមានតុល្យភាពរវាងចំណូល និងចំណាយ (មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**របស់ក្រុមប្រឹក្សា ត្រូវធានាឱ្យបានថា ថវិការបស់ក្រសួងដែលផ្តល់សេវានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុម

ចំពោះព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស សូមអានមេរៀនទី ៧។

ប្រឹក្សា ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការ កម្មវិធី វិនិយោគ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សា។

ប្រភពចំណូលរបស់ក្រុមប្រឹក្សា

✓ ក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាខេត្ត ក្រុង និងស្រុក មានសិទ្ធិទទួលបាន**ចំណូលពីបីប្រភពគឺ**

- ចំណូលផ្ទាល់ខ្លួននៅមូលដ្ឋាន
- ចំណូលពីថ្នាក់ជាតិ
- ចំណូលផ្សេងទៀត (មាត្រា ២៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

តើការបង់ពន្ធ ឬកម្រៃសេវា អាចបង្កើនគណនេយ្យភាពតាមវិធីណា?

នៅពេលលោក អ្នកបង់ពន្ធ ឬកម្រៃសេវាពីហោប៉ៅរបស់លោក អ្នក លោកអ្នកទំនងជាមានក្តីរំពឹងខ្ពស់ពីសេវាដែលលោក អ្នកនឹងទទួលបាន។ ដូច្នេះ លោក អ្នកទំនងជាតម្រូវឱ្យសមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោតរបស់លោក អ្នក ឆ្លើយតបចំពោះសេវាដែលមិនស្របទៅនឹងក្តីរំពឹងរបស់លោក អ្នក។ នៅពេលរដ្ឋាភិបាលប្រមូលពន្ធ និងកម្រៃផ្ទាល់ពីប្រជាពលរដ្ឋរបស់ខ្លួន រដ្ឋាភិបាលមានអារម្មណ៍មានការទទួលខុសត្រូវកាន់តែខ្ពស់ក្នុងការប្រើប្រាស់មូលនិធិ ទៅតាមរបៀបដែលមានការឆ្លើយតបចំពោះតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។

✓ **ចំណូលផ្ទាល់ខ្លួននៅមូលដ្ឋាន អាចត្រូវប្រមូលតាមរយៈ**

- ពន្ធនៅមូលដ្ឋាន (នឹងត្រូវកំណត់នៅក្នុងច្បាប់នៅពេលខាងមុខ)
- កម្រៃ និងឈ្នួល (នឹងត្រូវកំណត់នៅក្នុងច្បាប់ ឬលិខិតបទដ្ឋាននានានៅពេលខាងមុខ)
- ចំណូលរបស់ក្រុមប្រឹក្សាស្រុកពីពន្ធ ដែលត្រូវចែករំលែកជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ (នឹងត្រូវកំណត់នៅក្នុងច្បាប់នៅពេលខាងមុខ)
- អំណោយស្ម័គ្រចិត្ត
- ប្រភពផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬអនុក្រឹត្យនៅពេលខាងមុខ (មាត្រា ២៤៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រុមប្រឹក្សា ត្រូវប្រើប្រាស់ចំណូលរបស់ខ្លួន ដើម្បីផ្តោតទៅលើតម្រូវការអភិវឌ្ឍន៍សំខាន់បំផុត រួមមាន **តម្រូវការខុសគ្នារបស់ស្ត្រី យុវជន កុមារ និងក្រុមងាយរងគ្រោះ**រួមទាំងជនក្រីក្រ និងជនជាតិដើមភាគតិច (មាត្រា ៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រៅពីនេះ ជាការសំខាន់ដែលត្រូវធានាថា ពន្ធ កម្រៃ និងឈ្នួល មិនមាន**ផលប៉ះពាល់ដោយមិនសមាមាត្រ និងដោយមិនយុត្តិធម៌មកលើស្ត្រី ឬមកលើជនក្រីក្រ ឬក្រុមងាយរងគ្រោះផ្សេងទៀត។**

- ✓ **ចំណូលពីថ្នាក់ជាតិ** មានតាមរយៈ
  - ការចែករំលែកចំណូលជាតិ (នឹងត្រូវកំណត់នៅក្នុងច្បាប់នៅពេលខាងមុខ)
  - មូលនិធិផ្ទេរពីថវិកាជាតិ (នឹងត្រូវកំណត់នៅក្នុងច្បាប់នៅពេលខាងមុខ)
  - កម្រៃជាភ្នាក់ងារសម្រាប់សេវាពិសេសដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួង (មាត្រា ២៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ **មូលនិធិផ្ទេរពីថវិការជាតិ**ឡើងតាមរយៈ**ប្រាក់ផ្ទេរដោយមានភ្ជាប់ល័ក្ខខ័ណ្ឌ និងគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ** (មាត្រា ២៤៩ ដល់ ២៥១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

ប្រាក់ផ្ទេរជាតិដល់ក្រុមប្រឹក្សា

ប្រាក់ផ្ទេរគ្មានល័ក្ខខ័ណ្ឌ	**ប្រាក់ផ្ទេរមានល័ក្ខខ័ណ្ឌ**
✓ ដើម្បីបំពេញភារកិច្ចតាមផ្លូវច្បាប់របស់ក្រុមប្រឹក្សា	✓ ដើម្បីអនុវត្តមុខងារជាកាតព្វកិច្ច
✓ ដើម្បីអនុវត្តមុខងារជាជម្រើស	✓ ដើម្បីអនុវត្តមុខងារជាជម្រើសដែលកំពុងដំណើរការ
✓ ដើម្បីទូទាត់ការចំណាយផ្នែករដ្ឋបាល	✓ សម្រាប់គោលបំណងជាកាតព្វកិច្ចដែលបានកំណត់ផ្សេងទៀត
✓ ដើម្បីអនុវត្តមុខងារ និងភារកិច្ចទៅតាមរបៀបដែលជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ	

សេចក្តីសង្ខេបអំពីប្រភពចំណូល
ទាំងបីរបស់ក្រុមប្រឹក្សា



ផ្នែកទី ៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

ការគ្រប់គ្រងហិរញ្ញវត្ថុ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

មាត្រា ៤២. ៤៥. ២៤១. ២៩២

- ✓ ក្រុមប្រឹក្សា ត្រូវគ្រប់គ្រង និងប្រើប្រាស់ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បី**ជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**។ ក្រុមប្រឹក្សាក៏ត្រូវផ្តោតផងដែរទៅលើតម្រូវការអភិវឌ្ឍន៍ជាក់លាក់ រួមមាន **សេវាជាមូលដ្ឋាន និងចាំបាច់** និងតម្រូវការខុសៗ គ្នារបស់ស្ត្រី យុវជន កុមារ និងក្រុមងាយរងគ្រោះ (មាត្រា ៤២, ២៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ ហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា គឺជាហិរញ្ញវត្ថុរបស់រដ្ឋ ដូច្នេះ **គឺជាហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់**។
- ✓ ដូច្នេះ ក្រុមប្រឹក្សា ត្រូវគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុរបស់ខ្លួនទៅតាមរបៀបដែលមាន**តម្លាភាព និងគណនេយ្យភាព**ចំពោះប្រជាពលរដ្ឋរបស់ខ្លួន (មាត្រា ៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- ✓ ក្រុមប្រឹក្សា ត្រូវអនុវត្តទៅតាមបទបញ្ជា ប្រព័ន្ធ និងនីតិវិធីទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ដូចជា ទាក់ទងនឹង**ការរៀបចំបញ្ជីគណនេយ្យ** និង**របាយការណ៍ លទ្ធកម្ម** និង**សវនកម្ម**ផ្ទៃក្នុង និងផ្ទៃក្រៅ (មាត្រា ៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។។
- ✓ ក្រុមប្រឹក្សា មិនត្រូវបានអនុញ្ញាតឱ្យខ្ចីប្រាក់ឡើយ (មាត្រា ២៩២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

មាត្រា ៤៦. ២៥៤ - ២៦១

- ✓ ក្រុមប្រឹក្សា មានការទទួលខុសត្រូវចំពោះការប្រើប្រាស់ និងការគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាពលើទ្រព្យសម្បត្តិរដ្ឋ ដែលបានផ្ទេរមកឱ្យក្រុមប្រឹក្សា ឬដែលបានទទួលដោយមធ្យោបាយផ្ទាល់ខ្លួន។ ក្រុមប្រឹក្សា**មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ**អំពីរបៀបដែលក្រុមប្រឹក្សាគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួន (មាត្រា ៤៣,៤៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

> **ឧទាហរណ៍**
>
> **មុខងារវិស័យអប់រំ**
>
> អាចមានសេចក្តីសម្រេចថា ក្រុមប្រឹក្សាឃុំ នឹងទទួលបានការផ្ទេរមុខងារ ដើម្បី*បង្កើត និងប្រតិបត្តិមត្តេយ្យសាលា*។ ប្រសិនបើមុខងារនេះ ត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាឃុំ ក៏ត្រូវទទួលបានផងដែរនូវ៖
>
> - *ហិរញ្ញវត្ថុចាំបាច់*
> - *បុគ្គលិកដែលមានជំនាញចាំបាច់*
> - ***ទ្រព្យសម្បត្តិ*** ដែលទាក់ទងនឹងមត្តេយ្យសាលា ដូចជាអគារមត្តេយ្យសាលាដែលមានស្រាប់និងសំភារៈឧបទ្ទេស។

- ✓ ក្រុមប្រឹក្សាទទួលទ្រព្យសម្បត្តិស្របទៅនឹងមុខងារដែលបានផ្ទេរឱ្យក្រុមប្រឹក្សា ពោលគឺ **ទ្រព្យសម្បត្តិអមជាមួយនឹងមុខងារ**។ ក្នុងករណីដែលមុខងារ ត្រូវបានផ្ទេរ ហើយទ្រព្យសម្បត្តិចាំបាច់ មានបរិមាណមិនគ្រប់គ្រាន់ ឬ គ្មានតែម្តង ក្រុមប្រឹក្សា ត្រូវទទួលបានធនធានហិរញ្ញវត្ថុ ដើម្បីដោះស្រាយមធ្យោបាយចាំបាច់សម្រាប់បំពេញសេចក្តីត្រូវការរបស់ខ្លួន (មាត្រា ២១៧,២៥៦,២៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រុមប្រឹក្សា អាចគ្រប់គ្រង ប្រើប្រាស់ និង**ទាញយកចំណូល**ពីទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរមកឱ្យក្រុមប្រឹក្សា(មាត្រា ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រុមប្រឹក្សាគ្មានសិទ្ធិលក់ទ្រព្យសម្បត្តិរដ្ឋ ដោយគ្មានការយល់ព្រមពីក្រសួងមហាផ្ទៃ និងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ (មាត្រា ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

តួអង្គពាក់ព័ន្ធ

- ✓ **ក្រុមប្រឹក្សា** មានសិទ្ធិទាំងស្រុងលើការអនុម័តថវិកា កម្មវិធីវិនិយោគ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សា (មាត្រា ៤៤, ២៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ **អភិបាល** គឺជាអាណាប័កក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ (មាត្រា ២៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

> វាជា**ការរំលោភអំណាច** ប្រសិនបើសមាជិកក្រុមប្រឹក្សា អភិបាល គណៈអភិបាល ប្រធានហិរញ្ញវត្ថុ ឬបុគ្គលិករបស់ក្រុមប្រឹក្សា យក ឬប្រើប្រាស់មូលនិធិ ឬទ្រព្យសម្បត្តិរបស់ក្រុមប្រឹក្សាជាប្រយោជន៍ផ្ទាល់ខ្លួន។

- ✓ **គណៈអភិបាល** ជួយក្រុមប្រឹក្សាក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនទាក់ទងនឹងហិរញ្ញវត្ថុ។ គណៈអភិបាល រៀបចំសេចក្តីព្រាងថវិកា កម្មវិធីវិនិយោគ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ហើយដាក់ជូនក្រុមប្រឹក្សាសម្រាប់ពិចារណា និងសម្រេច។ គណៈអភិបាល រាយការណ៍ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំទាំងអស់ទាក់ទងនឹងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា។ គណៈអភិបាល ក៏ត្រូវបំពេញការងារជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសផងដែរ *(សូមអានខាងក្រោម)* (មាត្រា ១៥៦, ១៦៣, ១៦៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រុមប្រឹក្សា មាន**ប្រធានហិរញ្ញវត្ថុ**មួយរូបដែលត្រូវតែងតាំងដោយក្រុមប្រឹក្សា បន្ទាប់ពីមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួងមហាផ្ទៃ។ ប្រធានហិរញ្ញវត្ថុ មានការទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ និងការងារលទ្ធកម្ម ហើយត្រូវធានាឱ្យមានការធ្វើសវនកម្មហិរញ្ញវត្ថុត្រឹមត្រូវ (មាត្រា ១៧៩,១៨០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ ក្រុមប្រឹក្សា ត្រូវមាន**គណៈកម្មាធិការលទ្ធកម្ម។** គណៈកម្មាធិការលទ្ធកម្ម ធានាថា ការងារលទ្ធកម្មទាំងអស់ ត្រូវធ្វើឡើងដោយភាពស្មោះត្រង់ មានតម្លាភាព និងមិនលំអៀង និងអនុលោមទៅតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (មាត្រា ១៣៦,១៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

- ✓ **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស** មានតួនាទីនៅក្នុងការរៀបចំថវិកា កម្មវិធីវិនិយោគ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ក្រុមប្រឹក្សា។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស បំពេញការងារ ដើម្បីធានាថា ផែនការ និងថវិការបស់ក្រសួងស្ថាប័ន មន្ទីរ និងអង្គភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដែលប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ ថវិកា និងកម្មវិធីវិនិយោគរបស់ក្រុមប្រឹក្សា។

> ចំពោះព័ត៌មានបន្ថែមស្តីពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស សូមអានមេរៀនទី ៧។

- ✓ រដ្ឋបាលទាំងអស់ មានអង្គភាពមួយដែលបំពេញការងារលើការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ (មាត្រា ៥៨, ១១២, ១៧៣ នៃអនុក្រឹត្យស្តីពីតួនាទីខេត្ត)

ចំពោះព័ត៌មានបន្ថែមស្តីពីអង្គភាពរដ្ឋបាល សូមអានមេរៀនទី ១២។

តួអង្គផ្នែកហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ



គណៈកម្មាធិការ
លទ្ធកម្ម

ក្រុមប្រឹក្សា

អភិបាល

គណៈអភិបាល

គណៈកម្មាធិការ
សម្របសម្រួល
បច្ចេកទេស

ប្រធានហិរញ្ញវត្ថុ

✓ ដូចដែលបានលើកឡើង ខ្លឹមសារលំអិតជាច្រើនទាក់ទងនឹងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា និងការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានបន្ថែមទៀត រួមមាន *ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ* (មាត្រា ៤៤-៤៦, ២៤៤, ២៤៥, ២៤៨, ២៥៣, ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

ផ្នែកទី ៤: ការចាត់ចែងផ្នែកហិរញ្ញវត្ថុរបស់ឃុំ សង្កាត់

✓ **ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់** ចែងថា:

- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ មាន**ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងថវិការបស់ខ្លួនផ្ទាល់** (មាត្រា ៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។
- ក្រុមប្រឹក្សាឃុំ សង្កាត់ មាន**សិទ្ធិប្រមូលចំណូលផ្ទាល់ខ្លួន**ពីចំណូលពន្ធ ចំណូលមិនមែនពន្ធ និងកម្រៃ (ការប្រមូលពន្ធត្រូវធ្វើឡើងអនុលោមទៅតាមច្បាប់) (មាត្រា៧៤នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។
- ក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិទទួលបាន:
    - **ការបែងចែកចំណូលជាតិ**
    - កម្រៃពីការអនុវត្ត**មុខងារជាភ្នាក់ងារ**
    - មូលនិធិបន្ថែមពីប្រភពខាងក្នុង និងក្រៅប្រទេស (មាត្រា ៧៥,៧៦ និង៧៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់) រួមទាំងមូលនិធិពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។

> **មុខងារជាភ្នាក់ងារ**
>
> មុខងារដែលត្រូវបានធ្វើប្រតិភូកម្ម ដោយក្រសួងខ្សែបណ្តោយ ឬស្ថាប័នរបស់រាជរដ្ឋាភិបាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់។ មុខងារត្រូវអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងនាមក្រសួងខ្សែបណ្តោយ ឬស្ថាប័នរបស់រាជរដ្ឋាភិបាល។

- **មូលនិធិឃុំ សង្កាត់** ត្រូវបានបង្កើតឡើងនៅថ្នាក់ជាតិជាយន្តការសម្រាប់ការផ្ទេរមូលនិធិពីថ្នាក់ជាតិដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានបដិភាគរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ (មាត្រា ៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)
- ក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលបាន**ទ្រព្យសម្បត្តិ**រដ្ឋ ដែលក្រុមប្រឹក្សាអាចប្រើប្រាស់ និងបង្កើតចំណូល (មាត្រា ៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។

✓ ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏មានសិទ្ធិប្រមូល**ចំណូលនៅមូលដ្ឋាន**មួយចំនួនផងដែរ ដូចជាកម្រៃពីការចុះអត្រានុកូលដ្ឋាន។

✓ បរិមាណនៃមូលនិធិដែលក្រុមប្រឹក្សាឃុំ សង្កាត់បានទទួលតាមរយៈការផ្ទេរពីថ្នាក់ជាតិ មានលក្ខណៈបង្គួរ ប៉ុន្តែមានការកើនឡើងជារៀងរាល់ឆ្នាំ។ នៅឆ្នាំ ២០០២ ក្រុមប្រឹក្សាទទួលបាន ១,២% នៃចំណូលជាតិ។ សម្រាប់ឆ្នាំ ២០០៨ ក្រុមប្រឹក្សា ទទួលបាន**២,៧៥% នៃចំណូលជាតិ**។ នៅឆ្នាំ ២០០៨ ទឹកប្រាក់**ជាមធ្យម**នៅក្នុងថវិកាអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានប្រហែល **១០.០០០ ដុល្លារអាមេរិក**។

✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នឹងបន្តគ្រប់គ្រងក្រុមប្រឹក្សាឃុំនៅក្នុងស្រុកទាក់ទងនឹងហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាក្តី ថវិការបស់សង្កាត់នៅរាជធានីភ្នំពេញ និងនៅក្រុង នឹងត្រូវដាក់បញ្ចូលទៅក្នុងថវិការបស់រាជធានីភ្នំពេញ និងថវិការបស់ក្រុង។ (មាត្រា ២៤៤, ២៨៣នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

✓ ក្រៅពីនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា នៅពេលឃុំ ទទួលមុខងារពីថ្នាក់ជាតិ ឃុំក៏ត្រូវទទួលបានធនធានផងដែរ គឺហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិ ដែលចាំបាច់ដើម្បីអនុវត្តមុខងារ (មាត្រា២១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

> ក្រុមប្រឹក្សាឃុំ សង្កាត់ភាគច្រើន បានប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ខ្លួនសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ។

✓ ដូចគ្នានេះដែរ នៅពេលក្រុមប្រឹក្សារាជធានីភ្នំពេញ ឬក្រុមប្រឹក្សាក្រុង ធ្វើប្រតិភូកម្មមុខងារដល់សង្កាត់ ធនធានបន្ថែមដែលសង្កាត់ត្រូវការ ដើម្បីអនុវត្តមុខងារឱ្យមានប្រសិទ្ធិភាព គួរផ្ទេរឱ្យសង្កាត់។

បញ្ហាដែលត្រូវដោះស្រាយ

ខ្លឹមសារលម្អិតជាច្រើនទាក់ទងនឹងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា នឹងត្រូវចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋាន រួមមាន *ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ* (មាត្រា ៤៤-៤៦, ២៤៤, ២៤៥, ២៤៨, ២៥៣, ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

ជាការសំខាន់ដែលត្រូវពិចារណាសារនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិៈ ដើម្បីធ្វើឱ្យមានភាពខុសគ្នាពិតប្រាកដនៅក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សា ត្រូវការ**ហិរញ្ញវត្ថុគ្រប់គ្រាន់** និង**ចំណូលរបស់ខ្លួនផ្ទាល់** និងមានសិទ្ធិគ្រប់គ្រងការប្រមូលចំណូលផ្ទាល់ខ្លួន ក៏ដូចជា**ស្វ័យភាពផ្នែកហិរញ្ញវត្ថុពេញលេញ** ។ ដើម្បីឆ្លើយតប ទៅនឹងតម្រូវការនៅមូលដ្ឋាន ក្រុមប្រឹក្សា ត្រូវមាន**មូលនិធិឆន្ទានុសិទ្ធិ** ដែលក្រុមប្រឹក្សាអាចប្រើប្រាស់ទៅ តាមការយល់ឃើញរបស់ខ្លួនថាជាការសមស្រប ។

ក៏ជាការសំខាន់ផងដែរដែលច្បាប់ និងលិខិតបទដ្ឋាន មានបញ្ចូលយន្តការដ៏រឹងមាំសម្រាប់**តម្លាភាព ការចូលរួមរបស់ប្រជាពលរដ្ឋ** និង**យន្តការគណនេយ្យភាព** ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋធ្វើឱ្យក្រុមប្រឹក្សារបស់ខ្លួនមានគណនេយ្យភាពចំពោះរបៀបប្រើប្រាស់មូលនិធិសាធារណៈ ។

ដើម្បីឱ្យយន្តការទាំងនោះមានន័យ **ក្រុមប្រឹក្សាខ្លួនឯងផ្ទាល់ ត្រូវមានយន្តការដ៏រឹងមាំ** ដើម្បីធានាឱ្យមានតម្លាភាព និងធ្វើឱ្យ**តួអង្គពាក់ព័ន្ធផ្សេងទៀត**នៅក្នុងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាមានគណនេយ្យភាព ។ តួអង្គផ្សេងទៀត រួមមាន អភិបាល គណៈអភិបាល ប្រធានហិរញ្ញវត្ថុ និងគណៈ-កម្មាធិការលទ្ធកម្ម ។ ឧទាហរណ៍ ជាការសំខាន់ដែលត្រូវមានសមាជិកក្រុមប្រឹក្សានៅក្នុង**គណៈកម្មាធិការលទ្ធកម្ម** ពីព្រោះសមាជិកក្រុមប្រឹក្សា មានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋអំពីរបៀបចំណាយមូលនិធិសាធារណៈ ។

វគ្គទី ២:

សង្ខេបមេរៀន

- ភ្នំពេញ ខេត្ត ក្រុង ស្រុក ឃុំនៅក្នុងស្រុក មានថវិការបស់ខ្លួនផ្ទាល់។ ខណ្ឌ និងសង្កាត់នៅភ្នំពេញ ទទួលថវិកាពីក្រុមប្រឹក្សារាជធានីភ្នំពេញ។ សង្កាត់នៅក្នុងក្រុង ទទួលថវិកាពីក្រុមប្រឹក្សាក្រុង។

- ក្រុមប្រឹក្សា ត្រូវអនុម័តថវិកាប្រចាំឆ្នាំរបស់ខ្លួន ហើយត្រូវអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

- ក្រៅពីក្រុមប្រឹក្សា តួអង្គខាងក្រោម មានការពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។ អភិបាល គណៈអភិបាល ប្រធានហិរញ្ញវត្ថុ គណៈកម្មាធិការលទ្ធកម្ម។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក៏ដើរតួនាទីផងដែរ។

- វិមជ្ឈការសារពើពន្ធ គួរធានាថា ក្រុមប្រឹក្សាមានហិរញ្ញវត្ថុ និងស្វ័យភាពផ្នែកហិរញ្ញវត្ថុដែលចាំបាច់ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

- សមាសធាតុដ៏សំខាន់នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺថា ក្រុមប្រឹក្សា ទទួលបានការផ្ទេរមុខងារតាមវិស័យ ដើម្បីអនុវត្ត។ មុខងារ ត្រូវផ្ទេរទន្ទឹមគ្នានឹងការផ្ទេរហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិសមស្របដែលចាំបាច់ ដើម្បីអនុវត្តមុខងារឱ្យមានប្រសិទ្ធិភាព។

- ក្រុមប្រឹក្សា មានសិទ្ធិទទួលបានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីអនុវត្តមុខងាររបស់ខ្លួន បំពេញភារកិច្ចតាមផ្លូវច្បាប់ ទូទាត់ការចំណាយផ្នែករដ្ឋបាល និងអនុវត្តភារកិច្ច និងមុខងាររបស់ខ្លួនទៅតាមរបៀបដែលជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

- ក្រុមប្រឹក្សា មានប្រភពចំណូលបីគឺ ចំណូលផ្ទាល់ខ្លួននៅមូលដ្ឋាន (រួមមាន ពន្ធ កម្រៃ និងឈ្នួលនៅមូលដ្ឋាន) ចំណូលពីថ្នាក់ជាតិ (រួមមានការចែករំលែកចំណូលជាតិ និងការផ្ទេរពីថ្នាក់ជាតិ) និងចំណូលផ្សេងទៀត។

- ចំណូលមួយចំនួនរបស់ក្រុមប្រឹក្សា ត្រូវបានបម្រុងដោយឡែកសម្រាប់គោលបំណងជាក់លាក់ (ដូចជា ដើម្បីអនុវត្តមុខងារជាកាតព្វកិច្ច)។ ទោះជាយ៉ាងណាក៏ដោយ ចំណូលមួយចំនួនរបស់ក្រុមប្រឹក្សា គឺជាចំណូលតាមឆន្ទានុសិទ្ធិដែលក្រុមប្រឹក្សា អាចចំណាយទៅតាមការយល់ឃើញរបស់ខ្លួនថាជាការសមស្រប។

- ជាមួយនឹងកំណើនចំណូល និងជាមួយនឹងចំណូលឆន្ទានុសិទ្ធិ ជាការសំខាន់ដែលក្រុមប្រឹក្សា ត្រូវមានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។

វគ្គទី ៣៖

ធនធានឯកសារ

១. វិមជ្ឈការសារពើពន្ធ៖ គោលការណ៍ ទម្លាប់ និងការអនុវត្តនៅកម្ពុជា វគ្គបណ្តុះបណ្តាលស្តីពីវិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងវិស័យសង្គម សាស្ត្រាចារ្យ រ៉យ ខែលលី (Roy Kelly) ខែឧសភា ឆ្នាំ ២០០៧

វគ្គទី ៤:

ការងារជាក្រុម

ការងារជាក្រុមដែលបានពិពណ៌នាខាងក្រោម អាចមានភាពមិនសមស្របសម្រាប់ការបណ្តុះបណ្តាលទាំងអស់។ សូមចាត់ទុកការងារជាក្រុមខាងក្រោមថាគ្រាន់តែជាសំណូមពរប៉ុណ្ណោះ។

១. ចែងចែកសិក្ខាកាមជាក្រុមដែលមានសមាជិកមិនលើសពី ៨ នាក់។

២. ផ្តល់លំហាត់មួយក្នុងចំណោមលំហាត់ខាងក្រោមដល់ក្រុម៖

លំហាត់ទី ១: សង្កាត់ និងខណ្ឌ

ថវិការបស់ក្រុមប្រឹក្សាខណ្ឌ និងសង្កាត់នៅរាជធានីភ្នំពេញ គឺជាផ្នែកមួយនៃថវិការបស់ក្រុមប្រឹក្សារាជធានីភ្នំ-ពេញ។ ដូចគ្នានេះដែរ ថវិការបស់ក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង គឺជាផ្នែកមួយនៃថវិការបស់ក្រុមប្រឹក្សាក្រុង។ ដូច្នេះ ខណ្ឌ និងសង្កាត់នៅរាជធានីភ្នំពេញ និងនៅក្នុងក្រុង នឹងទទួលថវិការបស់ខ្លួនពីក្រុមប្រឹក្សារាជធានី ឬក្រុង។

ពិភាក្សាសំណួរខាងក្រោម៖

- តើលោក អ្នកគិតថាមានការលំបាកពិតប្រាកដអ្វីខ្លះសម្រាប់ខណ្ឌ និងសង្កាត់ដែលទទួលថវិការបស់ខ្លួនពីក្រុមប្រឹក្សារាជធានីភ្នំពេញ ឬក្រុមប្រឹក្សាក្រុង?
- តើសិទ្ធិអំណាច និងឆន្ទានុសិទ្ធិកម្រិតណាដែលខណ្ឌ និងសង្កាត់នឹងមានលើថវិការបស់ខ្លួន?

លំហាត់ទី ២: ហិរញ្ញវត្ថុ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

ពិភាក្សាសំណួរខាងក្រោម :

- តើយុទ្ធសាស្ត្រជាក់ស្តែងអ្វីខ្លះ ដើម្បីធានាថា ចំណូល និងចំណាយរបស់ក្រុមប្រឹក្សា មានតម្លាភាពចំពោះប្រជាពលរដ្ឋ (*ក្រៅពីការបិទផ្សាយព័ត៌មាននៅលើក្តារខៀន*) ?

- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា ក្រុមប្រឹក្សា ត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីឆ្លើយនឹងតម្រូវការរបស់ស្ត្រី យុវជន កុមារ និងក្រុមងាយរងគ្រោះ ដែលរួមមាន ជនក្រីក្រ និងជនជាតិដើមភាគតិច។ តើវិធីជាក់ស្ដែងអ្វីខ្លះដែលក្រុមប្រឹក្សាអាចធានាថា ហិរញ្ញវត្ថុរបស់ខ្លួន ពិតជាដោះស្រាយតម្រូវការរបស់ក្រុមទាំងនេះ?
- តើលោក អ្នកគិតថាមានឧបសគ្គអ្វីខ្លះ ដើម្បីឱ្យប្រជាពលរដ្ឋធ្វើឱ្យក្រុមប្រឹក្សារបស់ខ្លួនមានគណនេយ្យភាពចំពោះរបៀបចំណាយមូលនិធិសាធារណៈ?
- ដោយគិតពីឧបសគ្គទាំងនេះ តើមានយន្តការអ្វីដែលអាចបង្កើតឡើង ដើម្បីផ្ដល់លទ្ធផលកាន់តែប្រសើរដល់ប្រជាពលរដ្ឋក្នុងការធ្វើឱ្យក្រុមប្រឹក្សារបស់ខ្លួន មានគណនេយ្យភាពចំពោះរបៀបចំណាយមូលនិធិសាធារណៈ?

លំហាត់ទី ៣: ចំណូលផ្ទាល់

របៀបចំសំណើលើប្រភពចំណូលសមស្របសម្រាប់ក្រុមប្រឹក្សាតាមថ្នាក់នីមួយៗ។

ដាក់ចំណាងជើងសម្រាប់ក្រុមប្រឹក្សាដែលបានរាយខាងក្រោម។ សម្រាប់ក្រុមប្រឹក្សានីមួយៗ កំណត់ប្រភពចំណូលដោយឡែកដែលលោក អ្នកគិតថាសមស្របសម្រាប់ក្រុមប្រឹក្សានោះ។ ត្រៀមបកស្រាយជម្រើសរបស់លោក អ្នក។

- ក្រុមប្រឹក្សាឃុំ
- ក្រុមប្រឹក្សាស្រុក
- ក្រុមប្រឹក្សាក្រុង
- ក្រុមប្រឹក្សាខេត្ត
- ក្រុមប្រឹក្សារាជធានីភ្នំពេញ

ឧទាហរណ៍លើលទ្ធភាពមួយចំនួនៈ

កម្រៃ ឬឈ្នួលពីសេវាដែលបានផ្តល់

កម្រៃចំពោះអាជ្ញាប័ណ្ណអាជីវកម្ម

ពន្ធលើដីប្រើប្រាស់

កម្រៃពីការចុះបញ្ជីយានយន្ត

កម្រៃចំណត

ពន្ធលើតម្លៃបន្ថែម

ឈ្នួលពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមប្រឹក្សា

ភាស៊ីផ្សារ

ពន្ធលើដីមិនប្រើប្រាស់

កម្រៃពីការផ្ទេរម្ចាស់កម្មសិទ្ធិដីធ្លី

កម្រៃពីការផ្ទេរម្ចាស់កម្មសិទ្ធិយានយន្ត

ពន្ធលើចំណូល

ឈ្នួលពីការប្រើប្រាស់ធនធានធម្មជាតិ

កម្រៃពីការចុះបញ្ជីអត្រានុកូលដ្ឋាន

Chapter 10
Presentation on the sub-national finance law

គជអប
NCDD
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
The National Committee for Sub-National Democratic Development

បទបង្ហាញ

ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ភ្នំពេញ, ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨

ការបង្កើតរដ្ឋបាលដែលមានសិទ្ធិធ្វើសេចក្ដីសម្រេចចិត្តឱ្យស្ថិតនៅកៀកជិតនឹងប្រជាពលរដ្ឋ
គជអប NCDD
www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

មាតិកា

១. សវតា និងដំណើរការតាក់តែងច្បាប់

២. គោលបំណង និងវិសាលភាពច្បាប់

៣. ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៤. សមត្ថកិច្ចនិងការគ្រប់គ្រងហិរញ្ញវត្ថុ

៥. គោលការណ៍គ្រប់គ្រងថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៦. ថវិកាចំណូលនិងចំណាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៧. ការរៀបចំនិងការអនុម័តថវិកា

៨. ការអនុវត្តនិងការបិទបញ្ជីថវិកា

៩. ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១. សង្ខេបដំណើរការតាក់តែងច្បាប់

- យោងតាមមាត្រាទី ២៤៤ ២៤៥ ២៥៤ និង ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ចេញសេចក្តីព្រាងច្បាប់លើកទី១ ខែធ្នូ ឆ្នាំ២០០៨
- ដំណើរការពិនិត្យ និងពិគ្រោះយោបល់ ដើម្បីបញ្ចប់សេចក្តីព្រាងចាប់ពីខែមករា ឆ្នាំ២០០៩ ដល់ខែមិនា ឆ្នាំ២០១១
- ពិនិត្យនិងអនុម័តដោយរដ្ឋសភា ខែឧសភា ឆ្នាំ២០១១
- អនុម័តជាស្ថាពរដោយព្រឹទ្ធសភា ចុងខែឧសភា ឆ្នាំ២០១១
- ប្រកាសឲ្យប្រើដោយព្រះមហាក្សត្រ ១៧ មិថុនា ២០១១

២. បទប្បញ្ញត្តិទូទៅ

- គោលដៅ: កំណត់ពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- គោលបំណង: បង្កើតនូវប្រភពធនធានហិរញ្ញវត្ថុ ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការអភិវឌ្ឍន៍មូលដ្ឋាន។
- វិសាលភាព: ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះតែរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តែប៉ុណ្ណោះ ។
- កំណត់សម្គាល់: រដ្ឋបាលឃុំ-សង្កាត់ ស្ថិតក្នុងក្របខ័ណ្ឌច្បាប់ដោយឡែកមួយផ្សេងទៀត ហៅថាច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់» ។
- កាគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តគោលការណ៍ជាមូលដ្ឋានដែលមានបញ្ញត្តិក្នុងច្បាប់ស្តីពីប្រព័ន្ធ ហិរញ្ញវត្ថុសាធារណៈ។

៣. ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ថវិការាជធានី ខេត្តៈ អភិបាលរាជធានី ខេត្តជាអាណាប័កនៃថវិការាជធានី ខេត្ត
- ថវិកាក្រុង ស្រុកៈ អភិបាលក្រុង ស្រុកជាអាណាប័កនៃថវិកាក្រុង ស្រុក
- ថវិកាខណ្ឌ សង្កាត់ក្នុងថវិការាជធានីៈ អភិបាលខណ្ឌ ចៅសង្កាត់ ជាអាណាប័កផ្ទេរសិទ្ធិពីអភិបាលរាជធានីចំពោះថវិការបស់ខ្លួន
- ថវិកាសង្កាត់ក្នុងថវិកាក្រុងៈ ចៅសង្កាត់ ជាអាណាប័កផ្ទេរសិទ្ធិពីអភិបាលក្រុងចំពោះថវិការបស់ខ្លួន

៤. សមត្ថកិច្ចនិងការគ្រប់គ្រងហិរញ្ញវត្ថុ

ក្រុមប្រឹក្សា៖

- ក្រុមប្រឹក្សាត្រូវគ្រប់គ្រង និងចាត់ចែងកិច្ចការហិរញ្ញវត្ថុសារធារណៈឲមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងរាជរដ្ឋាភិបាល។
- ពិនិត្យនិងអនុម័ត ផែនការអភិវឌ្ឍ៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរកិលក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ផែនការយុទ្ធសាស្ត្រថវិកាគម្រោងថវិកាប្រចាំឆ្នាំ ការកែសម្រួលថវិកា របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។
- តាមដានត្រួតពិនិត្យការអនុវត្តហិរញ្ញវត្ថុនិងថវិការបស់អភិបាល

៤. សមត្ថកិច្ចនិងការគ្រប់គ្រងហិរញ្ញវត្ថុ (ត)

អភិបាល៖

- តំណាងឲស្ថាប័ន និងជាអ្នកប្រតិបត្តិផ្ទាល់តាមដីកានិងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។
- ក្នុងនាមក្រុមប្រឹក្សាជាអាណាប័កដើមខ្សែបញ្ជាចំណាយនិងចំណូល
- រៀបចំផែនការអភិវឌ្ឍ៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ផែនការយុទ្ធសាស្រ្តថវិកា គម្រោងថវិកាប្រចាំឆ្នាំ ការកែសម្រួលថវិកា របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។
- តាមដានត្រួតពិនិត្យការអនុវត្តហិរញ្ញវត្ថុនិងថវិកាប្រចាំឆ្នាំ
- គ្រប់គ្រងធនធាននិងទ្រព្យសម្បត្តិ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

៤. សមត្ថកិច្ចនិងការគ្រប់គ្រងហិរញ្ញវត្ថុ (ត)

ប្រធានហិរញ្ញវត្ថុ៖

- ជួយក្រុមប្រឹក្សា និងគណៈអភិបាលលើកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុ
- បំពេញតួនាទី និងប្រតិបត្តិកិច្ចការហិរញ្ញវត្ថុរបស់ខ្លួន ដោយមានការសម្របសម្រួលពីនាយករដ្ឋបាល និងការសហការជា មួយអង្គភាពនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ទទួលខុសត្រូវក្នុងកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុនៅក្រោមសិទ្ធិអំណាចនៃអភិបាលនៃគណៈអភិបាលរបស់ខ្លួន។

៤. សមត្ថកិច្ចនិងការគ្រប់គ្រងហិរញ្ញវត្ថុ(ត)

<u>រតនាគារខេត្ត</u>

- បំពេញតួនាទីជាគណនេយ្យករសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រមូល ឬទទួលចំណូល របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ទូទាត់ចំណាយ ដែលបានចេញអាណត្តិដោយអភិបាល
- គ្រប់គ្រង និងបើកផ្តល់ថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុតាមកាលកំណត់
- ថែរក្សាទុកដាក់ឯកសារ សក្ខីបត្រ កត់ត្រា និងគ្រប់គ្រងកិច្ចបញ្ជីកាគណនេយ្យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៥. គោលការណ៍គ្រប់គ្រងថវិកា នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- ត្រូវមានសង្គតភាពជាមួយនឹងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ឆ្នាំថវិកាចាប់ផ្តើមពីថ្ងៃទី ១ មករា បញ្ចប់នៅថ្ងៃទី ៣១ ធ្នូ
- គម្រោងថវិកាត្រូវបញ្ចូលចំណូល និងចំណាយទាំងអស់
- រៀបចំតាមទម្រង់និងមាតិកាថវិកាកំណត់ដោយ សហវ
- ចំណូល និងចំណាយទាំងអស់ជាផ្នែកនៃថវិកាឯកភាពតែមួយគត់
- ចំណូលត្រូវប្រមូល បង្ហាញជាទឹកប្រាក់សរុប (គ្មានកាត់កងចំណាយ)
- គ្មានចំណូលណាមួយ ប្រើសម្រាប់ចំណាយជាក់លាក់ណាមួយឡើយ
- ថវិកាត្រូវមានតុល្យភាពរវាងចំណូលនិងចំណាយ
- គ្មានចំណូល ឬចំណាយណាមួយ អនុវត្តនៅក្រៅប្រព័ន្ធថវិកាឡើយ
- ត្រូវផ្សព្វផ្សាយព័ត៌មាននៃការរៀបចំនិងអនុម័តថវិកា
- រដ្ឋបាលថ្នាក់ក្រោមជាតិ គ្មានសិទ្ធិខ្ចីបុល និងធានាខ្ចីឡើយ។

៦. ចំណូលនិងចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

<u>ចំណូល រួមមាន៖</u>

- ចំណូលពីប្រភពនៅមូលដ្ឋាន (សារពើពន្ធ និងមិនមែនសារពើពន្ធ)
- ចំណូលពីថ្នាក់ជាតិ
- ចំណូលផ្សេងៗទៀត ដែលកំណត់ដោយច្បាប់

<u>ចំណាយ រួមមាន៖</u>

- ចំណាយប្រតិបត្តិការរដ្ឋបាល
- ចំណាយក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច
- ចំណាយក្នុងការអនុវត្តមុខងារជាជម្រើស និង
- ចំណាយក្នុងការអនុវត្តតួនាទី និងភារកិច្ចផ្សេងៗទៀតដែលកំណត់ដោយច្បាប់

៦. ចំណូលនិងចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ត)

ចំណូលពីថ្នាក់ជាតិ

- ចំណូលចែករំលែក
- មូលនិធិផ្ទេរពីថ្នាក់ជាតិៈ មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌៈ (មូលនិធិក្រុង ស្រុក) លនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ (ធនធានតាមការផ្ទេរមុខងារពីក្រសួងស្ថប័នទៅឲដល់រដ្ឋបាលថ្នាក់ក្រោមជាតិ)
- ថ្លៃសេវាបានពីមុខងារជាភ្នាក់ងារដែលអនុវត្តដោយក្រុមប្រឹក្សា ក្នុងនាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល

៧. ការរៀបចំ និងការអនុម័តថវិកា

ជំហាន	សកម្មភាព	កាលវិភាគ
ផែនការយុទ្ធសាស្ត្រថវិកា	•សហវ: ចេញសារាចរណែនាំពីផែនការយុទ្ធសាស្ត្រថវិកា •ក្រសួងនានា: ណែនាំទៅមន្ទីរជំនាញតាមខេត្ត •អភិបាល: រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកា •ក្រុមប្រឹក្សា: ប្រជុំពិនិត្យនិងអនុម័ត •ផែនការយុទ្ធសាស្ត្រថវិកា ត្រូវផ្ញើជូនមន្ទីរ សហវ ដើម្បីបូកសរុបផ្ញើមក សហវ យឺតបំផុតត្រឹមថ្ងៃទី១៥ ឧសភា	១ មិនា ដល់ ១៥ ឧសភា
រៀបចំកញ្ចប់គម្រោងថវិកា	•សហវ: ចេញសារាចរណែនាំពីការរៀបចំថវិកា •អភិបាល: រៀបចំគម្រោងពង្រាងថវិកា •ក្រុមប្រឹក្សា: ពិនិត្យ និងអនុម័តពង្រាងថវិកា •មន្ទីរ សហវ: បូកសរុបពង្រាងថវិកា និងផ្ញើមក សហវ	១ មិថុនា ដល់១៥ កក្កដា

៧. ការរៀបចំ និងការអនុម័តថវិកា (ត)

ជំហាន	សកម្មភាព	កាលវិភាគ
ការពិនិត្យនីត្យានុកូលភាព	•សហវ ឬប្រតិភូកម្ម: ដំណើរការពិនិតនីត្យានុកូលភាព •ពិនិត្យកែសម្រួល និងជូនដំណឹងជាលាយលក្ខណ៍ទៅអភិបាលដើម្បីរៀបចំកែសម្រួលឡើងវិញ។	១ ដល់ ៣១ សីហា
ការអនុម័តថវិកា	•សហវ: បូកសរុបនិងបញ្ចូលជាជំពូកមួយក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ •រដ្ឋសភាជាតិ: ពិនិត្យ និងអនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ •ព្រឹទ្ធសភា: អនុម័តជាស្ថាពរ។	១ តុលា ដល់ ២៥ ធ្នូ

៨. ការអនុវត្តនិងការបិទបញ្ជីថវិកា

ការអនុវត្តថវិកា:

- រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបើកគណនីប្រាក់បញ្ញើនៅរតនាគារខេត្ត
- ថវិកាអាចធ្វើការកែតម្រូវបាន នៅក្នុងឆ្នាំថវិកានីមួយៗ
- ចលនាឥណទានផ្ទៃក្នុងធ្វើឡើងក្នុងលក្ខខណ្ឌកំណត់ដោយប្រកាសសហវ
- គម្រោងឬកម្មវិធីអនុវត្តមិនទាន់ចប់ក្នុងឆ្នាំថវិកាត្រូវបន្តអនុវត្តដោយបញ្ចូលក្នុងគម្រោងចំណាយថវិកានៅឆ្នាំបន្ទាប់។
- មិនអនុញ្ញាតឲមានឱនភាព ក្នុងការអនុវត្តថវិកាឡើយ
- ករណីមានចំណូលជាក់ស្តែងលើសពីគម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ អាចបង្កើនឥណទានចំណាយ ឬធ្វើនិយ័តកម្មជាគុណ ប្រយោជន៍ដល់ថវិការបស់ខ្លួនតាមរយៈប្រកាសសហវ។
- អតិរេកថវិកាថ្នាក់ក្រោមជាតិត្រូវកត់ត្រាចូលគណនីលទ្ធផលរតនាគារជាតិ

៨. ការអនុវត្តនិងការបិទបញ្ជីថវិកា(ត)

<u>ការបិទបញ្ជីថវិកា:</u>

- រតនាគារខេត្តរៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុ
- រដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា (គណនេយ្យថវិកា)។
- អភិបាល ផ្ញើការផ្ទៀងផ្ទាត់គណនេយ្យថវិកា និងគណនេយ្យហិរញ្ញវត្ថុ និងរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា
- ក្រុមប្រឹក្សា ពិនិត្យ និងអនុម័តរបាយការណ៍ស្តីពីការអនុវត្តថវិកា
- អតិរេកថវិកាដំណាច់ឆ្នាំ កត់ត្រាចូលគណនីលទ្ធផលរតនាគារជាតិ
- មន្ទីរ សហវ បូកសរុបរបាយការណ៍ និងផ្ញើជូនទៅ សហវ
- សហវ បូកសរុបនិងរៀបចំសេចក្តីព្រាងទូទាត់ថវិកាថ្នាក់ក្រោមជាតិ ជាជំពូកមួយក្នុងសេចក្តីព្រាងទូទាត់ថវិកាទូទៅរបស់រដ្ឋ
- រដ្ឋសភា និងព្រឹទ្ធសភា ពិនិត្យ និងអនុម័ត ។

៩. ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឲ្យ និងទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង
- ការផ្ទេរទ្រព្យសម្បត្តិពីថ្នាក់ជាតិត្រូវស្របតាមមុខងារដែលបានផ្ទេរឲទៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។
- រដ្ឋបាលថ្នាក់ក្រោមជាតិ អាចថែរក្សា គ្រប់គ្រង ប្រើប្រាស់ និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឲទាំងនេះ។
- រដ្ឋបាលថ្នាក់ក្រោមជាតិ គ្មានសិទ្ធិលក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ ដោយគ្មានការយល់ព្រមពីរដ្ឋមន្ត្រី សហការ នឹងការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឡើយ។
- ទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯងខ្លួនមានសិទ្ធិស្វយសម្រេចក្នុងការគ្រប់គ្រង និងប្រើប្រាស់ដើម្បីទាញ យកផលចំណូលពីទ្រព្យសម្បត្តិទាំងនេះ តែត្រូវកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត។

អរគុណ!

Chapter 11

Introduction to local budget scrutiny

ការពិនិត្យ
ពិច័យថវិកា
ថ្នាក់មូលដ្ឋាន

គោលបំណង

ការពិនិត្យពិច័យថវិកាតើសម្រាប់អ្វី?

ការពិនិត្យពិច័យថវិកានៅថ្នាក់មូលដ្ឋាន មានគោលបំណងជាច្រើន៖

- ពិនិត្យឡើងវិញលើប្រសិទ្ធភាព និងប្រសិទ្ធផលហិរញ្ញវត្ថុ (ពោលគឺ តម្លៃសម្រាប់លុយ) នៃសេវាកម្មដែលផ្តល់ដោយក្រុមប្រឹក្សា និងក្នុងនាមក្រុមប្រឹក្សា។
- ត្រួតពិនិត្យតាមដាននិងពិនិត្យឡើងវិញលើវឌ្ឍនភាពនៃផែនការប្រចាំឆ្នាំ ឬផែនការយុទ្ធសាស្ត្រ
- ធ្វើការរួមគ្នាជាមួយអភិបាល គណៈអភិបាល ប្រធានផ្នែកសេវាកម្ម និងដៃគូក្រុមប្រឹក្សាខាងក្រៅ ដើម្បីកំណត់និងបង្កើតជម្រើសគោលនយោបាយរូបីសម្រាប់ពិចារណាដោយគណៈអភិបាល និងកិច្ចប្រជុំក្រុមប្រឹក្សា ទាក់ទងទៅនឹង
  - ការកំណត់ថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា
  - ការប្រើធនធានសារពើពន្ធ និងទ្រព្យសម្បត្តិរបស់ក្រុមប្រឹក្សា
  - ការកំណត់ពីចំណូល និងឱកាសរកប្រាក់ចំណូល
  - បង្កើនជាអតិបរមានូវប្រសិទ្ធភាពនៃទ្រព្យសម្បត្តិរបស់ក្រុមប្រឹក្សា។

តើការពិនិត្យពិច័យថវិកានៅមូលដ្ឋានមានគោលបំណងអ្វី?

ធ្វើការចោទសួររដ្ឋបាល

- ការពិនិត្យពិច័យថវិកាអាចចោទសួរថាតើដំណើរការរៀបចំថវិកាមានប្រសិទ្ធភាព និងអាចធ្វើការពិនិត្យមើលបានដែរឬទេ (មជ្ឈមណ្ឌលសម្រាប់ការពិនិត្យពិច័យសាធារណៈ ឆ្នាំ 2012)។ វាគឺជាដំណើរការមួយ ដែលសមាជិកក្រុមប្រឹក្សាធ្វើការចោទសួរអំពីការគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋាន និងចោទសួរថ្នាក់ដឹកនាំរបស់រដ្ឋបាល ថាតើថវិកាត្រូវបានចំណាយយោងទៅតាមគោលដៅរួមរបស់រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន ឬទេ។

- ការពិនិត្យពិច័យអាចធ្វើការចោទសួរអំពីនៃរបៀបនៃការបែងចែកធនធាន ពិនិត្យតាមដានមើលរបៀបនៃការប្រើប្រាស់ធនធានទាំងនេះ នឹងពិនិត្យមើលផលប៉ះពាល់របស់វា។ តើការរៀបចំផែនការរបស់ស្ថាប័ន ត្រូវបានផ្សារភ្ជាប់ទៅនឹងការរៀបចំផែនការសេវាកម្មឬទេ ហើយតើការគ្រប់គ្រងគុណផលការងារ ត្រូវបានផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងហិរញ្ញវត្ថុដែរឬទេ? ការពិនិត្យពិច័យអាចធ្វើតេស្ត និងបង្ហាញច្បាស់ថា តើក្រុមប្រឹក្សាកំពុងប្រើថវិការបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបតាមអាទិភាពរបស់ខ្លួនឬទេ ហើយបង្ហាញថាតើក្រុមប្រឹក្សាកំពុងសម្រេចបានតម្លៃសម្រាប់ប្រាក់ដែរឬទេ។

- ការពិនិត្យពិច័យផ្តល់នូវឱកាសសាកសួរបន្ថែមនិងប្រកបដោយតម្លាភាព ចំពោះថ្នាក់ដឹកនាំផ្នែកប្រតិបត្តិនៃហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា។

តើសមាជិកក្រុមប្រឹក្សាមានសមត្ថភាពអ្វីខ្លះ?

ការពិនិត្យពិច័យនៅថ្នាក់មូលដ្ឋាន តម្រូវឱ្យសមាជិកក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន៖

- ដឹងអំពីស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់មូលដ្ឋានរបស់ពួកគេ។
- មានសមត្ថភាពអាននិងយល់ថវិការបស់ពួកគេ និងគណនីដែលបិទសម្រាប់វិភាគ
- យល់ថា ការពិនិត្យពិច័យថវិកាគឺជាឧបករណ៍សិក្សាមួយដើម្បីទទួលបានគុណផលកាន់តែប្រសើរថែមទៀត។
- ការពិនិត្យពិច័យនេះមិនត្រូវបានប្រើប្រាស់ជាឧបករណ៍នយោបាយនោះទេ។ ដូច្នេះ ការពិនិត្យពិច័យត្រូវតែគ្មានការពាក់ព័ន្ធនឹងនយោបាយ។

គោលការណ៍ទូទៅ

គុណតម្លៃនៃការពិនិត្យពិច័យថវិកា

សមាជិកនិងមន្ត្រីដែលជាប់ឆ្នោតទាំងអស់ ត្រូវតែទទួលស្គាល់សារៈសំខាន់ និងគុណតម្លៃនៃការពិនិត្យពិច័យថវិកានៅក្នុងការកែលម្អសេវាសម្រាប់ប្រជាពលរដ្ឋ និងស្ថាប័ន។ ភាពឯករាជ្យនៃការពិនិត្យពិច័យ ត្រូវតែបញ្ជាក់ឱ្យច្បាស់ និងការពារឱ្យបាន ប្រកបដោយភាពស្ថាបនា និងវិជ្ជមាន។

គោលការណ៍

- ភាពគ្រប់គ្រាន់ – តើធនធានមានគ្រប់គ្រាន់ដើម្បីអនុវត្តផែនការ និងមានតុល្យភាពសមស្របឬទេ ?
- ការកំណត់អាទិភាព – តើការបែងចែកការវិភាជរវាងគម្រោង កម្មវិធី និងវិស័យនានា មានលក្ខណៈហេតុផលសមស្រប និងមានសង្គតិភាពឬទេ ហើយតើការវិភាជទាំងនេះស្របតាមគោលបំណងជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលឬទេ ?
- តម្លៃសម្រាប់ប្រាក់ – តើថវិកាសាធារណៈត្រូវបានប្រើប្រាស់ដោយសមស្របឬទេ ពោលគឺសម្រាប់ធនធានដែលដាក់ចូល តើធាតុចេញនិងលទ្ធផលរំពឹងទុកកំពុងតែសម្រេចបានឬទេ ហើយតើវាមានភាពសន្សំសន្ស៊ំ ប្រសិទ្ធផល និងប្រសិទ្ធភាពឬទេ ?
- ដំណើរការ – តើដំណើរការថវិកាមានប្រសិទ្ធភាព និងអាចអនុវត្តបានឬទេ ហើយតើមានការប្រចាប់បញ្ចូលគ្នារវាងការរៀបចំផែនការនិងគុណផលរបស់រដ្ឋាភិបាលនិងក្រសួង និងការគ្រប់គ្រងហិរញ្ញវត្ថុ ដែរឬទេ ?

អត្ថប្រយោជន៍
នៃការពិនិត្យពិច័យថវិកានៅថ្នាក់មូលដ្ឋាន

លទ្ធផលនៃការពិនិត្យពិច័យថវិកានៅថ្នាក់មូលដ្ឋាន ប៉ះពាល់ដល់អ្នកធ្វើការសម្រេចចិត្ត ក៏ដូចជាមន្ត្រីនៃអង្គភាពពាក់ព័ន្ធនីមួយៗដែរ។ លទ្ធផលនៃការពិនិត្យពិច័យថវិកានៅថ្នាក់មូលដ្ឋានត្រូវមានលទ្ធផលដូចខាងក្រោម៖

- សមាជិកក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន រៀនប្រើការពិនិត្យពិច័យថវិកាដើម្បីតម្រែតម្រង់ទិសដៅសុទ្ធសាស្ត្រឡើងវិញនៅក្នុងការផលិត និងផ្តល់សេវា និងរៀនពីរបៀបប្រើការពិនិត្យពិច័យថវិកានៅថ្នាក់មូលដ្ឋានជាឧបករណ៍សិក្សារួមគ្នាមួយសម្រាប់ទាំងសមាជិកក្រុមប្រឹក្សា និងមន្ត្រីរបស់រដ្ឋបាលថ្នាក់មូលដ្ឋាន។
- សមាជិកក្រុមប្រឹក្សាមូលដ្ឋានត្រូវបានផ្តល់ឱកាសតាមរយៈដំណើរការពិនិត្យពិច័យដើម្បីស្វែងយល់កាន់តែច្បាស់ និងវិភាគព័ត៌មានហិរញ្ញវត្ថុ ហើយ មន្ត្រីថ្នាក់មូលដ្ឋានសិក្សាពីរបៀបបង្ហាញព័ត៌មានហិរញ្ញវត្ថុ ដល់អ្នកធ្វើការសម្រេចចិត្ត។
- សមាជិកក្រុមប្រឹក្សាថ្នាក់មូលដ្ឋានត្រូវបានផ្តល់ឱកាសតាមរយៈដំណើរការពិនិត្យពិច័យដើម្បីពិចារណាឡើងវិញនូវការសន្មតទូទៅ យុទ្ធសាស្ត្រ និងគោលបំណងនៃការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ថវិកាតាមរយៈការចំណាយសាធារណៈថ្នាក់មូលដ្ឋាន។

តើអ្នកណាជាអ្នកធ្វើការពិនិត្យពិច័យ?
ភាគីពាក់ព័ន្ធ

- សមាជិកក្រុមប្រឹក្សា៖
  សមាជិកក្រុមប្រឹក្សាដែលមានសមត្ថកិច្ច គឺជាគន្លឹះចំពោះប្រសិទ្ធភាពនៃការពិនិត្យពិច័យថវិកាថ្នាក់មូលដ្ឋាន។ ពួកគេត្រូវតែធ្វើការចោទសួររដ្ឋបាលថ្នាក់មូលដ្ឋាន។

- ប្រធានសេវាកម្ម៖
  ប្រធានសេវាកម្មនៅក្នុងរដ្ឋបាលថ្នាក់មូលដ្ឋាន ទទួលខុសត្រូវក្នុងការពន្យល់ពីហេតុផលនៃការបង្កើត និងផ្តល់សេវានៅថ្នាក់មូលដ្ឋានរបស់ពួកគេ។

- អ្នកទទួលផល៖
  នៅក្នុងដំណើរការពិនិត្យពិច័យថវិកានៅថ្នាក់មូលដ្ឋាន អ្នកទទួលផលនៃសេវានៅថ្នាក់មូលដ្ឋាន អាចត្រូវបានធ្វើអង្កេតស្ទង់មតិ (អតិថិជន ប្រជាពលរដ្ឋ) ដើម្បីស្វែងយល់ទស្សនៈរបស់ពួកគេអំពីប្រសិទ្ធផលនិងប្រសិទ្ធភាពនៃការផ្តល់សេវានៅថ្នាក់មូលដ្ឋាន។

ប្រធានបទនៃការពិនិត្យពិច័យ

ធាតុចូល ដំណើរការ ធាតុចេញ និងលទ្ធផលរំពឹងទុក

- ធាតុចូល៖ ធនធានដែលត្រូវបានប្រើក្នុងការផ្តល់សេវា ដូចជាការចំណាយផ្នែកហិរញ្ញវត្ថុនិងបុគ្គលិក សម្រាប់អត្ថប្រយោជន៍លំនៅស្ថានជារៀងរាល់ឆ្នាំ។ ក្នុងន័យតម្លៃសម្រាប់ប្រាក់ សេវាកម្មមួយដែលដំណើរការដើម្បីកាត់បន្ថយធនធានដែលត្រូវការ ត្រូវបានចាត់ទុកថាជាសេដ្ឋកិច្ចក្នុងការប្រើប្រាស់ធនធាន។
- ដំណើរការ៖ អភិក្រមដែលអង្គការ/ស្ថាប័នមួយអនុវត្តផ្អែកលើធនធានហិរញ្ញវត្ថុ និងបុគ្គលិកដែលមាន ដើម្បីផ្តល់សេវាជូនអតិថិជន។ នៅក្នុងន័យតម្លៃសម្រាប់ប្រាក់ សេវាកម្មមួយដែលប្រើប្រាស់យ៉ាងល្អបំផុតនូវធាតុចូលដែលស្ថាប័ននោះមាន នៅក្នុងការផ្តល់សេវាដែលមានគុណភាពខ្ពស់ ត្រូវបានចាត់ទុកថាមានប្រសិទ្ធភាពនៅក្នុងការប្រើប្រាស់ធនធានរបស់ស្ថាប័ន។

ប្រធានបទនៃការពិនិត្យពិច័យ
ធាតុចូល ដំណើរការ ធាតុចេញ និងលទ្ធផលរំពឹងទុក

- ធាតុចេញ៖ គឺជាសេវាកម្មដែលត្រូវបានផ្តល់ ជាលទ្ធផលនៃធាតុចូល និងដំណើរការរបស់ក្រុមប្រឹក្សា ឧទាហរណ៍ ដូចជាចំនួនអតិថិជនដែលទទួលបានការទូទាត់អត្ថប្រយោជន៍សម្រាប់លំនៅស្ថានរបស់ពួកគេ តាមការផែនការក្នុងខែនីមួយៗ។
- លទ្ធផលរំពឹងទុក៖ គឺជាភាពប្រសើរឡើងនៃគុណភាពជីវិតរបស់អ្នករស់នៅក្នុងសហគមន៍ ដោយសារតែធាតុចេញដែលបានផ្តល់ដោយក្រុមប្រឹក្សា ដូចជាការកាត់បន្ថយភាពក្រីក្រ ដែលជាលទ្ធផលនៃការផ្តល់ប្រាក់អត្ថប្រយោជន៍លំនៅស្ថាន ដល់អ្នកដែលខ្វះខាត។

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់មូលដ្ឋាន

ការងារជាក្រុម

ក្រដាសកិច្ចការ ០១

ព័ត៌មានហិរញ្ញវត្ថុ

កិច្ចការហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា - តើនរណាខ្លះចាប់អារម្មណ៍ចង់ដឹង ?

ចូររៀបរាប់តើនរណាខ្លះ ដែលអ្នកគិតថា អាចមានបំណងចង់ដឹងអំពីកិច្ចការហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សារបស់អ្នក ហើយហេតុអ្វី ?

តើនរណាខ្លះត្រូវដឹង ? ហេតុអ្វី ?

____

____

តើនរណាខ្លះអាចត្រូវដឹងដែរ ? ហេតុអ្វី ?

____

____

តើនរណាខ្លះអាចចង់ដឹង ? ហេតុអ្វី ?

____

____

សូមឆ្លើយនឹងសំណួរខាងលើ ហើយព័ត៌មានហិរញ្ញវត្ថុដែលមានបច្ចុប្បន្ននៅក្នុងស្រុករបស់អ្នក ត្រូវគ្នានឹងការអនុវត្តជាក់ស្តែង ដែរឬទេ។ បើសិនជាមិនដូចគ្នាទេ សូមពិភាក្សាពីវិធានការសមស្របដើម្បីធានាការទទួលបានព័ត៌មានហិរញ្ញវត្ថុកាន់តែច្រើនថែមទៀត។

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់មូលដ្ឋាន

ការងារជាក្រុម

ក្រដាសកិច្ចការ ០២

ព័ត៌មានហិរញ្ញវត្ថុដែលងាយយល់

កិច្ចការហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា និងអ្នក ក្នុងតួនាទីរបស់អ្នកជាសមាជិកក្រុមប្រឹក្សាស្រុកៈ

(១) តើអ្នកទទួលបានព័ត៌មានហិរញ្ញវត្ថុអ្វីខ្លះ?

សូមរៀបរាប់អំពីឯកសារសំខាន់ៗដែលអ្នកទទួលបាន!

(២) តើអ្នកទទួលបានព័ត៌មានហិរញ្ញវត្ថុនេះនៅពេលណា?

សូមបញ្ជាក់តើអ្នកទទួលបានព័ត៌មានហិរញ្ញវត្ថុទាំងនេះ (ដូចរៀបរាប់នៅក្នុងសំណួរទី១) នៅពេលណា។

(៣) តើអ្នកយល់ថា អ្នកទទួលបានព័ត៌មានហិរញ្ញវត្ថុ ទាន់ពេលវេលាឬទេ?

សូមបង្ហាញថាតើបន្ទាប់ពីបានទទួលព័ត៌មានហិរញ្ញវត្ថុ អ្នកមានពេលវេលាគ្រប់គ្រាន់ដើម្បីអាន និងរៀបចំឬទេ?

(៤) តើអ្នកយល់ឃើញថា ព័ត៌មានហិរញ្ញវត្ថុដែលអ្នកទទួលបាន មានភាពងាយស្រួលយល់ឬទេ?

សូមបញ្ជាក់ថាតើព័ត៌មានហិរញ្ញវត្ថុដែលអ្នកទទួលបាន ត្រូវបានសរសេរជាភាសាខ្មែរសាមញ្ញ ហើយថាតើអ្នកយល់ឃើញថា ព័ត៌មានហិរញ្ញវត្ថុងាយស្រួលយល់ឬទេ។ ប្រសិនបើមិនដូច្នោះ សូមបញ្ជាក់តើមានមធ្យោបាយអ្វីខ្លះដែលនឹងជួយអ្នកអាន និងយល់ព័ត៌មានហិរញ្ញវត្ថុទាំងនេះ?

____

____

____

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្នាក់មូលដ្ឋាន

ការងារជាក្រុម

ក្រដាសកិច្ចការ ០៣

ការវិភាគថវិការបស់រដ្ឋបាលស្រុក – ការចំណាយ

រដ្ឋបាលមូលដ្ឋានដាក់ជូនអ្នក នូវផែនការចំណាយសម្រាប់ឆ្នាំកន្លងមក។ របាយការណ៍នេះរួមមានថវិកាសម្រាប់ខ្ទង់ចំណាយនីមួយៗតាមផែនការនៅក្នុងអំឡុងដំណើរការថវិកា ក៏ដូចជាការបង្កើន និងការកាត់បន្ថយដែលបានធ្វើឡើងក្នុងអំឡុងឆ្នាំនោះ ព្រមទាំងការចំណាយជាក់ស្តែង។

(១) សូមពិនិត្យមើលជំពូកទី ៦០ ដែលជាផ្នែកមួយនៃការចំណាយ និងការស្វែងរកខ្ទង់ថវិកាលេខ ៦០០៦១។ ខ្ទង់ថវិកានេះសង្ខេបការចំណាយទាំងអស់ដែលបានគ្រោងឡើងសម្រាប់អគ្គិសនី។

សូមមើលករណីទាំងឡាយខាងក្រោម៖ ថវិកាសម្រាប់អគ្គិសនីត្រូវបានគ្រោងឡើងចំនួន ៥លាន ហើយនៅចុងឆ្នាំ រដ្ឋបាលបានចំណាយតែ ៤ លាន ប៉ុណ្ណោះ។

តើសំណួរអ្វីខ្លះដែលអ្នកគួរលើកឡើង ដើម្បីយល់ពីថវិកាដែលនៅសល់ចំនួនមួយលាន?

____

____

____

____

____

____

(២) សូមមើលមើលជំពូកទី ៦០ ម្តង់ទៀត។ ខ្ទង់ថវិកាលេខ ០៦៦៥១ សង្ខេបការចំណាយទាំងអស់ស្រាប់សម្ភារ និងឧបករណ៍បច្ចេកទេស។

ចូរពិនិត្យមើលករណីដូចខាងក្រោម៖ ថវិកាសម្រាប់សម្ភារនិងឧបករណ៍បច្ចេកទេសត្រូវបានគ្រោងឡើងមានចំនួន ២ លាន។ ក្នុងឆ្នាំនោះ ថវិកានេះត្រូវបានបង្កើនចំនួន ៤លាន ដូច្នេះ ការចំណាយសរុបដែលអនុញ្ញាត គឺ ៦ លាន។ របាយការណ៍ចំណាយបង្ហាញថា ថវិកាចំនួន ៦លានគត់ ត្រូវបានចំណាយនៅចុងឆ្នាំ។

តើសំណួរអ្វីខ្លះដែលអ្នកគួរសួរ ដើម្បីយល់ពីការកើនឡើងយ៉ាងខ្លាំងនូវវិបត្តិកាបូនលាននេះ?

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្នាក់មូលដ្ឋាន

ការងារជាក្រុម

ក្រដាសកិច្ចការ ០៤

ការវិភាគថវិការបស់រដ្ឋបាលស្រុក – ចំណូល

រដ្ឋបាលមូលដ្ឋានដាក់ជូនអ្នក នូវផែនការចំណូលនៃឆ្នាំកន្លងមក។ របាយការណ៍នេះមានថវិកាចំណូលដែលបានគ្រោងឡើងសម្រាប់ឆ្នាំនោះ និងខ្ទង់ចំណូលនីមួយៗនៅក្នុងដំណើរការថវិកា ក៏ដូចជាការបង្កើន និងការកាត់បន្ថយដែលបានធ្វើឡើងនៅក្នុងឆ្នាំនោះ ហើយចុងក្រោយគឺ ចំណូលជាក់ស្តែង។

(១) សូមមើលជំពូកទី៧៣ ដែលជាផ្នែកមួយនៃចំណូល និងការស្វែងរកខ្ទង់ថវិកាលេខ ៧៣០២៨ ។ ខ្ទង់ថវិកានេះ សង្ខេបរាល់ចំណូលទាំងអស់ពីថ្លៃសេវារដ្ឋបាល។

សូមមើលករណីខាងក្រោមនេះ៖ ថវិកាត្រូវបានគ្រោងឡើងចំនួន ៥០លាន ហើយនៅចុងឆ្នាំ រដ្ឋបាលប្រមូលបានតែ ៤,៥ លាន ប៉ុណ្ណោះ។

តើសំណួរអ្វីខ្លះដែលអ្នកគួរសួរ ដើម្បីស្វែងយល់ពីភាពខុសគ្នាខ្លាំងរវាងចំណូលដែលគ្រោងឡើង និងចំណូលជាក់ស្តែង?

(២) សូមពិនិត្យមើលចំណូលពីប្រភពផ្ទាល់របស់ថ្នាក់ស្រុក។ ទាំងនេះគឺជាចំណូលដែលស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុង ឬមួយផ្នែករបស់ក្រុមប្រឹក្សាស្រុក។ ចំណូលទាំងនេះមិនរួមបញ្ចូលចំណូលដែលផ្ទេរមកពីរដ្ឋាភិបាលថ្នាក់ជាតិនោះទេ។ សូមធ្វើការគណនាដូចខាងក្រោម៖

ផលធៀប ORS ជាក់ស្តែង = ចំណូលពីប្រភពផ្ទាល់ជាក់ស្តែង / ថវិកាសរុប

យកចំណូលជាក់ស្តែងពីចំណូលដោយប្រភពផ្ទាល់ ចែកនឹងថវិកាសរុប (ចំណូលជាក់ស្តែងទាំងអស់)។ សូមពិនិត្យមើលករណីដូចខាងក្រោម។ ចំណូលពីប្រភពផ្ទាល់ជាក់ស្តែង គឺ ៥ លាន ហើយថវិកាសរុបនៃចំណូលទាំងអស់ គឺ ៥០០ លាន ។ ដូច្នេះ ផលធៀប OSR គឺ ១% ប៉ុណ្ណោះ ។

តើសំណួរអ្វីខ្លះដែលអ្នកគួរសួរ ដើម្បីស្វែងយល់ពីភាពខុសគ្នានេះ?

____

____

____

____

____

____

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្នាក់មូលដ្ឋាន

ការងារជាក្រុម

ក្រដាសកិច្ចការ ០៥

តារាងគណនី

តារាងគណនីដែលប្រើសម្រាប់ស្ថាប័នសាធារណៈនៅក្នុងប្រទេសកម្ពុជា គឺដូចគ្នាសម្រាប់រដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់។

ដូច្នេះ តារាងគណនីសម្រាប់ថ្នាក់ស្រុក គឺដូចគ្នានឹងតារាងគណនីដែលប្រើនៅថ្នាក់ជាតិដែរ។ ប៉ុន្តែ មានគណនីយ៉ាងច្រើនដែលនៅមិនទាន់ត្រូវបានគេប្រើ ដោយហេតុថាវាមិនពាក់ព័ន្ធនឹងថ្នាក់ស្រុក។ សូមមើលរចនាសម្ព័ន្ធនៃតារាងគណនី។

ជំពូកទី ៦០ គឺសម្រាប់ទិញ មានអនុគណនីចំនួន ៨ (6001 to 6008) ហើយអនុគណនីទាំងនេះមានគណនីលម្អិតបន្ថែមទៀត៖ 6001 មានអនុគណនីប្រាំ 6002 បី, 6003 មួយ, 6004 បួន (ដែលក្នុងនោះ លេខលំដាប់គឺ 60041, 60042, 60043 និង 60048), 6005 ប្រាំ (ដែលក្នុងនោះ លេខលំដាប់គឺ 60051, 60052, 60053, 60054, និង 60058), 6006 មានបី (ដែលក្នុងនោះ លេខលំដាប់ គឺ 60061, 60062, និង 60068), និង 6008, ដែលមិនមានអនុគណនីទេ។

(១) ចូរអានសេចក្តីពណ៌នារបស់គណនីផ្សេងៗ ហើយរាយឈ្មោះគណនីទាំងនោះ ដែលទំនងជាមិនត្រូវបានប្រើនៅថ្នាក់ស្រុក។ ឧទាហរណ៍ ពិចារណាគណនីលេខ 60041 ។

(២) ចូរពិនិត្យមើលជំពូកទី ៦០ ក្រុមគណនីលេខ 6001 «តំហែទាំង សម្ភារ» និងអនុគណនីប្រាំទៀតនៅក្នុងនោះ។ ឧទាហរណ៍ ចូរពិនិត្យមើលអនុគណនីលេខ 60015 — ឥន្ធនៈ និងប្រេងរំអិល ។ ឧបមាថា រដ្ឋបាលស្រុកបានគ្រោងថវិកាចំនួន ៥ លាន ។ តើព័ត៌មានអ្វីខ្លះដែលមានប្រយោជន៍ដើម្បីត្រួតពិនិត្យមើលការចំណាយ?

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្នាក់មូលដ្ឋាន

ការងារជាក្រុម

ក្រដាសកិច្ចការ ០៦

វដ្តថវិកា

រដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ច្បាស់ពីវដ្តថវិកាសម្រាប់រដ្ឋាភិបាលថ្នាក់ក្រោមជាតិនីមួយៗ។ សូមមើលបទបង្ហាញអំពីវដ្តថវិកាសម្រាប់រដ្ឋបាលស្រុកនៅក្នុងប្រទេសកម្ពុជា។

(១) ចូរគូសគម្រោងពេលមួយ បង្ហាញពីពេលវេលាដែលសមាជិកក្រុមប្រឹក្សាគួរត្រូវបានពិគ្រោះយោបល់នៅក្នុងដំណើរការវដ្តថវិកា!

(២) កំណត់ពីចំណុចនីមួយៗនៅក្នុងគម្រោងពេលនោះ តើសមាជិកក្រុមប្រឹក្សាគួរមានតួនាទីអ្វីខ្លះ (ព័ត៌មាន ការពិគ្រោះយោបល់ ឬការសម្រេចចិត្ត)

(៣) កំណត់ពីចំណុចនីមួយៗនៅក្នុងគម្រោងពេលដែលត្រូវការព័ត៌មាន ដែលសមាជិកក្រុមប្រឹក្សាអាចទទួលបានព័ត៌មាននេះ!

Chapter 13

Introduction to public accounting and the chart of accounts

សេចក្ដីផ្ដើមនៃ

គណនេយ្យសាធារណៈ និងតារាងគណនី

តើបទបង្ហាញនេះ និយាយអំពីអ្វី?
ទិដ្ឋភាពរួម

- តើគណនេយ្យសាធារណៈគឺជាអ្វី?
- តើតារាងគណនីគឺជាអ្វី?
- តើសមាជិកក្រុមប្រឹក្សាស្រុក គួរដឹងអ្វីខ្លះអំពីគណនេយ្យសាធារណៈ?

តើគណនីគឺជាអ្វី?
គណនី និង តារាងគណនី

- គណនី (account) គឺជាកំណត់ត្រាមួយនៅក្នុងសៀវភៅធំ (the general ledger) ដែលត្រូវបានប្រើដើម្បីប្រមូល និងរក្សាទុកទឹកប្រាក់ឥណពន្ធ (debit) និង ឥណទាន ។
- តារាងគណនី (chart of accounts) (COA) គឺជាឧបករណ៍ហិរញ្ញវត្ថុដែលផ្តល់ជាបញ្ជីពេញលេញនៃគណនីនីមួយៗនៅក្នុងប្រព័ន្ធគណនេយ្យមួយ។ គណនីគឺជាកំណត់មួយសម្រាប់ប្រភេទនីមួយៗនៃទ្រព្យសកម្ម (asset) បំណុល (liability) ហ៊ុន (equity), ចំណូល (revenue) និង ចំណាយ (expense)។

អតិក្រមចម្បងពីរចំពោះគណនេយ្យ

សាច់ប្រាក់ ធៀបនឹង កំណើន (ACCRUAL)

គណនេយ្យមានទម្រង់ផ្សេងៗជាច្រើន

- ទម្រង់ចម្បងពីរ គឺ៖
  - គណនេយ្យផ្អែកលើសាច់ប្រាក់ និង
  - គណនេយ្យកំណើន
- ទម្រង់ទាំងពីរ មានភាពខុសគ្នា ដែលគេស្គាល់ថាជា
  - គណនេយ្យផ្អែកលើសាច់ប្រាក់កែប្រែ និង
  - គណនេយ្យកំណើនកែប្រែ

តើអ្វីទៅជា គណនេយ្យផ្អែកលើសាច់ប្រាក់?
លក្ខណៈសម្គាល់សំខាន់ៗ

- នៅក្នុងគណនេយ្យសាច់ប្រាក់ ប្រតិបត្តិការត្រូវបានទទួលស្គាល់តែនៅពេលណាសាច់ប្រាក់ដែលពាក់ព័ន្ធត្រូវបានទទួល ឬទូទាត់ ហើយព្រឹត្តិការណ៍សេដ្ឋកិច្ចមិនត្រូវបានរាយការណ៍ ប្រសិនបើគ្មានការប្តូរសាច់ប្រាក់ភ្លាមៗ។
- គេឆ្លៀតឱកាសកេងប្រវ័ញ្ចរដ្ឋាភិបាលដោយសារចំណុចខ្សោយនេះ ដោយពន្យារពេលការបញ្ចេញសាច់ប្រាក់ ឬរុញការទទួលសាច់ប្រាក់ទៅមុខជាបន្តទៀត ជាមធ្យោបាយនៃការបំប៉ោងតុល្យភាពហិរញ្ញវត្ថុដោយចេតនា។
- បន្ថែមពីលើនេះ រដ្ឋាភិបាលដែលអនុវត្តគណនេយ្យសាច់ប្រាក់ ច្រើនតែមិនរក្សាកំណត់ត្រាគ្រប់ជ្រុងជ្រោយនិងបច្ចុប្បន្នអំពីតម្លៃនៃទ្រព្យសម្បត្តិនិងបំណុលរបស់ខ្លួន។ ការធ្វើបែបនេះជួយឱ្យពួកគេផ្ទេរទ្រព្យសម្បត្តិ (ដូចជា សិទ្ធិដីធ្លី ឬរ៉ែ) ឬបំណុល (ដូចជា ប្រាក់សោធន ឬកិច្ចសន្យាភាពជាដៃគូសាធារណៈ-ឯកជន) ចំពោះភាគីទីបីដោយមិនបង្ហាញភាពពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុរបស់ខ្លួនដល់រដ្ឋាភិបាល និងអ្នកបង់ពន្ធ។

គណនេយ្យផ្អែកលើសាច់ប្រាក់

តើគណនេយ្យផ្អែកលើសាច់ប្រាក់មានសារៈប្រយោជន៍សម្រាប់ស្ថាប័នណាខ្លះ?

- គណនេយ្យផ្អែកលើសាច់ប្រាក់គឺជាអភិក្រមដ៏មានសារៈប្រយោជន៍មួយនៅក្នុងគណនេយ្យ ប្រសិនបើ៖
  - គ្មានទ្រព្យសម្បត្តិ
  - គ្មានបំណុល
- ប៉ុន្តែ គណនេយ្យផ្អែកលើសាច់ប្រាក់មិនផ្តល់ព័ត៌មានហិរញ្ញវត្ថុដោយសុក្រឹតទេ
  - ប្រសិនបើស្ថាប័នសាធារណៈមាន ឬប្រើប្រាស់ទ្រព្យសម្បត្តិដែលត្រូវការអតិមូលធន (ពោលគឺ ដីធ្លី គ្រឿងចក្រ និងឧបករណ៍) ដោយហេតុថា គណនេយ្យផ្អែកលើសាច់ប្រាក់មិនបង្ហាញពីការរំលោះទេ។
  - ប្រសិនបើស្ថាប័នសាធារណៈមានបំណងទទួលយកកម្ចីដើម្បីធ្វើការវិនិយោគ។

តារាងគណនី

តារាងគណនី

ក្រុមទី 1 ចំណូលពិត

- នៅក្នុងក្រុមទី ១ មានពីរប្រភេទ៖
  - ប្រភេទទី ១ ចំណូលសារពើពន្ធ និង
  - ប្រភេទទី ២ ចំណូលមិនមែនសារពើពន្ធ
- នៅក្នុងក្រុមទី ២ មានចំណូលប្រភេទទី ៣ ពីលក្ខន្តិកៈ (គ្មានសាច់ប្រាក់)

តារាងគណនី

ចំណូលសារពើពន្ធក្នុងស្រុក

- ជំពូកទី ៧០ រួមបញ្ចូលចំណូលសារពើពន្ធក្នុងស្រុកទាំងអស់
  - 7003 ពន្ធដាក់លាក់លើទំនិញ និងសេវាកម្ម
  - 7004 ពន្ធលើសេវាកម្ម
  - 7005
  - 7006 ពន្ធលើការបោះពុម្ព
  - 7007 ពន្ធលើអចលនទ្រព្យ

ថវិកាការ

ចំណូល

ចំណូលមិនមែនសារពើពន្ធចម្បង

មានព័ត៌មានមិនគ្រប់គ្រាន់អំពីចំណាងជើងចំណូល

- គណនីទាំងនេះនៅតែគ្មានការបំពេញ ដោយសារស្រុកមិនទទួលបានពន្ធណាមួយឡើយ។ ថ្នាក់ស្រុកមិនទទួលបានចំណូលសារពើពន្ធក្នុងស្រុកឡើយ។
- ប្រភពចំណូលតែមួយគត់គឺចំណូលមិនមែនសារពើពន្ធ ហើយនៅទីនេះ គឺចំណូលពីថ្លៃសេវារដ្ឋបាល (មានតែសេវាចក្រចេញចូលតែមួយ ប៉ុណ្ណោះ) សូមមើលគណនីលេខ 73028
- ប្រព័ន្ធគណនេយ្យរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា ចាត់ថ្នាក់ការផ្ទេរពីរដ្ឋាភិបាលថ្នាក់ជាតិទៅរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ក្រោមជំពូកទី 75 - គណនីលេខ 7501 ឧបត្ថម្ភធនពីថ្នាក់ជាតិ។ នេះគឺជាប្រភពចំណូលដ៏សំខាន់បំផុតរបស់ស្រុកនៅក្នុងប្រទេសកម្ពុជា។

តារាងគណនី
ការចំណាយ

- នៅក្នុងក្រុមទី ១ ដែលមានឈ្មោះថា ការចំណាយពិត មានៈ
  - ប្រភេទទី 1: ទំនិញ និងសេវាកម្ម
    - ជំពូកទី 60 ការទិញ/លទ្ធកម្ម
    - ជំពូកទី 61 សេវាកម្ម
    - ជំពូកទី 64 បុគ្គលិក
  - ប្រភេទទី 2: បន្ទុកហិរញ្ញវត្ថុ
    - ជំពូកទី 66

តារាងគណនី
ការចំណាយ

- ប្រភេទទី 3: អន្តរាគមន៍សាធារណៈ
  - ជំពូកទី 62 តាវកាលិកសង្គម
  - ជំពូកទី 65 ថវិកាជំនួយ
- ប្រភេទទី 4: ការចំណាយផ្សេងទៀត
  - ជំពូកទី 63 ពន្ធ និងអាករ
- នៅក្នុងក្រុមទី 2 មានការចំណាយតាមលក្ខខន្តិកៈ និងថវិកាបម្រុងនៅក្នុងប្រភេទពីរ ប្រភេទទី 5 ការចំណាយមិនមែនសាច់ប្រាក់ និងប្រភេទទី 6 ការចំណាយបម្រុង

តារាងគណនី
ការចំណាយ

- ជំពូកទី 67 ការចំណាយលើកលែង
- ជំពូកទី 68 រំលោះ
- ជំពូកទី 60 បម្រុង (Contingency)

តារាងគណនី
ចំណាយមូលធន

- នៅក្នុងក្រុមទី1, មានពីរប្រភេទ
  - ប្រភេទទី 1: ការទូទាត់បំណុល និងបំណុលពាក់ព័ន្ធ
  - ប្រភេទទី 2: ទ្រព្យសកម្ម
    - ជំពូកទី 20 អចលកម្មអរូបី
    - ជំពូកទី 21 អចលកម្មរូបី
    - ជំពូកទី 23 ទ្រព្យសកម្មកំពុងសាងសង់
- នៅក្នុងក្រុមទី 2, មានតែមួយប្រភេទ 6

និន្នាការ ចំណាយ

និន្នាការចំណាយ
របស់រដ្ឋបាលថ្នាក់ស្រុក

- មានការចំណាយយ៉ាងខ្លាំងទៅលើបុគ្គលិករដ្ឋបាល និងការចំណាយពាក់ព័ន្ធផ្សេងទៀត (6402 ដល់ 6406 និងផ្នែក 6407 ដោយគ្មានផ្នែក 64073 ដែលមានចំណងជើងថា « សំណងសម្រាប់សមាជិកក្រុមប្រឹក្សា និងមេឃុំ និងចៅសង្កាត់», ដែលតំណាងឱ្យប្រមាណជាង 65% នៃការចំណាយសរុបរបស់ស្រុក។

- ការចំណាយលើប្រជាធិបតេយ្យ — ការចំណាយសម្រាប់សមាជិកក្រុមប្រឹក្សាតែប៉ុណ្ណោះ (ផ្នែកទី 64073 ដែលមានចំណងជើងថា « សំណងចំពោះសមាជិកក្រុមប្រឹក្សា និងមេឃុំនិងចៅសង្កាត់ »), ដោយគ្មានការចំណាយតូចៗសម្រាប់វិធីផ្សេងៗ (ផ្នែកទី 61104)— តំណាងឱ្យប្រមាណ 18% នៃការចំណាយសរុប។

- សរុបមក ការចំណាយលើបុគ្គលិកនិងតំណាងនយោបាយ តំណាងឱ្យប្រមាណ ៨០% របស់ស្រុក។ ការចំណាយដ៏ច្រើនសន្ធឹកសន្ធាប់នេះធ្វើឱ្យសល់ថវិកាតិចតួចបំផុតសម្រាប់ការផ្តល់សេវា។

និន្នាការនៃការចំណាយ
របស់រដ្ឋបាលថ្នាក់ស្រុក

- ការចំណាយសម្រាប់សេវា (ជំពូកទី 61) តំណាងឱ្យប្រមាណតែ 9% ប៉ុណ្ណោះ។
- ការចំណាយសម្រាប់ទិញ/លទ្ធកម្ម (ជំពូកទី 60) តំណាងឱ្យប្រមាណតែ 3% ប៉ុណ្ណោះ
- ទោះបីជាយ៉ាងណាក្តី មានខ្ទង់ថវិកាជំគួរសមមួយសម្រាប់បម្រុង (ជំពូកទី 69) ដែលមានប្រមាណ 5% នៃថវិកាសរុប ។

ការងារជាក្រុម

ការវិភាគថវិកា

ការងារជាក្រុម

សូមឆ្លើយនឹងសំណួរពីរខាងក្រោម

- ការងារជាក្រុមទី 1:
  ចូរពិនិត្យមើលការចំណាយនៅក្នុងគណនីលេខ 6005 និង 6006!
  - តើព័ត៌មានសំខាន់អ្វីខ្លះដែលប្រធានផ្នែកហិរញ្ញវត្ថុ អាចផ្តល់ដើម្បីបញ្ជាក់ពីហេតុផលនៃការចំណាយតាមគម្រោង?
  - តើសំណើអ្វីខ្លះដែលសមាជិកក្រុមប្រឹក្សា អាចរៀបចំឡើងដើម្បីកាត់បន្ថយចំណាយ?
- ការងារជាក្រុមទី 2:
  ចូរពិនិត្យមើលការចំណាយក្នុងគណនីលេខ 6105!
  - តើព័ត៌មានសំខាន់អ្វីខ្លះដែលប្រធានផ្នែកហិរញ្ញវត្ថុ អាចផ្តល់ដើម្បីបញ្ជាក់ពីហេតុផលនៃការចំណាយតាមគម្រោង?
  - តើព័ត៌មានអ្វីខ្លះដែលសមាជិកក្រុមប្រឹក្សា គួរកត់ត្រាទុក?

Chapter 14

How to retrieve the evidence

ការពិនិត្យពិច័យថវិកានៅថ្នាក់មូលដ្ឋាន

របៀបទទួលបានភ័ស្តុតាង

របៀបទទួលបានព័ត៌មានស្តុតាង

ប្រភេទនៃព័ត៌មាន

- ព័ត៌មានមានបួនប្រភេទសំខាន់ៗ ដែលគួរត្រូវបានប្រើប្រាស់សម្រាប់ដំណើរការពិនិត្យពិច័យថវិកានៅថ្នាក់មូលដ្ឋាន៖

1. ព័ត៌មានហិរញ្ញវត្ថុ ដែលផ្តល់ដោយរដ្ឋបាលស្រុក
2. ព័ត៌មានអំពីសេវាកម្ម ដែលផ្តល់ដោយប្រធានយន្តការ ឬការិយាល័យច្រកចេញចូលតែមួយ និងបុគ្គលិករបស់រដ្ឋបាលស្រុក
3. ព័ត៌មានអំពីប្រជាពលរដ្ឋ ដែលផ្តល់ដោយប្រជាពលរដ្ឋក្នុងមូលដ្ឋាន ម្ចាស់ហាង/តូបអាជីវកម្ម អង្គការសង្គមស៊ីវិល ។ល។
4. ព័ត៌មានប្រៀបធៀប ដូចជា មធ្យមភាគរបស់ស្រុក ស្រុកជិតខាង និងស្រុកដែលមានស្ថានភាពប្រហាក់ប្រហែលគ្នា

តើត្រូវប្រមូលយកឯកសារអ្វីខ្លះ?

ព័ត៌មានហិរញ្ញវត្ថុ

- ព័ត៌មានទាំងនេះរួមមាន៖
  - ថវិកាពីឆ្នាំមុន
  - គម្រោងផែនការចំណូលពីឆ្នាំមុន
  - ផែនការចំណាយពីឆ្នាំមុន
- រៀបរាប់ពីការចំណាយ និង/ឬចំណូលទាំងអស់ដែលបានគ្រោងឡើងសម្រាប់ជំពូកពាក់ព័ន្ធ អនុគណនី ដើម្បីពិនិត្យមើលការផ្លាស់ប្តូរក្នុងរយៈពេលសមស្របមួយ (ជាធម្មតា គឺរយៈពេលបីឆ្នាំជាប់ៗគ្នា)
- អ្នកគួរតែអាចយល់ពីការផ្លាស់ប្តូរទាំងនេះទៅតាមពេលវេលា និងកំណត់ពីការកើនឡើង និងការធ្លាក់ចុះនៃថវិកា ។

តើត្រូវប្រមូលយកព័ត៌មានអ្វីខ្លះ?

ព័ត៌មានអំពីសេវាកម្ម

- ការផ្តល់សេវាគួរតែជាស្នូលនៃសកម្មភាពរបស់ក្រុមប្រឹក្សាស្រុក និងរដ្ឋបាលស្រុក។ ដូច្នេះ ប្រធានផ្នែកសេវាកម្ម ក៏ដូចជា បុគ្គលិកអាចផ្តល់ព័ត៌មានដែលមានប្រយោជន៍អំពីបញ្ហា ផ្តល់សេវាកម្ម។
- រៀបចំការសម្ភាសន៍ជាមួយប្រធានផ្នែកសេវាកម្មដែលពាក់ព័ន្ធចំពោះអ្នក។ សួរប្រធានផ្នែកសេវាសកម្មទាំងនេះ ថាតើថវិកាមានគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់ ហើយហេតុអ្វី សម្រាប់ការផ្តល់សេវា។ ចូរព្យាយាមស្វែងយល់ថាតើថវិកាបន្ថែមទៀតមួយណាដែលនឹងនាំមកនូវលទ្ធផលនៃសេវាកម្រិតណា។ កុំរារែកក្នុងការនិយាយជាមួយបុគ្គលិកធម្មតាផងដែរ។ តើមានអ្វីខ្លះដែលអាចធ្វើបានដើម្បីជំរុញទឹកចិត្តពួកគេឱ្យផ្តល់សេវា?
- តើអ្នកយល់ថា ការចំណាយចរន្ត ជួយនៅក្នុងការផ្តល់សេវាដែរឬទេ។

តើត្រូវប្រមូលយកព័ត៌មានអ្វីខ្លះ?
ព័ត៌មានអំពីប្រជាពលរដ្ឋ

- ប្រជាពលរដ្ឋ ជាម្ចាស់ឆ្នោតដែលអាចផ្តល់ព័ត៌មានយ៉ាងសំខាន់ថាតើថវិកាដែលចំណាយដោយស្រុក មានប្រសិទ្ធភាពឬទេ។
- ចុះទៅជួបប្រជាពលរដ្ឋធម្មតា អ្នកស្រុក ម្ចាស់ហាង/តូបលក់ទំនិញ ស្ត្រី ។ល។ ហើយសួរពួកគេអំពីអ្វីខ្លះដែលពួកគេរំពឹងថានឹងទទួលបានពីរដ្ឋបាលស្រុក។ សួរពួកគេតើគេអាចធ្វើអ្វីខ្លះដើម្បីកែលម្អឱ្យកាន់តែប្រសើរ។
- បន្ទាប់មក អ្នកគួរតែមានគំនិតមួយថាតើប្រជាពលរដ្ឋនៅមូលដ្ឋានយល់ពីការងាររបស់រដ្ឋបាលស្រុក ដែរឬទេ។

តើត្រូវប្រមូលយកឯកសារអ្វីខ្លះ?

ព័ត៌មានប្រៀបធៀប

- ដើម្បីយល់ពីថវិការបស់អ្នក ជាការសំខាន់ដែលត្រូវដឹងពីថវិកាផ្សេងទៀត! រៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយសមាជិកក្រុមប្រឹក្សាស្រុកមកពីស្រុកផ្សេងទៀត ទាំងស្រុកនៅជិតខាង ឬស្រុកដែលមានទំហំនិងសេដ្ឋកិច្ចស្រដៀងគ្នា។
- រៀបចំបញ្ជីថវិកាស្រុកមួយ ដែលនេះគួរតែជាភារកិច្ចរបស់សមាគមរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ប៉ុន្តែ គេគួរចាប់ផ្តើមធ្វើការការអភិវឌ្ឍសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាម្នាក់ៗ។
- បន្ទាប់មក អ្នកគួរតែយល់ដឹងអំពីថវិកាផ្សេងទៀត យល់ពីលក្ខណៈពិសេសរបស់ថវិកាទាំងនោះ ហើយប្រៀបធៀបថវិការបស់អ្នកជាមួយមធ្យមភាគជាតិ តួលេខមធ្យមភាគ តួលេខអប្បបរមា និងអតិបរមា។

ការកសាងសមត្ថភាព

អ្វីដែលអ្នកគួរដឹង

ការរៀបចំព័ត៌មានហិរញ្ញវត្ថុឡើងវិញដើម្បីបង្ហាញពីបញ្ហាសំខាន់ៗនៅក្នុងការរៀបចំថវិកា

ចំណេះដឹងស៊ីជម្រៅអំពីមធ្យោបាយ និងលំនាំនៃការផ្តល់សេវា

ការយល់ថា ប្រជាពលរដ្ឋជាអ្នកលើកកម្ពស់គុណភាពសេវា

ការរៀនប្រើសូចនាករគុណផលហិរញ្ញវត្ថុសំខាន់ៗដើម្បីយល់អំពីថវិការបស់ស្រុកកាន់តែច្បាស់

ការសាកសួរ ប្រកបដោយ ប្រសិទ្ធភាព

ការសាកសួរប្រកបដោយប្រសិទ្ធភាព

ការអនុវត្តជាវិជ្ជមាន

- សេចក្តីបរិយាយដោយសេរី និងសំណួរបើក – ការសួរសំណួរបើក និងទុកឱ្យអ្នកឆ្លើយនឹងសំណួរផ្តល់ការពន្យល់អំពីស្ថានភាពតាមការយល់ឃើញដោយខ្លួនឯង ឧទា. "តើអ្នកយល់ដូចម្តេចអំពីការចំណាយលើសគម្រោង...?"
- ការសាកសួរបន្ថែម – ដោយប្រើបច្ចេកទេសជាច្រើនដើម្បីទទួលបានព័ត៌មាន និងយល់ដឹងកាន់តែច្បាស់
- ការចោទសួរដេញដោល – "តើការចំណាយនេះគឺជាអ្វីពិតប្រាកដ?"
- ការលើកទឹកចិត្ត – "នោះគឺជាការចំណាយតិចពេកហើយ!" (ដោយរង់ចាំចម្លើយបន្ថែមទៀត)។

ការសាកសួរប្រកបដោយប្រសិទ្ធភាព
ការអនុវត្តជាវិជ្ជមាន

- ទទួលយក/ថាឡើងវិញ – "អ្នកបាននិយាយថា ពុំមានការព្យាករណ៍ថានឹងការចំណាយលើសនៅក្នុងផ្នែកនេះទេ តើអ្នកអាចពន្យល់បន្ថែមទៀតបានទេអំពីថាតើហេតុអ្វីបានជាដូច្នោះ?"
- ការសាកសួររកព័ត៌មានលម្អិត – "តើអ្នកបានធ្វើអ្វីផ្សេងទៀតដើម្បីកាត់បន្ថយការចំណាយទេ?"
- សំណួរដោយផ្ទាល់ – "តើអាជ្ញាធរផ្សេងទៀតធ្វើអ្វីខ្លះដើម្បីរក្សាការចំណាយតាមថវិកាដែលមាន?"
- បង្ហាញពីការយល់ – "អូ ខ្ញុំដឹងហើយ" (ទុកពេលឱ្យអ្នកឆ្លើយនឹងសំណួរ ធ្វើការពន្យល់)។

ការប្រមូលទិន្នន័យប្រកបដោយប្រសិទ្ធភាព

ប្រភពទិន្នន័យ

- សមាជិកក្រុមប្រឹក្សាអាចប្រមូលភ័ស្តុតាងពីប្រភពជាច្រើន៖
- ស្នើសុំភ័ស្តុតាងជាលាយលក្ខណ៍អក្សរពីបុគ្គលនិងអង្គការខាងក្នុងនិងខាងក្រៅ។
- ពិនិត្យឡើងវិញលើផែនការ យុទ្ធសាស្ត្រ ផែនការសេវាកម្ម និងរបាយការណ៍របស់ក្រុមប្រឹក្សា ដែលពាក់ព័ន្ធទៅនឹងប្រធានបទដែលចង់ដឹង។

ការប្រមូលទិន្នន័យប្រកបដោយប្រសិទ្ធភាព

ប្រភពទិន្នន័យ

- ពិនិត្យឡើងវិញលើគោលការណ៍ណែនាំ ច្បាប់ និងឯកសាររបស់រដ្ឋាភិបាលដែលពាក់ព័ន្ធ
- ពិនិត្យឡើងវិញលើគោលការណ៍ណែនាំ មគ្គុទ្ទេសក៏ស្តីពីការអនុវត្តល្អពីស្ថាប័នជាតិនិងតំបន់ ឧទាហរណ៍ សមាគមរដ្ឋាភិបាលថ្នាក់មូលដ្ឋាន
- ពិនិត្យឡើងវិញលើរបាយការណ៍និងផែនការល្អៗនិងនវានុវត្តន៍ ពីអាជ្ញាធរមូលដ្ឋានផ្សេងទៀត។

ការប្រមូលទិន្នន័យប្រកបដោយប្រសិទ្ធភាព

ប្រភព

- មានប្រភពជាច្រើនដែលគេអាចទទួលបានសាក្សី។ នៅខាងក្នុង សាក្សីអាចរួមមានសមាជិកគណៈរដ្ឋមន្ត្រីដែលពាក់ព័ន្ធ សមាជិកមន្ត្រីដែលពាក់ព័ន្ធនៃស្ថាប័នផ្សេងទៀត។ សាក្សីខាងក្រៅអាចទទួលបានពីបុគ្គល និងអង្គការជាច្រើន ដូច្នេះ សមាជិកគួររៀបចំបញ្ជីភាគគីពាក់ព័ន្ធ ដើម្បីទទួលបានសាក្សីត្រឹមត្រូវ។ ក្រុមប្រឹក្សាមានភាគីពាក់ព័ន្ធជាច្រើន ពោលគឺ អ្នកដែលមានចំណាប់អារម្មណ៍លើបញ្ហាដែលដែលក្រុមប្រឹក្សាចង់ដឹង ឬក្រុមប្រឹក្សាមានចំណាប់អារម្មណ៍លើបញ្ហាដែលពួកគេចង់ដឹង។ ភាគីពាក់ព័ន្ធមួយចំនួន ត្រូវបានកំណត់ដូចខាងក្រោម៖
- សំណួរដែលពាក់ព័ន្ធសម្រាប់សាក្សី គួរត្រូវបានរៀបចំជាមុននៅមុនកិច្ចប្រជុំ។ សំណួរគួរតែជាសំណួរបើក ដើម្បីទទួលបានភស្តុតាងច្រើន។ ព័ត៌មានត្រូវបានស្នើសុំតាមបែប អព្យាក្រឹត្យ ហើយសាក្សីត្រូវបានលើកទឹកចិត្តឱ្យនិយាយឱ្យបានច្រើនបំផុត និងពន្យល់បន្ថែមលើចំណុចដែលពួកគេបានលើកឡើង។

ការប្រមូលទិន្នន័យប្រកបដោយប្រសិទ្ធភាព

ប្រភព

- ការប្រមូលយកភ័ស្តុតាងជាលាយលក្ខណ៍អក្សរនិងផ្ទាល់មាត់ មិនមែនជាវិធីដែលមានតែមួយគត់នោះទេ។ មានវិធីជាច្រើនទៀត ដូចជា៖
- ការចុះទៅទីកន្លែងផ្ទាល់ – ទាំងនៅក្នុងក្រុមប្រឹក្សា និងទៅកន្លែងគោលដៅនៅខាងក្រៅ
- ការប្រើករណីសិក្សា
- ការរៀបចំធ្វើការសិក្សាស្រាវជ្រាវ
- ការចូលរួមកិច្ចប្រជុំ/សន្និសីទនានា
- ការចុះទៅជួបអាជ្ញាធរមូលដ្ឋានផ្សេងទៀត និងអង្គការដៃគូនានា
- សិក្ខាសាលា

ជំហានប្រាំ

- ការរៀបចំផែនការដំណើរការពិនិត្យពិច័យថ្នាក់មូលដ្ឋាន

ជំហានទី 1: ជ្រើសរើសប្រធានបទ

ជំហានទី 2: រៀបចំផែនការ

ជំហានទី 3: ប្រមូលភ័ស្តុតាង

ជំហានទី 4: រៀបចំ និងឯកភាពលើរបាយការណ៍

ជំហានទី 5: ការបញ្ជូនរបាយការណ៍ និងការតាមដានបន្ត

សូចនាករគុណផលសំខាន់ៗ

សូចនាករគុណផលសំខាន់ៗមួយចំនួន

KPI

- *ផលធៀប ប្រភពចំណូលផ្ទាល់ដែលបានគ្រោង = ប្រភពចំណូលផ្ទាល់ដែលបានគ្រោង / ថវិកាសរុប*
- *ផលធៀប ប្រភពចំណូលផ្ទាល់ជាក់ស្តែង = ប្រភពចំណូលផ្ទាល់ជាក់ស្តែង / ថវិកាសរុប*
- *ផលធៀបអនុវត្តថវិកា = ចំណាយដែលបានគ្រោងសរុប / ចំណាយជាក់ស្តែងសរុប*
- *ផលធៀបចំណាយមូលធន = ចំណាយមូលធនជាក់ស្តែងសរុប / ចំណាយជាក់ស្តែងសរុប*
- *ផលធៀបចំណាយលើបុគ្គលិក = ចំណាយលើបុគ្គលិកជាក់ស្តែងសរុប / ចំណាយចរន្តជាក់ស្តែងសរុប*

សំណួរ

សំណួរសម្រាប់រៀបចំថវិកា

ចំណុចជាមូលដ្ឋាន

សំណួរទាំងឡាយខាងក្រោមនេះ មានសារៈសំខាន់ជាសារវន្តសម្រាប់ការពិនិត្យពិច័យនៃដំណើរការរៀបចំថវិកា៖

១. តើផែនការចំណាយដែលបានស្នើឡើង សមស្របតាមគោលដៅរួម គោលបំណង និងអាទិភាពរបស់ក្រុមប្រឹក្សា ដែរឬទេ?

២. តើមធ្យោបាយដើម្បីវាស់វែងលទ្ធផល/ធាតុចេញ ត្រូវបានបញ្ជាក់ច្បាស់ឬទេ?

៣. តើមានឱកាសអ្វីខ្លះដើម្បីរកប្រាក់ចំណូលសម្រាប់ក្រុមប្រឹក្សា (ឧទា. ពីថ្លៃសេវា ថ្លៃសេវារដ្ឋបាល ។ល។)?

សំណួរសម្រាប់រៀបចំថវិកា

ចំណុចជាមូលដ្ឋាន (ត)

៤. តើចំណុចដៅត្រូវបានកំណត់ឬទេ? តើចំណុចដៅទាំងនោះអាចទទួលយកបានឬទេ ហើយតើចំណុចដៅទាំងនេះនឹងត្រូវបានតាមដានមើលដោយសមាជិកក្រុមប្រឹក្សាដូចម្តេច?

៥. តើថវិកាត្រូវបានពិនិត្យមើលល្អិតល្អន់ដោយសមាជិកឬទេ និងត្រូវបានកំណត់យោងតាមផែនការហិរញ្ញវត្ថុ រយៈពេលមធ្យម ដែរឬទេ?

៦. តើថវិកានោះមានការផ្សារភ្ជាប់ជាមួយតម្រូវការសេវាដែលរំពឹងទុក បានល្អប៉ុណ្ណា?

សំណួរសម្រាប់ត្រួតពិនិត្យតាមដានថវិកា
ចំណុចជាមូលដ្ឋាន

សំណួរទាំងឡាយខាងក្រោមនេះ មានសារៈសំខាន់ជាសារវន្តសម្រាប់ការពិនិត្យពិច័យនៃការតាមដានថវិកានៅក្នុងឆ្នាំថវិកានីមួយៗ៖

១. តើការចំណាយសម្រេចបាន (ឬជួយសម្រេចបាន) គោលបំណងគុណផលដែលបានកំណត់ដោយសមាជិកដែរឬទេ?

២. តើមន្ត្រីមានការយល់ដឹងអំពីមូលហេតុនៃការចំណាយតិចជាង ឬចំណាយលើសគម្រោង ដែរឬទេ?

៣. តើការចំណាយក្រោម/លើសគម្រោង មានផលប៉ះពាល់អ្វីខ្លះទៅលើការសម្រេចបានផែនការ និងគោលនយោបាយរបស់ក្រុមប្រឹក្សា?

សំណួរសម្រាប់ត្រួតពិនិត្យតាមដានថវិកា

ចំណុចជាមូលដ្ឋាន (ត)

៤. តើផលប៉ះពាល់នេះ ត្រូវបានគេពិចារណាសម្រាប់ថវិកានៅឆ្នាំបន្ទាប់ និងថវិកាក្នុងពេលអនាគតឬទេ?

៥. តើចំណុចដៅនៃការប្រមូលចំណូល ត្រូវបានសម្រេចដែរឬទេ?

៦.តើមានហានិភ័យអ្វីខ្លះ ប្រសិនបើសម្រេចមិនបាន? តើបញ្ហាទាំងនេះនឹងត្រូវបានត្រួតពិនិត្យតាមដាន និងដោះស្រាយ ដូចម្តេច?

The programme is co-funded by the European Union and German Federal Ministry for Economic Cooperation and Development (BMZ). The contents of this publication are the sole responsibility of the Decentralisation and Administrative Reform Programme and can in no way be taken to reflect the views of the European Union.

កម្មវិធីត្រូវបានផ្តល់មូលនិធិរួមគ្នាដោយសហភាពអឺរ៉ុប និងក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍនៅសហព័ន្ធអាល្លឺម៉ង់ (BMZ)។ ខ្លឹមសារក្នុងអត្ថបទនេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់កម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។

Co-funded by the European Union

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

គជអប
NCDD

EU DAR
European Union Project for Decentralisation and Administrative Reform